គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

UCSF

# ការពិចារណាឡើងវិញពីផលប៉ះពាល់នៃទេសន្តរប្រវេសន៍ នៅលើឪពុកម្ដាយវ័យចំណាស់

## ករណីសិក្សាអំពីឃុំចំនួនពីរ នៅក្នុងខេត្តបាត់ដំបង ប្រទេសកម្ពុជា



គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) នៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
និងសកលវិទ្យាល័យកាលីហ្វញ៉ា រដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ (UCSF)







ADI និង UCSF សូមថ្លែងអំណរគុណចំពោះ វិទ្យាស្ថានអន្តរជាតិ DOHA សម្រាប់ការសិក្សាអំពីគ្រួសារ
និងការអភិវឌ្ឍន៍ ដែលជួយគាំទ្រ នៅក្នុងកិច្ចសហការស្រាវជ្រាវនេះ

ខែ វិច្ឆិកា ឆ្នាំ២០១១

# ការពិចារណាឡើងវិញពីផលប៉ះពាល់នៃ ទេសន្តរប្រវេសន៍ នៅលើឪពុកម្តាយវ័យចំណាស់

## ករណីសិក្សាអំពីឃុំចំនួនពីរ នៅក្នុងខេត្តបាត់ដំបង ប្រទេសកម្ពុជា


គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ **(ADI)**
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

និង

សកលវិទ្យាល័យកាលីហ្វញ៉ា រដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ (UCSF)


**វិច្ឆិកា ២០១១**


ADI និង UCSF សូមថ្លែងអំណរគុណចំពោះការជួយគាំទ្ររបស់វិទ្យាស្ថានអន្តរជាតិដូហា សម្រាប់ការសិក្សាអំពីគ្រួសារ និងការអភិវឌ្ឍន៍ ក្នុងកិច្ចសហការស្រាវជ្រាវនេះ

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារគំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) នៃអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និង សិក្ខាកាមនៃវគ្គជាន់ខ្ពស់របស់គំរោងវិភាគបញ្ហា អភិវឌ្ឍន៍ជំនាន់ទី ៥។

ក្រុមស្រាវជ្រាវសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការរួមចំណែកពីសំណាក់លោកសាស្ត្រាចារ្យ Zachary Zimmer នៃសាកលវិទ្យាល័យកាលីហ្វ័រនី និង លោកសាស្ត្រាចារ្យ John Knodel មកពីមជ្ឈមណ្ឌល សិក្សាស្រាវជ្រាវប្រជាសាស្ត្រនៃសាកលវិទ្យាល័យមីស៊ីហ្គេន។ កិច្ចសហការនេះត្រូវ បានរួមចំណែកគាំទ្រជាថវិកាពី វិទ្យាស្ថានអន្តរជាតិ DOHA សម្រាប់ការសិក្សាអំពីគ្រួសារ និងការអភិវឌ្ឍន៍ ។ ក្រុមអ្នកស្រាវជ្រាវក៏សូមថ្លែងអំណរគុណផងដែរ ចំពោះម្ចាស់ជំនួយនៃគំរោងវិភាគ បញ្ហាអភិវឌ្ឍន៍ រួមមាន DanChurchAid/Christian Aid, Trocaire, Broederlijk Delen (BD), Oxfam Hong Kong, Evangelischer Entwicklungsdienst (EED) and Ecumenical Scholarships Program (ESP) ដែលបាន ផ្តល់ថវិកាសំរាប់ការស្រាវជ្រាវនេះ ។

# មាតិកា


**សង្ខេប** ៤

**សេចក្តីផ្តើម** ៥

សំនួរស្រាវជ្រាវ ៩

វិធីសាស្ត្រស្រាវជ្រាវ ១០

**លទ្ធផលស្រាវជ្រាវ** ១៤

ការរៀបចំការរស់នៅរបស់ឪពុកម្តាយ និងកូន ១៤

ផលប៉ះពាល់នៃទេសន្តរប្រវេសន៍ទៅលើសុខុមាលភាពរបស់ឪពុកម្តាយ ២៤

កិច្ចគាំទ្រគ្នាជាសម្ភារៈ និងថវិកា ៣០

ទំនាក់ទំនងសង្គមរវាងឪពុកម្តាយ និងកូន ៣៦

ការថែទាំចៅ ៣៩

សុខភាព និងសុខុមាលភាពផ្លូវចិត្តរបស់ឪពុកម្តាយ ៤១

**សេចក្តីសន្និដ្ឋាន** ៤៦

**ឯកសារយោង** ៥២

**អ្នកស្រាវជ្រាវ** ៥៤

# សង្ខេប

ការសិក្សាស្រាវជ្រាវនេះ ដែលត្រូវបានធ្វើឡើងក្រោមកិច្ចសហការរវាងគំរោង ADI ជាមួយ សកលវិទ្យាល័យកាលីហ្វញ៉ា រដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ មានបំណងដោះស្រាយសំនួរចម្បងចំនួនពីរ ៖ តើការធ្វើ ទេសន្តរ ប្រវេសន៍របស់កូនដែលពេញវ័យ បង្កឲ្យមានផលប៉ះពាល់ទៅលើសុខុមាលភាព របស់ឪពុកម្តាយវ័យ ចំណាស់ ដែលពួកគេបន្សល់ទុកនៅទីជនបទដោយរបៀបណា និងតើការធ្វើ ទេសន្តរប្រវេសន៍នេះ បង្កឲ្យមានផលប៉ះពាល់ទៅលើការរួបរួមគ្នា រវាងមនុស្សពីជំនាន់មួយទៅ ជំនាន់មួយទៀតយ៉ាងដូចម្តេច? ការស្រាវជ្រាវត្រូវបានធ្វើឡើងនៅក្នុងឃុំចំនួនពីរ នៃខេត្តបាត់ដំបង ក្នុងខែមិថុនា និងកក្កដា ឆ្នាំ២០១០ ដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យនិងគុណវិស័យ។ កម្រងសំនួរអង្កេតមួយ ដែលបានធ្វើការសាកសួរទៅលើឪពុកម្តាយ ចំនួន ២៦៥នាក់ ដែលមាន អាយុចន្លោះពី ៦០ឆ្នាំ ទៅ ៧០ឆ្នាំ ផ្តល់នូវព័ត៌មានអំពីអ្នកផ្តល់ការឆ្លើយតប និងកូនរបស់ពួកគេ ចំនួន ១.២៦៨នាក់។ បន្ថែមពីនេះទៀត គេបានធ្វើកិច្ចសម្ភាសន៍ចំនួន ៣០ ដោយការសួរសំនួរបើក ដើម្បីពិនិត្យតាមដានបន្ត ជាមួយសំណាករងនៃអ្នកផ្តល់ការឆ្លើយតបដែលមានវ័យចំណាស់ ដែល សកម្មភាពបែបនេះ បាន បំពេញបន្ថែមនូវព័ត៌មានជាច្រើនទៅលើទិន្នន័យនេះ។

ការសិក្សាស្រាវជ្រាវបានពិនិត្យមើលទៅលើផលវិបាកនៃការធ្វើទេសន្តរប្រវេសន៍ ចំពោះ ឪពុកម្តាយ ដែលមានវ័យចំណាស់ ទាក់ទងទៅនឹងការរៀបចំការរស់នៅរបស់ឪពុកម្តាយនិងកូន ផលប៉ះពាល់ នៃការធ្វើទេសន្តរប្រវេសន៍ ទៅលើសុខុមាលភាពរបស់ឪពុកម្តាយ ការជួយគ្នាជា សម្ភារៈ និងជាថវិកា ទំនាក់ទំនងសង្គម រវាងឪពុកម្តាយនិងកូន ការថែទាំចៅ ព្រមទាំងសុខភាព និង សុខុមាលភាព ផ្លូវចិត្តរបស់ឪពុកម្តាយ។ ការសិក្សានេះ បង្ហាញជាទូទៅអំពីផលប៉ះពាល់ជាវិជ្ជមាន នៃការធ្វើទេសន្តរប្រវេសន៍ ទៅលើសុខុមាលភាពរបស់ឪពុកម្តាយដែលមានវ័យចំណាស់។ ចំណុច នេះ ផ្តល់ នូវកិច្ចគាំទ្រមួយចំនួនទៅលើគោលគំនិតថា "ការផ្លាស់ប្តូរទំនាក់ទំនងនៅក្នុងគ្រួសារធំ" កំពុងកើតមានឡើង រវាងឪពុកម្តាយដែលមានវ័យចំណាស់ និងកូន ដែលធ្វើទេសន្តរប្រវេសន៍នៅ ក្នុងប្រទេសកម្ពុជា។ ស្របពេលជាមួយគ្នានេះដែរ ការរួបរួមគ្នាពីជំនាន់មួយទៅជំនាន់មួយ រវាង ឪពុកម្តាយ និងកូនដែលធ្វើទេសន្តរប្រវេសន៍ និងកូនដែលមិនធ្វើទេសន្តរប្រវេសន៍ កើតឡើងនៅ ក្នុងបរិបទរួមមួយនៃភាពក្រីក្រ។ គ្រួសារដែលមានកូនតិច និងគ្រួសារដែលទំនងនឹងមានទំហំកាន់ តែតូចនៅពេលអនាគត អាចបង្កឲ្យមានផលប៉ះពាល់ទៅលើការប្រាស្រ័យទាក់ទងរវាងមនុស្សមួយ ជំនាន់ទៅមនុស្សមួយជំនាន់ទៀត។

# សេចក្តីផ្តើម

ការធ្វើចលនារបស់មនុស្សពីតំបន់ជនបទ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទៅកាន់តំបន់ទីក្រុង និងឆ្លងកាត់ព្រំដែន ជាពិសេសដើម្បីស្វែងរកការងារធ្វើ គឺជាផលវិបាកមួយនៃការអភិវឌ្ឍន៍ និងដំណើរការសកលភាវូបនីយកម្ម ដែលមិនអាចគេចផុតបាន។ ការធ្វើទេសន្តរប្រវេសន៍ ដើម្បីស្វែងរកការងារ ធ្វើប្រភេទនេះ បានក្លាយទៅជាតថភាពជាក់ស្តែងមួយ ដែលកំពុងកើតមានឡើងយ៉ាងឆាប់រហ័ស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន រាប់បញ្ចូល ប្រទេសកម្ពុជាផងដែរ (Chan, 2008)។ បើទោះជាដូច្នេះក្តី លក្ខណៈដែលបញ្ហានេះបង្កឲ្យមានផលប៉ះពាល់ទៅលើសមាជិកគ្រួសារ រាប់បញ្ចូល ការរួបរួមគ្នា រវាងសមាជិកគ្រួសារពីជំនាន់មួយទៅជំនាន់មួយទៀត នៅតែបន្តជាបញ្ហាមួយគួរឲ្យ កត់សម្គាល់សម្រាប់យកមកធ្វើការពិភាក្សាវែកញែក។ វេទិកាអន្តរជាតិ ដែលទាក់ទងទៅនឹងបញ្ហាការតស៊ូមតិ និងប្រព័ន្ធផ្សព្វផ្សាយចម្រុះ ហាក់មានទស្សនៈចំពោះការធ្វើទេសន្តរប្រវេសន៍ ថាជាការធ្វើឲ្យគ្រួសារមានការចុះខ្សោយ និងនាំឲ្យមានការបាត់បង់កិច្ចគាំទ្រផ្នែកសេដ្ឋកិច្ច កិច្ចគាំទ្រសង្គម និងកិច្ចគាំទ្រផ្លូវចិត្ត ព្រមទាំងការថែទាំផ្ទាល់ខ្លួន សម្រាប់ឪពុកម្តាយដែលមានវ័យចំណាស់ ដោយ សារតែអវត្តមានរបស់កូន (Knodel et al, 2010)។ មនុស្សចាស់ ដែលត្រូវបានកូនបន្សល់ទុកឲ្យ ថែទាំខ្លួនឯងនៅក្នុងតំបន់ជនបទ ដោយសារតែកូនរបស់ពួកគេដែលពេញវ័យធ្វើនិរប្រវេសន៍ ក៏ជា បញ្ហាទូទៅ នៅក្នុងឯកសាររបស់កម្ពុជាផងដែរ។

ការសិក្សាមួយរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែល ទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោក មានចំណងជើងថា *ការបោះជំហានចេញពីភាព ក្រីក្រ?* បានកំណត់ថា ការធ្វើទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារដែលទទួលបានប្រាក់កម្រៃ គឺជាចរន្តមួយដ៏សំខាន់ សម្រាប់ធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់បុគ្គល។ បើទោះជាដូច្នេះក្តី អ្នកសរសេររបាយការណ៍ ក៏បានដកស្រង់អំពីការធ្វើចលនារបស់ប្រជាជនចេញពីតំបន់ជនបទ ថាជាការជម្រុញឲ្យមានការផ្លាស់ប្តូរប្រជាសាស្ត្រ ឆ្ពោះទៅរកភាពវេចរិលនៃប្រភពនៃកិច្ចការពារបែបប្រពៃណី ចំពោះមនុស្សចាស់ដែលកំពុងរស់នៅក្នុងតំបន់ទាំងនោះនៅឡើយ (FitzGerald et al, 2007)។ ការសិក្សាស្រាវជ្រាវមួយទៀត របស់ CDRI ដែលត្រូវបានធ្វើឡើងក្រោមកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី បានដកស្រង់ការធ្វើទេសន្តរប្រវេសន៍ ថាជាការពន្លឿនចំពោះការធ្វើឲ្យមានអស្ថេរភាពទៅលើតំបន់ជនបទ៖ "ខណៈពេលដែលបុរសស្ត្រីវ័យក្មេង ដែលមានកាយសម្បទារឹងមាំ ចាកចេញពីភូមិរបស់ពួកគេម្តងមួយៗ ដោយបន្សល់ទុកនូវមនុស្សចាស់ និងកុមារតូចៗ ព្រមទាំងជនក្រីក្រឲ្យនៅថែទាំស្រែចម្ការ" (Murshid, 2007)។ និយាយឲ្យខ្លី សេចក្តីថ្លែងទាំងនេះបង្កប់អត្ថន័យថា ការធ្វើទេសន្តរប្រវេសន៍របស់កូនដែលជាមនុស្សពេញវ័យ ចេញពីផ្ទះឪពុកម្តាយរបស់ពួកគេ នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា មានសក្តានុពលក្នុងការបង្អាក់ដំណើរ

ការ និងធ្វើឲ្យរេចរិលនូវគុណតម្លៃ និងនិយាម ដែលត្រូវបានបង្កើតឡើង ព្រមទាំងទទួលបានការគោរពជាយូរយារណាស់មកហើយ ដែលគុណតម្លៃ និងនិយាមទាំងនេះ បានពង្រឹងទៅលើគ្រួសារ និងការរក្សាឲ្យមាននូវការរួបរួមសមាជិកគ្រួសារពីមួយជំនាន់ទៅមួយជំនាន់ទៀត។ រូបភាពអវិជ្ជមានទាំងនេះ ស្របទៅនឹងទស្សីករទូលំទូលាយមួយ ដែលពិនិត្យមើលទៅលើដំណើរការទូទៅនៃការអភិវឌ្ឍន៍ (ដែលកំណើននៃការធ្វើទេសន្តរប្រវេសន៍ គឺជាផ្នែកមួយដ៏សំខាន់) ថាធ្វើឲ្យមានការចុះខ្សោយចំពោះគ្រួសារធំ និងមុខងាររបស់វា ក្នុងលក្ខណៈជាប្រភពមួយដែលផ្តល់ការគាំទ្រចំពោះមនុស្សចាស់ (Aboderin, 2004; Hendricks and Yoon, 2006; Hermalin et al, 2003)។

ស្របពេលជាមួយគ្នានេះដែរ មានទស្សនវិស័យដោយឡែកមួយចំនួន ដែលពិនិត្យមើលទៅលើផលប៉ះពាល់នៃការធ្វើទេសន្តរប្រវេសន៍ ចំពោះគ្រួសារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងលក្ខណៈមួយដែលមិនសូវមានភាពអវិជ្ជមាន។ ភាគច្រើននៅក្នុងឯកសារនេះ ការធ្វើទេសន្តរប្រវេសន៍ ត្រូវបាន គេមើលឃើញ ថាជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រួសារ ក្នុងការធ្វើឲ្យមានហានិភ័យផ្សេងគ្នា សម្រាប់គ្រួសារ និងការផ្តល់ប្រយោជន៍សម្រាប់សមាជិកគ្រួសារដែលធ្វើទេសន្តរប្រវេសន៍ និង សមាជិកដែលមិនធ្វើទេសន្តរប្រវេសន៍ រាប់បញ្ចូលឪពុកម្តាយវ័យចំណាស់ ដែលភាគច្រើនបន្តរស់នៅកន្លែងដើមរបស់គាត់ (Cai, 2003; Stark and Bloom, 1985; Stark and Lucas, 1988; Vanwey, 2004)។ បើទោះជាដូច្នេះក្តី ឯកសារនេះភាគច្រើនមានមូលដ្ឋានផ្អែកលើតំបន់ទីក្រុង និងស្តែងចេញពីទស្សនវិស័យរបស់ជនទេសន្តរប្រវេសន៍។ បើទោះបីជានៅពេលដែលសមាជិកគ្រួសារមួយចំនួនដែលពុំមែនជាជនទេសន្តរប្រវេសន៍ ត្រូវបានគេយកមកពិចារណាក៏ដោយ មានការសិក្សាតិចតួច ដែលផ្តោតយកចិត្តទុកដាក់ជាក់លាក់អំពីផលប៉ះពាល់ទៅលើឪពុកម្តាយ ដែលមានវ័យចំណាស់។ បន្ថែមពីនេះទៀត ការផ្តោតយកចិត្តទុកដាក់នៃការសិក្សាស្រាវជ្រាវទាំងនេះ ភាគច្រើនផ្តោតទៅលើតែសញ្ញាណ សម្រាប់បំលាស់ប្តូរសេដ្ឋកិច្ច ច្រើនជាងកម្រងពេញលេញនៃកិច្ចគាំទ្រដែលកូនផ្តល់ជូនចំពោះឪពុកម្តាយ ដែលរាប់បញ្ចូលការប្រាស្រ័យទាក់ទងសង្គម ការផ្តល់ជំនួយនៅក្នុងការរស់នៅប្រចាំថ្ងៃ និងការថែទាំសុខភាព។

ទស្សនវិស័យមួយដែលពិចារណាទៅលើកម្រងនៃផលប៉ះពាល់មួយចំនួន និង ផ្តោតយកចិត្តទុក ដាក់ទូលំទូលាយជាងនេះទៅលើរបៀបដែលទំនាក់ទំនង និងរចនាសម្ព័ន្ធគ្រួសារមានការផ្លាស់ប្តូរ ខណៈពេលដែលសង្គមងាកចេញពីវិស័យកសិកម្ម ទៅឧស្សាហកម្មនិងបន្ទាប់មក បោះជំហានចូលទៅក្នុងទម្រង់ក្រោយឧស្សាហកម្មគឺជាទស្សនវិស័យដែលសំដៅចំពោះ "ការផ្លាស់ប្តូរគ្រួសារធំ" (Knodel et al, 2010; Litwak, 1960, 1987; Smith, 1998)។ ជំនួសឲ្យការដែលការអភិវឌ្ឍន៍នាំឲ្យ ឈានទៅរកការបញ្ចប់ទំនាក់ទំនងគ្រួសារធំ វត្តមាននៃទម្រង់ដែលត្រូវបានផ្លាស់ប្តូរ មានលក្ខណៈ ស្របទៅនឹងស្ថានភាពដែលកំពុងប្រែប្រួល។ យោងតាមទស្សនៈនេះ និងអាស្រ័យដោយភាព រីកចម្រើននៃបច្ចេកវិទ្យា ជាពិសេសទាក់ទងទៅនឹងមធ្យោបាយធ្វើដំណើរការ និងការប្រាស្រ័យ ទាក់ទង បានអនុញ្ញាតឲ្យសមាជិកគ្រួសារ រក្សាទំនាក់ទំនងជិតស្និទ្ធ និងបំពេញការទទួលខុសត្រូវ មួយចំនួន (បើទោះបីជាមិនបានទាំងអស់ក៏ដោយ) សម្រាប់គ្នាទៅវិញទៅមក

រាប់បញ្ចូលកាតព្វកិច្ច ចំពោះឪពុកម្ដាយមានវ័យចំណាស់ ដែលកាលពីមុន ត្រូវការឲ្យរស់នៅកន្លែងក្បែរគ្នា។ មកទល់ នឹងពេលនេះ គោលគំនិតនៃ "ការផ្លាស់ប្ដូរគ្រួសារធំ" ត្រូវបានយកមកពិភាក្សាភាគច្រើននៅក្នុង បរិបទរបស់ប្រទេសលោកខាងលិច ដែលមានកម្រិតសេដ្ឋកិច្ចខ្ពស់ ជាពិសេសនៅក្នុងសហរដ្ឋអាមេរិក។ យ៉ាងណាមិញ វិធីដែលគេអាចបំពេញរចនាសម្ព័ន្ធគ្រួសារសំខាន់ៗ នៅក្នុងរយៈចម្ងាយ ភូមិសាស្ត្រមួយ និងវិសាលភាពដែលគេអាចរក្សាបាននូវរចនាសម្ព័ន្ធគ្រួសារទាំងនេះ ក្នុងការពិនិត្យមើលទៅលើគុណតម្លៃរបស់សង្គមមួយ ដែលកំពុងមានការប្រែប្រួល គឺស្ថិតនៅក្នុងបរិបទនៃ ប្រទេសកំពុងអភិវឌ្ឍន៍ (Knodel et al, 2010)។

ប្រទេសកម្ពុជា ដែលជាទីកន្លែងនៃការស្រាវជ្រាវបច្ចុប្បន្ន ផ្ដល់នូវករណីមួយដែលមានលក្ខណៈគួរ ឲ្យចាប់អារម្មណ៍ជាពិសេស ដើម្បីសិក្សាទៅលើផលវិបាកនៃការធ្វើទេសន្តរប្រវេសន៍ទៅលើជីវិត រស់នៅរបស់គ្រួសារ។ ប្រទេសកម្ពុជា ធ្លាប់បានជួបប្រទះការធ្វើចលនាប្រជាសាស្ត្រទូទាំងប្រទេស ក្នុងអំឡុងសម័យខ្មែរក្រហម និងក្រោយសម័យខ្មែរក្រហម ដែលបណ្ដាលឲ្យប្រជាជនមួយចំនួនធំ ធ្វើការតាំងទីលំនៅឡើងវិញ នៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទ។ ការធ្វើទេសន្តរប្រវេសន៍ទាំងនេះ បានបញ្ចប់នៅចុងទសវត្សឆ្នាំ១៩៩០ ជាមួយនឹងការធ្វើមាតុភូមិនិវត្តរបស់ជនភៀសខ្លួនកម្ពុជា រាប់ពាន់នាក់ពីព្រំដែនប្រទេសថៃ និងការដែលរដ្ឋាភិបាលបានគ្រប់គ្រងទៅលើបន្ទាយចុងក្រោយរបស់ខ្មែរក្រហម។ ខណៈពេលដែលការធ្វើទេសន្តរប្រវេសន៍ដោយសារបញ្ហាជម្លោះ បានមានភាពស្ងប់ស្ងាត់ទៅវិញ ការផ្លាស់ប្ដូរសេដ្ឋកិច្ច និងសង្គម បានផ្ដល់នូវកម្លាំងចលករមួយ ចំពោះការធ្វើទេសន្តរប្រវេសន៍ដែលមានការជម្រុញពីទីផ្សារ ដោយចាកចេញពីតំបន់ជនបទទៅកាន់តំបន់ទីក្រុងជាពិសេស គឺរាជធានីភ្នំពេញ និងឆ្លងកាត់ព្រំដែនអន្តរជាតិ ជាពិសេស គឺការឆ្លងកាត់ព្រំដែនទៅ ប្រទេសថៃ។ នៅក្នុងទសវត្សឆ្នាំ១៩៩០ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាស្ថិតនៅក្នុងសម័យអន្តរកាល ដើម្បីបោះជំហានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារបើកចំហមួយ បានធ្វើឲ្យមានការកើនឡើង យ៉ាងឆាប់រហ័សនូវឧស្សាហកម្មកាត់ដេរ ការរីកចម្រើននៅក្នុងវិស័យទេសចរណ៍ និងសំណង់ ព្រមទាំងការធ្វើសមាហរណកម្មជាច្រើនទៀត ជាមួយទីផ្សារតំបន់ និងទីផ្សារសកល។ ការអភិវឌ្ឍន៍ ទាំងនេះ បានបង្កើតឲ្យមាននូវតម្រូវការពលកម្មជាច្រើន ដែលមានការសម្របសម្រួលពីការពង្រីក បណ្ដាញទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធ។ ស្របពេលជាមួយគ្នានោះដែរ មានកត្តាជាច្រើន ដែលបានលើកទឹកចិត្តឲ្យប្រជាជនវ័យក្មេងធ្វើទេសន្តរប្រវេសន៍ចាកចេញពីគ្រួសាររបស់ពួកគេ ដើម្បីស្វែងរកការងារធ្វើ។ កត្តាទាំងនោះរួមមាន ការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនប្រជាជន ផលិតភាពកសិកម្មមានកម្រិតទាប បរាជ័យជាបន្តបន្ទាប់នៅក្នុងការបង្កបង្កើនផល ដែលបណ្ដាល មកពីគ្រោះរាំងស្ងួត និងទឹកជំនន់ ក្នុងអំឡុងឆ្នាំ២០០០/២០០៥ ការធ្លាក់ចុះយ៉ាងឆាប់រហ័សនូវ ធនធានធម្មជាតិ ការបាត់បង់លទ្ធភាពទទួលបានធនធានធម្មជាតិលក្ខណៈប្រពៃណី និងកង្វះ ឧស្សាហកម្មនៅក្នុងតំបន់ជនបទ (Murshid, 2007; FitzGerald et al, 2007; Analyzing Development Issues, 2005; Ang et al, 2007; Ballard, 2007; Lim, 2008)។

ការសិក្សាស្រាវជ្រាវរបស់ CDRI ដែលមានចំណងជើងថា *ការបោះជំហានចេញពីភាពក្រីក្រ?* បានកំណត់ថា ការធ្វើទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារ គឺជាចរន្តមួយដ៏សំខាន់សម្រាប់ធ្វើឲ្យ ប្រសើរឡើងនូវសុខុមាលភាពរបស់គ្រួសារ និងសហគមន៍។ ស្របពេលជាមួយគ្នានេះដែរ ការសិក្សាស្រាវជ្រាវបានទាញការប្រុងប្រយ័ត្នថា ទេសន្តរប្រវេសន៍ពុំមែនជាដំណោះស្រាយឆាប់ រហ័សមួយ ដើម្បីកាត់បន្ថយភាពក្រីក្រឡើយ អាស្រ័យដោយផលប៉ះពាល់របស់វាតែងមានការប្រែប្រួល និងមានរយៈពេលខ្លី (FitzGerald et al, 2007)។ ការសិក្សាស្រាវជ្រាវដែលត្រូវបានធ្វើឡើង ក្នុងលក្ខណៈជាផ្នែកមួយនៃ *ការប៉ាន់ប្រមាណបែបចូលរួមទៅលើភាពក្រីក្រ របស់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញបឹងទន្លេសាប* របស់ CDRI បានបង្ហាញឲ្យឃើញថា ឥទ្ធិពលរបស់ទេសន្តរប្រវេសន៍ទៅលើសុខុមាលភាពរបស់គ្រួសារ មានលក្ខណៈចម្រុះ។ លំហូរនៃការផ្ទេរសាច់ប្រាក់ពី ប្រភពដទៃទៀត ក្រៅពីការងារជាកម្មករកាត់ដេរ ត្រូវបានចាត់ទុកថា ពុំមានស្ថេរភាព និងមិនអាច ព្យាករណ៍ទុកជាមុនបាន (Murshid, 2007)។ ការសិក្សារបស់ Chan ទូទាំងប្រទេសទៅលើការធ្វើ ទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារធ្វើ (២០០៩) បានទាញសេចក្តីសន្និដ្ឋានថា ប្រយោជន៍ដែល ទទួលបានពីការធ្វើទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារធ្វើ មានចំនួនច្រើនជាងការចំណាយ។ ការសិក្សារបស់គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ ដែលមានចំណងជើងថា *ផលប៉ះពាល់នៃឧស្សាហកម្មកាត់ដេរ ទៅលើជីវភាពរស់នៅក្នុងតំបន់ជនបទ* (២០០៥) បានបង្ហាញអំពីសារៈសំខាន់នៃការងាររោងចក្រកាត់ដេរ នៅក្នុងជីវិតរស់នៅរបស់គ្រួសារដែលប្រកបរបរធ្វើស្រែនៅក្នុងខេត្តព្រៃវែង។ យ៉ាងណាមិញ ប្រាក់ដែលបានផ្ញើជូនគ្រួសារ ជាទូទៅ តែងត្រូវបានចំណាយដើម្បីគាំទ្រចំពោះថ្លៃ ជីវភាពរស់នៅប្រចាំថ្ងៃ ជាជាងការចាប់ផ្តើមធ្វើមុខជំនួញខ្នាតតូច។ ដូច្នេះ ជីវភាពរស់នៅតំបន់ ជនបទ ទទួលបាននិរន្តរភាព ដោយសារឧស្សាហកម្មកាត់ដេរ បើទោះបីជាពុំមានការផ្លាស់ប្តូរ ក៏ដោយ។ ការសិក្សាស្រាវជ្រាវមួយ របស់ CDRI ដែលមានមូលដ្ឋានផ្អែកលើការអង្កេតសង្គម សេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៧ ដែលតំណាងឲ្យប្រទេសទាំងមូល បានរកឃើញថា ប្រាក់ដែលផ្ញើទៅ ឲ្យគ្រួសារ មានផលប៉ះពាល់ធំធេងទៅលើការកាត់បន្ថយភាពធ្ងន់ធ្ងរនៃភាពក្រីក្រជាងការកាត់ បន្ថយសមាមាត្រនៃជនក្រីក្រ (Tong, 2010)។ បើទោះបីជាការសិក្សាស្រាវជ្រាវទាំងនេះ ផ្តល់នូវទិដ្ឋភាពមួយចំនួន អំពីឥទ្ធិពលនៃការធ្វើទេសន្តរប្រវេសន៍ ទៅលើសុខុមាលភាពរបស់គ្រួសារ ក៏ដោយ ភាគច្រើនគេផ្តោតយកចិត្តទុកដាក់ទៅលើបញ្ហាសេដ្ឋកិច្ចតែប៉ុណ្ណោះ ដោយពុំមានការផ្តោតយកចិត្តទុកដាក់ជាក់លាក់ទៅលើឪពុកម្តាយដែលមានវ័យចំណាស់ឡើយ។

ការអង្កេត ឆ្នាំ២០០៤ របស់កម្ពុជាទៅលើមនុស្សចាស់ បានបង្ហាញអំពីធាតុសំខាន់ៗមួយចំនួននៃ ជីវិតគ្រួសារកម្ពុជា ទាក់ទងទៅនឹងបញ្ហាទេសន្តរប្រវេសន៍ (Knodel et al, 2005)។ ដូចគ្នាទៅនឹង ប្រទេសភាគច្រើននៅក្នុងពិភពលោកដែរ គ្រួសារនៅក្នុងប្រទេសកម្ពុជា មានប្រពៃណីផ្តល់ការ ទទួលខុសត្រូវបបមចំពោះមនុស្សចាស់។ ដូច្នេះគ្រួសារពុំមែនត្រឹមតែមានការទទួលខុសត្រូវក្នុងការផ្តល់កិច្ចគាំទ្រជាសម្ភារៈ សម្រាប់សមាជិកគ្រួសារដែលជាមនុស្សចាស់ប៉ុណ្ណោះទេ ប៉ុន្តែគ្រួសារក៏ ត្រូវផ្តល់ជំនួយមួយចំនួនដែលទាក់ទងទៅនឹងមុខងារសុខភាពផងដែរ រាប់បញ្ចូលការផ្តល់

ជំនួយ ចាំបាច់ ដែលពាក់ព័ន្ធទៅនឹងសកម្មភាពជីវិតរស់នៅប្រចាំថ្ងៃ។ កិច្ចគាំទ្របែបនេះ មានសារៈសំខាន់ជាពិសេស ចំពោះមនុស្សចាស់ដែលមានភាពទន់ខ្សោយ។ ដោយយោងទៅតាមភាពចាំបាច់ចំពោះ ការរស់នៅក្បែរគ្នា ដើម្បីចូលរួមនៅក្នុងការប្រាស្រ័យទាក់ទងពីជំនាន់មួយទៅជំនាន់មួយទៀត ជាពិសេសគឺ ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងសេចក្តីត្រូវការរូបវន្តប្រចាំថ្ងៃ ការរៀបចំការរស់នៅ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធគាំទ្រគ្រួសារ។ ការអង្កេតឆ្នាំ២០០៤ របស់កម្ពុជាទៅលើមនុស្សចាស់ បានបង្ហាញឲ្យឃើញថា ស្ទើរតែពាក់កណ្តាលនៃប្រជាជនដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ នៅក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់មានកូនម្នាក់រស់នៅក្រៅខេត្តរបស់ពួកគេ។ ស្របពេលជាមួយគ្នានេះ មនុស្សចាស់ក្នុងវ័យនេះច្រើនជាង៨០% ក៏មានកូនម្នាក់រស់នៅក្បែរពួកគេផងដែរ (Zimmer et al, 2008)។ ចំនុចនេះបង្ហាញឲ្យដឹង អំពីលទ្ធភាពក្នុងការដែលអាចមាន ការប្រាស្រ័យទាក់ទងស្មុគស្មាញមួយចំនួនក្នុងចំណោម និងរវាងកូន និងឪពុកម្តាយរបស់ពួកគេទាក់ទងទៅនឹងកិច្ចគាំទ្រប្រភេទផ្សេងៗគ្នា។ ក្នុងនោះរាប់បញ្ចូលកិច្ចគាំទ្រផ្នែកកាយសម្បទា ដែលតម្រូវឲ្យមានការរស់នៅក្បែរគ្នា និងកិច្ចគាំទ្រសម្ភារៈ (ដែលមិនចាំបាច់តម្រូវឲ្យរស់នៅក្បែរគ្នា)។ ការពិនិត្យមើលថាតើមាន ឬ គ្មានការធ្លាក់ចុះនៃកិច្ចគាំទ្រពាក់ព័ន្ធ គឺជាបញ្ហាមួយដ៏សំខាន់ ប៉ុន្តែមិនទាន់ត្រូវបានពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។

## សំនួរស្រាវជ្រាវ

សំនួរចម្បងៗដែលត្រូវបានដោះស្រាយនៅក្នុងការសិក្សាស្រាវជ្រាវនេះ រួមមានដូចជា ៖ តើការធ្វើ ទេសន្តរប្រវេសន៍របស់កូនដែលពេញវ័យ បង្កឲ្យមានផលប៉ះពាល់ទៅលើសុខុមាលភាពរបស់ឪពុក ម្តាយវ័យចំណាស់ នៅតំបន់ជនបទ ដែលពួកគេបន្សល់ទុកនៅទីជនបទដោយរបៀបណា និងតើ ការធ្វើទេសន្តរប្រវេសន៍នេះ បង្កឲ្យមានផលប៉ះពាល់ទៅលើការរួបរួមគ្នា រវាងមនុស្សពីជំនាន់មួយ ទៅជំនាន់មួយទៀត យ៉ាងដូចម្តេច? ជាក់លាក់ជាងនេះទៀត ការសិក្សាស្រាវជ្រាវមានបំណងពិនិត្យមើល ថាតើការធ្វើទេសន្តរប្រវេសន៍របស់កូនពេញវ័យ នាំឲ្យឈានទៅរកការបោះបង់ និងការមិនយកចិត្តទុកដាក់ចំពោះឪពុកម្តាយ ដែលមានវ័យចំណាស់ដែរឬទេ ថាតើប្រភេទនៃការប្រាស្រ័យទាក់ទង រវាងជំនាន់មួយទៅជំនាន់មួយទៀត មានភាពខុសប្លែកពីគ្នាដែរឬទេ អាស្រ័យទៅតាមទីកន្លែងរស់នៅរបស់កូន ថាតើជនទេសន្តរប្រវេសន៍ និងឪពុកម្តាយរបស់ពួកគេរក្សាទំនាក់ទំនងសង្គមដែរឬទេ ថាតើតុល្យភាពនៃការផ្លាស់ប្តូរសម្ភារៈទៅវិញទៅមក ក្នុងរយៈពេលនៃការរស់នៅបែកគ្នាផ្តល់ប្រយោជន៍ទៅខាងឪពុកម្តាយ ឬកូន និងថាតើការថែទាំកូនរបស់ជនទេសន្តរប្រវេសន៍ គឺជាបន្ទុករបស់ឪពុកម្តាយដែលមានវ័យចំណាស់ដែរឬទេ។

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាត្រូវបានធ្វើឡើងនៅក្នុងឃុំចំនួនពីរ នៃខេត្តបាត់ដំបង ក្នុងខែមិថុនា និង ខែកក្កដា ឆ្នាំ២០១០ ដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ។ ខេត្តបាត់ដំបង មានព្រំប្រទល់ភាគខាងលិច ជាប់នឹងប្រទេសថៃ និងខេត្តប៉ៃលិន និងជាខេត្តមួយដែលត្រូវបានគេដឹងថាបានផ្តល់ពលករជាច្រើនទៅប្រទេសថៃ និងខេត្តដទៃទៀត នៅក្នុងប្រទេសកម្ពុជា ជាពិសេសចាប់តាំងពីចុងទសវត្សឆ្នាំ១៩៩០។ ទិន្នន័យបរិមាណវិស័យទទួលបានពីការអង្កេតមានគោលបំណងច្បាស់លាស់មួយដែលបានធ្វើទៅលើអ្នកផ្តល់ការឆ្លើយតបចំនួន ២៦៥នាក់ ដែលមានអាយុចន្លោះពី ៦០ឆ្នាំ ទៅ ៧០ឆ្នាំ និងកូនរបស់ពួកគេចំនួន ១.២៦៨នាក់។ ព័ត៌មានដែលទទួលបានពីការអង្កេតនេះ ត្រូវបានបំពេញបន្ថែមដោយទិន្នន័យបែបគុណវិស័យ ដែលទទួលបានពីកិច្ចសម្ភាសន៍ចំនួន ៣០ ដោយការសួរសំនួរបើក ដើម្បីពិនិត្យតាមដានបន្តជាមួយសំណាករងនៃអ្នកផ្តល់ការឆ្លើយតបដែលមានវ័យចំណាស់។

ខេត្តនៃប្រទេសកម្ពុជា ត្រូវបានបែងចែករចនាសម្ព័ន្ធរដ្ឋបាលជាស្រុក ដែលនៅក្នុងស្រុកនីមួយៗ រួមមានឃុំជាច្រើន។ ខេត្តបាត់ដំបង មានស្រុកចំនួន ១៣ ហើយការសិក្សាស្រាវជ្រាវ បានធ្វើឡើង នៅឃុំចំនួនពីរ ក្នុងស្រុកចំនួនពីរ នៃចំនួនស្រុកសរុប។ ឃុំទី១ ដែលការសិក្សាស្រាវជ្រាវត្រូវបាន ធ្វើឡើងមានឈ្មោះថា ឃុំត្រែង ដែលជាឃុំមួយក្នុងចំណោមឃុំចំនួន៤ នៅក្នុងស្រុករតនៈមណ្ឌល។ ឃុំនេះ មានទីតាំងស្ថិតនៅភាគខាងលិចនៃខេត្ត និងស្ថិតនៅក្បែរ (ប៉ុន្តែ ពុំមែនស្ថិតនៅតាម បណ្តោយ) ព្រំដែនប្រទេសថៃ។ ផ្លូវជាតិលេខ ៦៧ ដែលជាផ្លូវដ៏ធំមួយដែលភ្ជាប់ទីរួមខេត្តបាត់ដំបង និងទីរួមខេត្តប៉ៃលិន ក៏ឆ្លងកាត់ឃុំនេះដែរ។ នៅពេលធ្វើជំរឿនឆ្នាំ២០០៨ ឃុំត្រែង មានប្រជាជន ចំនួន ១២.៨១០នាក់ និង ២.៥៣៨គ្រួសារ។ ឃុំទី២ ដែលការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងមាន ឈ្មោះថា ឃុំតាឡុស ដែលជាឃុំមួយក្នុងចំណោមឃុំទាំង១១ នៅក្នុងស្រុកមោងឬស្សី។ ឃុំនេះ មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃខេត្ត និងស្ថិតនៅក្បែរផ្លូវជាតិលេខ៥ ដែលជាផ្លូវដ៏ធំមួយ ដែលលាតសន្ធឹងពីភាគខាងជើងទៅភាគខាងត្បូង ដោយឆ្លងកាត់ខេត្តនេះ និងភ្ជាប់ទីរួមខេត្តបាត់ដំបង ទៅនឹងរាជធានីភ្នំពេញ។ ឃុំតាឡុស ក៏ស្ថិតនៅក្បែរខេត្តពោធិ៍សាត់ផងដែរ។ នៅពេលធ្វើជំរឿន ឆ្នាំ២០០៨ ឃុំនេះ មានគ្រួសារចំនួន ១.៧៦៥គ្រួសារ និងមានប្រជាជនរស់នៅចំនួន ៨.៥០៩នាក់ (រូបភាពទី១)។

ឃុំត្រូវបានបន្តបែងចែកជាភូមិ ដែលសំណាកត្រូវបានជ្រើសរើសពីភូមិទាំងនោះ។ ភូមិត្រូវបាន ជ្រើសរើសក្នុងគោលបំណងជាក់លាក់ ដោយផ្អែកលើការច្របាច់បញ្ចូលគ្នានូវកត្តាមួយចំនួនដូចជា លទ្ធភាពក្នុងការធ្វើដំណើរនៅក្នុងរដូវវស្សា នៅពេលដែលកិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងភាពងាយ ស្រួលក្នុងការប៉ាន់ប្រមាណទៅលើកម្រងសំណាក និង គំលាតភូមិសាស្ត្រមួយចំនួនរវាងភូមិ។ កម្រងសំណាកមានទម្រង់ជាការចុះបញ្ជីគ្រួសារ ដែលត្រូវបានរក្សាទុកនៅឯការិយាល័យ

នគរបាលឃុំ។ ការចុះបញ្ជីទាំងនេះ រួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងស្ថានភាពអាពាហ៍ពិពាហ៍របស់ សមាជិកគ្រប់រូប របស់គ្រួសារទាំងអស់ នៅក្នុងភូមិ។ ឃុំត្រែង មានភូមិចំនួន ៨ ដែលក្នុងចំណោមនោះ មានភូមិចំនួន៥ ត្រូវបានជ្រើសរើស ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។ ឃុំតាឡូស មានភូមិ ចំនួន៩ និងដូចគ្នាទៅនឹងឃុំត្រែងដែរ គឺភូមិចំនួន៥ ត្រូវបានជ្រើសរើស ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។ ភូមិចំនួន២បន្ថែមទៀត នៅក្នុងឃុំតាឡូស ត្រូវបានប្រើប្រាស់នៅក្នុងការសាកល្បង នៃការសិក្សាស្រាវជ្រាវ។

**រូបភាពទី១ ៖ ផែនទីនៃកន្លែងធ្វើការសិក្សាស្រាវជ្រាវ ក្នុងខេត្តបាត់ដំបង**




ការសិក្សាបច្ចុប្បន្ន បានជ្រើសរើសគ្រួសារដែលរួមមាន បុគ្គលដែលកើតនៅចន្លោះ ឆ្នាំ ១៩៤០ និង ឆ្នាំ១៩៥០ ពីឯកសារចុះបញ្ជីគ្រួសារ និង បានស្វែងរកធ្វើការសម្ភាសន៍សមាជិកម្នាក់ពីគ្រួសារ នីមួយៗដែលមានមនុស្សក្នុងវ័យនេះ។ បញ្ជីរាយនាមប្រជាជនដែលបានកើតនៅក្នុងចន្លោះពេលនេះ ត្រូវបានមេភូមិនីមួយៗធ្វើការផ្ទៀងផ្ទាត់ ហើយអ្នកដែលបានចាកចេញទៅរស់នៅកន្លែងផ្សេង ឬស្លាប់ ត្រូវបានលុបចេញពីបញ្ជី។ មេភូមិក៏បានបន្ថែមព័ត៌មានអំពីប្រជាជនមករស់នៅថ្មី ដែលពុំ មាននៅក្នុងបញ្ជីផងដែរ។ ក្នុងអំឡុងពេលនៃដំណើរការផ្ទៀងផ្ទាត់ជាមួយមេភូមិ ផែនទីចំណុចត្រូវបានរៀបចំ ដើម្បីកំណត់អត្តសញ្ញាណទៅលើគ្រួសារជាក់លាក់ ដែលអ្នកផ្តល់ការឆ្លើយតបរស់នៅ។ បន្ទាប់មក អ្នកធ្វើសម្ភាសន៍ធ្វើដំណើរទៅតាមភូមិនានា និង បែងចែកទៅតាមគ្រួសារដែលមាន លក្ខខ័ណ្ឌសមស្រប ដើម្បីធ្វើកិច្ចសម្ភាសន៍។ ក្នុងករណីមានអ្នកផ្តល់ការឆ្លើយតបដែលមានលក្ខខ័ណ្ឌ សមស្របលើសពីម្នាក់ ការជ្រើសរើសឥតព្រៀងទុកមួយត្រូវបានធ្វើឡើងដើម្បីសម្រេចទៅលើ អ្នកដែលត្រូវធ្វើសម្ភាសន៍។

ពុំមានការបដិសេធឡើយ អាស្រ័យដោយបុគ្គលគ្រប់រូបដែលត្រូវបានទាក់ទង សុទ្ធសឹងតែបានផ្តល់កិច្ចសម្ភាសន៍។ ប្រសិនបើអ្នកផ្តល់ការឆ្លើយតបមិនទំនេរ អ្នកធ្វើសម្ភាសន៍បានខិតខំទាក់ទង

ដើម្បីជួបជាមួយពួកគេនៅថ្ងៃដទៃទៀត ឬនៅពេលក្រោយ។ បើទោះជាដូច្នេះក្តី អ្នកផ្តល់ការឆ្លើយតបដែល មានល័ក្ខខ័ណ្ឌសមស្របមួយចំនួនមិនទំនេរឡើយ នៅពេលដែលអ្នកធ្វើសម្ភាសន៍បានចុះទៅជួប ពួកគេ ជាញឹកញាប់ ដោយសារតែពួកគេជាប់រវល់ធ្វើការងារនៅឯស្រែចម្ការ។ អត្រាឆ្លើយតបមានចំនួន ៨០%។ កិច្ចសម្ភាសន៍នៅក្នុងការអង្កេតនេះ ត្រូវបានបញ្ចប់រួចរាល់ក្នុងរយៈពេល ៥ថ្ងៃ នៅក្នុង ខែមិថុនា ឆ្នាំ២០១០។ អ្នកផ្តល់ការឆ្លើយតបទាំង ២៦៥នាក់ ដែលត្រូវបានសម្ភាសន៍ស្ទើរតែមាន ចំនួនស្មើគ្នារវាងឃុំទាំងពីរ ដែលត្រូវបានជ្រើសរើសយកមកធ្វើការសិក្សាស្រាវជ្រាវ ក្នុងនោះមាន អ្នកផ្តល់ការឆ្លើយតបចំនួន ១៣១នាក់ មកពីឃុំត្រែង និងអ្នកផ្តល់ការឆ្លើយតបចំនួន ១៣៤ មកពីឃុំ តាឡុស។

នៅក្នុងខែកក្កដា ឆ្នាំ២០១០ អ្នកស្រាវជ្រាវបានត្រឡប់មកឃុំត្រែង និងឃុំតាឡុសវិញ ដើម្បីធ្វើកិច្ចសម្ភាសន៍ដោយការសួរសំនួរបើក។ សរុបមក កិច្ចសម្ភាសន៍ត្រូវបានបញ្ចប់ដោយជោគជ័យ ជាមួយអនុកម្រងដែលមានអ្នកផ្តល់ការឆ្លើយតបចំនួន ៣០នាក់ និងមន្រ្តីឃុំ ចំនួន ២នាក់។ កិច្ចសម្ភាសន៍នីមួយៗមានរយៈពេលជាមធ្យមប្រមាណ ១ម៉ោង។ គោលបំណងនៃកិច្ចសម្ភាសន៍ ទាំងនេះ គឺដើម្បីអនុញ្ញាតឲ្យផ្តល់ការឆ្លើយតបធ្វើការពណ៌នា ដោយប្រើប្រាស់ពាក្យពេចន៍ផ្ទាល់ខ្លួនរបស់ពួកគេ អំពីទំនាក់ទំនងរបស់ពួកគេ ជាមួយកូនដែលធ្វើទេសន្តរប្រវេសន៍ និង កូនដែលមិនធ្វើទេសន្តរប្រវេសន៍។ ធម្មជាតិនៃកិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើកបែបនេះ ផ្តល់នូវព័ត៌មានបន្ថែមសំខាន់ៗមួយចំនួន ដល់ទិន្នន័យ ដែលទទួលបានតាមរយៈកម្រងសំនួរអង្កេត។ ដូច្នេះ ការវិភាគរួមទៅលើប្រភពទិន្នន័យទាំងពីរនេះ អនុញ្ញាតឲ្យមានអភិក្រមវិធីសាស្រ្តចម្រុះមួយ ដែលលើសពីអ្វីដែលគេអាចពឹងផ្អែកទៅលើទិន្នន័យបែបបរិមាណវិស័យតែម្យ៉ាង។ ពាក្យសម្តីផ្ទាល់មួយចំនួន ត្រូវបានដកស្រង់ពីការកត់ត្រាសម្តី និង បញ្ចូលទៅក្នុងការវិភាគ ដើម្បីសម្របសម្រួលដល់ការបកស្រាយគំហើញ បែបបរិមាណវិស័យជាក់លាក់មួយចំនួន។ ដោយឡែក កិច្ចសម្ភាសន៍បែបគុណវិស័យ បង្ហាញអំពីរបៀបដែលគំហើញជាក់លាក់ផ្សេងៗគ្នាដែលទទួលបានពីការអង្កេតមានលក្ខណៈស្របគ្នា ដើម្បីផ្តល់នូវរូបភាពជាក់ស្តែងមួយមានមូលដ្ឋានផ្អែកលើតថភាព ដែលជាទស្សនាទានរបស់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ។

## រចនាសម្ព័ន្ធនៃកម្រងសំនួរអង្កេត

កម្រងសំនួរអង្កេតដែលត្រូវបានប្រើប្រាស់ដើម្បីសម្ភាសន៍ឪពុកម្តាយ មិនត្រឹមតែមានសំនួរជាច្រើន អំពីអ្នកផ្តល់ការឆ្លើយតប និងសហព័ទ្ធ (ប្រសិនបើនៅរស់) របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែកម្រងសំនួរ ក៏អាចទទួលបានព័ត៌មានជាច្រើន អំពីកូនរបស់ពួកគេ ដែលកំពុងរស់នៅផងដែរ។ បណ្តុំសំនួរមួយ បានសួរសំនួរជាក់លាក់អំពីកូនដែលធ្លាប់ចាកចេញពីស្រុករបស់ឪពុកម្តាយពួកគេ និងមិនត្រឡប់មកវិញ ក្នុងរយៈពេលតិចបំផុតចំនួន១ឆ្នាំ ឬ កូនដែលបានធ្វើការចាកចេញច្រើនដង រយៈពេលខ្លី ដែលរយៈពេលសរុបនៃការចាកចេញរបស់ពួកគេ មានរយៈពេលតិចបំផុត ចំនួន១ឆ្នាំ។

ចំណុចនេះ គឺជាផ្នែកមួយនៃនិយមន័យបឋមរបស់យើង អំពីការធ្វើទេសន្តរប្រវេសន៍ ដែលបានកំណត់ថា កូន ដែលបន្តរស់នៅក្នុងស្រុកដើមរបស់ឪពុកម្តាយពួកគេ ក្រោយពេលដែលឪពុកម្តាយរបស់ពួកគេ បានធ្វើទេសន្តរប្រវេសន៍មកកាន់កន្លែងដែលត្រូវបានជ្រើសរើស ដើម្បីធ្វើការសិក្សាស្រាវជ្រាវមិនត្រូវបានចាត់ទុក ថាជាជនទេសន្តរប្រវេសន៍ឡើយ។ បណ្តុំសំនួរបន្ថែមទៀត បានសាកសួរអំពី "ជនទេសន្តរប្រវេសន៍ដែលបានត្រឡប់មកវិញ" ដូចជា ជនដែលមានល័ក្ខខ័ណ្ឌស្របទៅនឹង និយមន័យទេសន្តរប្រវេសន៍នេះ ប៉ុន្តែ បានវិលត្រឡប់មកវិញ និងកំពុងរស់នៅក្នុងស្រុករបស់ឪពុក ម្តាយពួកគេ។ បើទោះជាដូច្នេះក្តី បណ្តុំសំនួរលម្អិត មិនត្រូវបានយកមកធ្វើការសាកសួរអំពីកូនដែល ទើបតែចាកចេញពីស្រុក (ទៅហើយមកវិញជាបន្តបន្ទាប់ ឬ មិនទាន់ត្រឡប់មកវិញ) ប៉ុន្តែ មិនទាន់ បានរយៈពេល១ឆ្នាំនោះទេ។

បណ្តុំសំនួរមួយទៀត បានសាកសួរអំពីកូននីមួយៗរបស់អ្នកផ្តល់ការឆ្លើយតប រាប់បញ្ចូលកន្លែង រស់នៅបច្ចុប្បន្នរបស់ពួកគេ និង ការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ ក្នុងអំឡុងពេលកាល ពីឆ្នាំមុន ដោយមិនសំដៅចំពោះស្ថានភាព ឬ រយៈពេលនៃការធ្វើទេសន្តរប្រវេសន៍ឡើយ។ ដូច្នេះ ក្រុមកូន ដែលត្រូវបានយកមកធ្វើការប្រៀបធៀបជាមួយគ្នា មានភាពខុសប្លែកពីគ្នាមួយចំនួននៅក្នុង ការវិភាគខាងក្រោម អាស្រ័យទៅលើ តើបណ្តុំសំនួរណាមួយដែលផ្តល់ព័ត៌មានពាក់ព័ន្ធសម្រាប់ការ ប្រែប្រួលពាក់ព័ន្ធជាក់លាក់។ ការវិភាគមួយចំនួនប្រៀបធៀបកូន ដោយពឹងផ្អែកតែម្យ៉ាងទៅលើ កន្លែងរស់នៅបច្ចុប្បន្នរបស់ពួកគេប៉ុណ្ណោះ។ នៅក្នុងការវិភាគទាំងនេះ កូនមួយចំនួនតូចដែល រស់នៅក្រៅស្រុករបស់ឪពុកម្តាយពួកគេ ពុំមែនជាជនទេសន្តរប្រវេសន៍ទេ អាស្រ័យដោយ ជាក់ស្តែង ឪពុកម្តាយ គឺជាអ្នកដែលបានផ្លាស់ប្តូរទីលំនៅ ពុំមែនកូនឡើយ។ ការវិភាគដទៃទៀត បានធ្វើការប្រៀបធៀបកូនធ្វើទេសន្តរប្រវេសន៍ ដែលបានចាកចេញពីឪពុកម្តាយ យ៉ាងហោចណាស់រយៈពេល ១ឆ្នាំ (ទៅហើយមកវិញជាបន្តបន្ទាប់ ឬ មិនទាន់ត្រឡប់មកវិញ) ប៉ុន្តែ មិនរាប់បញ្ចូលកូនដែល ទើបតែបានចាកចេញពីស្រុករបស់ឪពុកម្តាយ មិនទាន់បានរយៈពេល ១ឆ្នាំឡើយ។

# លទ្ធផលស្រាវជ្រាវ

របកគំហើញពីការស្រាវជ្រាវ ត្រូវបានយកមកធ្វើការពិភាក្សាក្រោមប្រធានបទធំៗចំនួន៦៖ ការរៀបចំការ រស់នៅរបស់ឪពុកម្តាយ និងកូន ផលប៉ះពាល់នៃការធ្វើទេសន្តរប្រវេសន៍ទៅលើសុខុមាលភាព របស់ឪពុកម្តាយ ការជួយគ្នាជាសម្ភារៈនិងថវិកា ទំនាក់ទំនងសង្គមរវាងឪពុកម្តាយ និងកូន ការថែទាំសុខភាព និងសុខុមាលភាពផ្នែកចិត្តសាស្ត្ររបស់ចៅ និងឪពុកម្តាយ។

## ការរៀបចំការរស់នៅរបស់ឪពុកម្តាយ និងកូន

របកគំហើញនៃការសិក្សារបស់យើងបង្ហាញឲ្យដឹងថា ការធ្វើទេសន្តរប្រវេសន៍ (ពុំមែនជាការបោះបង់) គឺជាគោលដៅនៃការធ្វើអង្កេតទៅលើគ្រួសារដែលមានមនុស្សចាស់។ គ្រួសារជាច្រើនដែលមាន មនុស្សចាស់ បានរាយការណ៍ឲ្យដឹងថា មានកូនម្នាក់នៅក្នុងគ្រួសារធ្វើទេសន្តរប្រវេសន៍។ ប៉ុន្តែ បើទោះជាដូច្នេះក្តី គ្រួសារជាច្រើនក្នុងកម្រិតភាគរយកាន់តែខ្ពស់ជាងនេះទៀត បានថ្លែងឲ្យដឹងថា ពួកគេមានកូនម្នាក់រស់នៅឯផ្ទះ។ អ្នកផ្តល់ការឆ្លើយតបប្រមាណជិតពីរភាគបី មានកូនម្នាក់ដែល កំពុងធ្វើទេសន្តរប្រវេសន៍នាពេលបច្ចុប្បន្ន ដោយឡែក អ្នកផ្តល់ការឆ្លើយតបចំនួនបួនភាគប្រាំ មានកូនម្នាក់ដែលកំពុងរស់នៅជាមួយ។ ចំណុចនេះ បង្ហាញឲ្យដឹងថា ឪពុកម្តាយដែលមានវ័យចំណាស់ មិនត្រូវបានទុកចោលឲ្យរស់នៅតែម្នាក់ឯងឡើយ បើទោះបីជាអត្រានៃការធ្វើទេសន្តរប្រវេសន៍របស់កូនពួកគេ មានកម្រិតខ្ពស់ក៏ដោយ។ គេអាចពន្យល់បានថា កត្តានេះគឺបណ្តាលមកពីក្រុម ឪពុកម្តាយទាំងនេះមានកូនច្រើន។ ជាមធ្យម អ្នកផ្តល់ការឆ្លើយតបមានកូនចំនួន ៤,៨នាក់ដែលនៅរស់។ ល័ក្ខខ័ណ្ឌនេះ អនុញ្ញាតឲ្យកូនមួយចំនួនអាចធ្វើទេសន្តរប្រវេសន៍បាន និងកូនដទៃទៀត បន្តរស់នៅក្នុងផ្ទះ ឬ ភូមិរបស់ឪពុកម្តាយពួកគេ (រូបភាពទី២)។

**រូបភាពទី២ ៖ គ្រួសារមនុស្សចាស់ ដែលមានកូនធ្វើទេសន្តរប្រវេស្តន៍ និងមានកូនរស់នៅក្បែរ**




ការសិក្សា ក៏ប្រៀបធៀបផងដែរទៅលើការរៀបចំការរស់នៅ រវាងអ្នកផ្តល់ការឆ្លើយតប ដែលមាន កូនកំពុងធ្វើទេសន្តរប្រវេស្តន៍ និង អ្នកផ្តល់ការឆ្លើយតបដែលពុំមានកូនធ្វើទេសន្តរប្រវេស្តន៍។ ប្រសិនបើឪពុកម្តាយវ័យចំណាស់ដែលមានកូនម្នាក់កំពុងធ្វើទេសន្តរប្រវេស្តន៍ ត្រូវបានទុកចោល ឲ្យរស់នៅតែម្នាក់ឯង យើងរំពឹងថា ឪពុកម្តាយទាំងនោះភាគច្រើនរស់នៅដោយពុំមានកូននៅក្នុងគ្រួសារ។ ប៉ុន្តែនេះពុំមែនជាករណីដែលបានកើតឡើងឡើយ។ អ្នកផ្តល់ការឆ្លើយតបច្រើនជាង បីភាគបួន ដែលមានកូនម្នាក់កំពុងធ្វើទេសន្តរប្រវេស្តន៍នាពេលបច្ចុប្បន្ន ក៏កំពុងរស់នៅជាមួយកូន ម្នាក់ទៀតផងដែរ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ អ្នកផ្តល់ការឆ្លើយតបដែលមានកូនម្នាក់កំពុង ធ្វើទេសន្តរប្រវេស្តន៍ មិនទំនងថារស់នៅតែម្នាក់ឯងឡើយ បើធៀបទៅនឹងអ្នកផ្តល់ការឆ្លើយតប ដែលពុំមានកូនកំពុងធ្វើទេសន្តរប្រវេស្តន៍ បើទោះបីជាអ្នកដែលមានកូនកំពុងធ្វើទេសន្តរប្រវេស្តន៍ ទំនងនឹងរស់នៅតែជាមួយ សហព័ទ្ធ ឬ ចៅ (តែពុំមែនជាកូន) ក៏ដោយ បើធៀបទៅនឹងអ្នកដែល ពុំមានកូនកំពុងធ្វើទេសន្តរប្រវេស្តន៍។ យ៉ាងណាមិញ ភាពខុសគ្នានៅក្នុងគ្រប់ករណីទាំងអស់នេះ មានទំហំតិចតួចប៉ុណ្ណោះ (រូបភាពទី៣)។

រូបភាពទី៣ ៖ ការរៀបចំការរស់នៅរបស់អ្នកផ្តល់ការឆ្លើយតបដែលមានវ័យចំណាស់




* រួមបញ្ចូលទាំងអ្នកឆ្លើយតបរស់នៅតែជាមួយចៅ ជាមួយសហព័ទ្ធ និងចៅតែមិនមែនកូន និងជាមួយសាច់ញាតិដទៃទៀតក្នុងគ្រួសារនិងចៅ តែមិនមែនកូន។

## ស្ថានភាពទេសន្តរប្រវេសន៍របស់កូនៗ

ក្នុងចំណោមអ្នកផ្តល់ការឆ្លើយតបចំនួន ២៦៥នាក់ មាន ៦០% ជាស្ត្រី។ អ្នកផ្តល់ការឆ្លើយតបភាគច្រើន (៦០%) បានរៀបការរួច និងអ្នកដែលនៅសេសសល់ភាគច្រើន គឺជាស្ត្រីមេម៉ាយ (៣៥%)។ ជាទូទៅ ពុំមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់លើផ្នែកស្ថិតិ រវាងអ្នកផ្តល់ការឆ្លើយតបដែល មានវ័យចំណាស់ ដោយផ្អែកលើភេទ និងស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្នរបស់ពួកគេឡើយ បើសំដៅចំពោះស្ថានភាពទេសន្តរប្រវេសន៍នៃកូនរបស់ពួកគេ។ បើទោះជាដូច្នេះក្តី នៅក្នុងឃុំ តាឡុស ភាគរយនៃគ្រួសារដែលមានឪពុកម្តាយវ័យចំណាស់ ដែលមានកូនធ្លាប់ធ្វើទេសន្តរប្រវេសន៍ មានកម្រិតខ្ពស់ជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងគ្រួសារដែលមានឪពុកម្តាយវ័យចំណាស់ នៅក្នុងឃុំត្រែង (តារាងទី១)។

### តារាងទី១ ៖ ភាគរយនៃអ្នកផ្តល់ការឆ្លើយតបអំពីស្ថានភាពទេសន្តរប្រវេសន៍នៃកូនរបស់ពួកគេ ដោយបែងចែកទៅតាម ឃុំ ភេទ និងស្ថានភាពអាពាហ៍ពិពាហ៍

| ភាគរយនៃអ្នកផ្តល់ការឆ្លើយតបដែលមាន ៖ | សរុប | ឃុំ | | ភេទ | | ស្ថានភាព អាពាហ៍ពិពាហ៍ (ក) | |
|---|---|---|---|---|---|---|---|
| | | ត្រែង | តាឡុស | ប្រុស | ស្រី | នៅលីវ | រៀបការរួច |
| ចំនួនករណី | ២៦៥ | ១៣១ | ១៣៤ | ១០៦ | ១៥៩ | ១០៥ | ១៦០ |
| កូនដែលរស់នៅជាមួយ | ៨០.០ | ៨០.២ | ៧៩.៩ | ៨២.១ | ៧៨.៦ | ៧៨.១ | ៨១.៣ |
| កូនដែលរស់នៅក្នុងភូមិជាមួយគ្នា (ខ) | ៩១.៣ | ៩២.៤ | ៩០.៣ | ៩៥.៣ | ៨៨.៧ | ៨៧.៦ | ៩៣.៨ |
| កូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ | ៦៧.៩ | ៥៨.៨ | ៧៦.៩** | ៦៧.៩ | ៦៧.៩ | ៦២.៩ | ៧១.៣ |
| កូនធ្វើទេសន្តរប្រវេសន៍ដែលបានត្រឡប់មកវិញ | ១៥.៨ | ១២.២ | ១៩.៤ | ១៣.២ | ១៧.៦ | ១៥.២ | ១៦.៣ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍ | ៦៤.៥ | ៥៨.០ | ៧០.៩* | ៦៦.០ | ៦៣.៥ | ៥៩.០ | ៦៨.១ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស | ៥៥.៨ | ៥២.៧ | ៥៩.០ | ៥៧.៥ | ៥៤.៧ | ៥១.៤ | ៥៨.៨ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍ទៅភ្នំពេញ | ១៤.៣ | ១២.២ | ១៥.៧ | ១៧.៩ | ១១.៣ | ១១.៤ | ១៦.៣ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍ទៅក្រៅប្រទេស | ២៣.៨ | ១៨.៣ | ២៩.១* | ២០.៨ | ២៥.៨ | ២១.០ | ២៥.៦ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍ទៅក្បែរព្រំដែនក្នុងប្រទេសថៃ | ៦.៤ | ១.៥ | ១១.២*** | ៣.៨ | ៨.២ | ៥.៧ | ៦.៩ |
| កូនដែលកំពុងធ្វើទេសន្តរប្រវេសន៍ទៅឆ្ងាយពីព្រំដែនក្នុងប្រទេសថៃ (គ) | ១៧.៧ | ១៦.៨ | ១៨.៧ | ១៧.០ | ១៨.២ | ១៥.២ | ១៩.៤ |

កម្រិតនៃភាពគួរឲ្យកត់សម្គាល់ ៖ *=.០៥; **=.០១; ***=.០០១

សំគាល់ ៖ តារាងនេះ រាប់បញ្ចូលកូនដែលបានចាកចេញពីស្រុករបស់ឪពុកម្តាយពួកគេនាពេលថ្មីៗនេះ ប៉ុន្តែពុំទាន់បានរយៈពេល ១ឆ្នាំនៅឡើយ។

(ក) រៀបការរួច រាប់បញ្ចូលទាំងអ្នកដែលបានរៀបការរួច ប៉ុន្តែមិនរស់នៅជាមួយសហព័ទ្ធ។

(ខ) រាប់បញ្ចូល អ្នកដែលមានកូនរស់នៅជាមួយ។

(គ) រាប់បញ្ចូល ជនទេសន្តរប្រវេសន៍នៅក្នុងប្រទេសដទៃទៀត ព្រមទាំងប្រទេសថៃ។

បើទោះបីជាភូមិសាស្ត្ររបស់ឃុំត្រែង នៅជិតព្រំដែនថៃ ជាងឃុំតាឡុសក៏ដោយ ប៉ុន្តែសមាមាត្រនៃ ឪពុកម្តាយវ័យចំណាស់ដែលមានកូនធ្វើទេសន្តរប្រវេសន៍នៅក្នុងឃុំតាឡុស មានចំនួនច្រើនជាង គួរឲ្យកត់សម្គាល់ បើសំដៅចំពោះការធ្វើទេសន្តរប្រវេសន៍ទៅក្បែរព្រំដែនក្នុងប្រទេសថៃ។ ភាពខុសគ្នានេះ អាចឆ្លុះបញ្ចាំងអំពីបណ្តាញសង្គម ដែលមានលក្ខណៈរឹងមាំ និងមានការអភិវឌ្ឍន៍ជាងមុន ដែលជម្រុញឲ្យមានការធ្វើទេសន្តរប្រវេសន៍បែបនេះ នៅក្នុងឃុំតាឡុសច្រើនជាងឃុំត្រែង ដែល គេអាចធ្វើការតាមដានបាន អំពីភាពខុសប្លែកគ្នានៃប្រវត្តិតាំងទីលំនៅរបស់ឃុំ

ទាំងពីរនេះ ការរៀបចំការរស់នៅ និងទីតាំងជាក់លាក់។ ឃុំត្រែង គឺជាឃុំដែលទើបមានប្រជាជនមកតាំងទីលំនៅ នាពេលថ្មីៗនេះ ដែលអ្នកផ្តល់ការឆ្លើយតបទើបតែបានមកតាំងទីលំនៅក្នុងឃុំនេះរយៈពេល ១៨ឆ្នាំ ប៉ុណ្ណោះ។ ផ្ទុយទៅវិញ ស្ទើរតែបួនភាគប្រាំនៃអ្នកផ្តល់ការឆ្លើយតបក្នុងឃុំតាឡុសបានរស់នៅក្នុង ឃុំតាឡុស ចាប់តាំងពីពេលដែលសម័យខ្មែរក្រហមត្រូវបានបញ្ចប់ កាលពី ៣០ឆ្នាំមុនមកម្ល៉េះ។ បន្ថែមពីនេះទៀត នៅក្នុងឃុំត្រែងប្រជាជនរស់នៅជាជួរ តាមបណ្តោយផ្លូវជាតិ ដូច្នេះ ការរស់នៅ របស់ពួកគេ មានភាពបែកខ្ញែកពីគ្នា ជាងការរស់នៅក្នុងឃុំតាឡុស។ ដើម្បីទាញប្រយោជន៍ពី ភូមិសាស្ត្រដែលស្ថិតនៅក្បែរព្រំដែនប្រទេសថៃ ប្រជាជនដែលរស់នៅក្នុងឃុំត្រែង ត្រូវឆ្លងកាត់ ខេត្តប៉ៃលិន ដែលមានព្រំប្រទល់ជាប់គ្នា ដែលខេត្តនេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហម ព្រមទាំងមានការប្រយុទ្ធគ្នារប៉េះរប៉ោះរហូតដល់ចុងទសវត្សឆ្នាំ១៩៩០។

## មូលហេតុដែលកូនត្រូវធ្វើទេសន្តរប្រវេសន៍

បើទោះបីជាកម្រងសំនួរអង្កេតមិនបានធ្វើការសាកសួរដោយផ្ទាល់ អំពីមូលហេតុឫសគល់នៃការធ្វើទេសន្តរប្រវេសន៍ក៏ដោយ ប៉ុន្តែមតិយោបល់ពាក់ព័ន្ធមួយចំនួនត្រូវបានផ្តល់ជូននៅក្នុងកិច្ចសម្ភាសន៍ ដោយការសួរសំនួរបើក។ ការសង្កេតរបស់មេឃុំតាឡុស បានទាញសេចក្តីសន្និដ្ឋានដោយសង្ខេប ទៅលើស្ថានភាពទូទៅមួយចំនួន ៖

> ទី១ ពួកគេធ្វើទេសន្តរប្រវេសន៍ ដោយសារតែពួកគេគ្មានដីសម្រាប់ធ្វើស្រែចម្ការ។ ទី២ មនុស្សមួយចំនួនធ្វើទេសន្តរប្រវេសន៍ទៅតំបន់ព្រំដែន ដើម្បីស្វែងរកការងារធ្វើ ក្រោយ ពេលដែលពួកគេធ្វើការងារស្រែចម្ការរួចរាល់។ ពួកគេមួយចំនួនក៏ប្រកបរបរអាជីវកម្មនៅឯ តំបន់ព្រំដែនផងដែរ។ គ្រួសារមួយចំនួនពុំមានដីសម្រាប់ធ្វើស្រែចម្ការ ដូច្នេះ ពួកគេត្រូវធ្វើ ទេសន្តរប្រវេសន៍ញឹកញាប់ជាងគ្រួសារដទៃទៀត។ គ្រួសារដទៃមានដីសម្រាប់ធ្វើស្រែចម្ការ ប៉ុន្តែ គេធ្វើទេសន្តរប្រវេសន៍នៅក្នុងរដូវដែលពួកគេទំនេរ... នៅក្នុងរដូវប្រមូលផលពោត ពួកគេធ្វើទេសន្តរប្រវេសន៍ទៅព្រំដែនដើម្បីកាច់ពោត។ មនុស្សមួយចំនួនក៏បានឆ្លងដែន ទៅប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើផងដែរ។ មនុស្សមួយចំនួនបញ្ជូនកូនរបស់ពួកគេ ឲ្យទៅធ្វើការងារនៅឯរោងចក្រកាត់ដេរ ក្នុងរាជធានីភ្នំពេញ។ មនុស្សមួយចំនួនធ្វើទេសន្តរ ប្រវេសន៍ទៅប្រទេសម៉ាឡេស៊ី។

អ្នកផ្តល់ការឆ្លើយតបមួយចំនួនយល់ឃើញ ចំពោះការធ្វើទេសន្តរប្រវេសន៍ ថាជាការឆ្លើយតបចំពោះ កង្វះការងារនៅក្នុងប្រទេសកម្ពុជា។ ឪពុកម្នាក់ អាយុ ៦១ឆ្នាំ រស់នៅក្នុងឃុំតាឡុស ដែលមានកូន ៤នាក់ ក្នុងចំណោមកូនចំនួន ៧នាក់ ដែលកំពុងធ្វើការងារនៅក្នុងប្រទេសថៃ បានឲ្យដឹងថា ៖

> ខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំទៅធ្វើការនៅប្រទេសដទៃទេ ប្រសិនបើមានការងារធ្វើនៅក្នុងប្រទេស របស់យើង។ ខ្ញុំចង់ឲ្យពួកគេប្រកបរបរចិញ្ចឹមជីវិតនៅទីនេះ... ប៉ុន្តែ ពុំមានការងារធ្វើទាល់តែ សោះ។

យើងត្រូវតែទៅកន្លែងដែលមានការងារធ្វើ។ បើមិនដូច្នេះទេ យើងមិនអាចធ្វើអ្វីបានឡើយ។ យើងមិនអាចនៅកន្លែងនេះដែលគ្មានការងារធ្វើនោះទេ។ យើងត្រូវទៅរក ការងារធ្វើដើម្បីចិញ្ចឹមជីវិតគ្រប់ពេល។ ប្រសិនបើយើងមិនទៅរកការងារធ្វើទេ យើងនឹងនៅ តែក្រជារៀងរហូត។

អ្នកផ្តល់ការឆ្លើយតបដទៃទៀត បានរៀបរាប់ឲ្យដឹងថា គ្រោះរាំងស្ងួតនាពេលថ្មីៗនេះ បានធ្វើឲ្យ ទិន្នផលស្រូវមានការធ្លាក់ចុះ និងបង្ខំឲ្យប្រជាជនខ្ចីបុល ដែលនាំឲ្យកូនរបស់ពួកគេត្រូវធ្វើទេសន្តរ ប្រវេសន៍។ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦១ឆ្នាំ រស់នៅក្នុងឃុំតាឡស ដែលពឹងផ្អែកទៅលើប្រាក់ដែល កូនប្រសាររបស់គាត់រកបាននៅក្នុងប្រទេសថៃ បានឲ្យដឹងថា ៖

> មនុស្សជាច្រើនបានចាកចេញពីភូមិ អាស្រ័យដោយពួកគេធ្វើស្រែមិនបានផល... អ្នកខ្លះ បានស្ទូងស្រូវរួចទៅហើយ ប៉ុន្តែ ដោយសារតែគ្មានភ្លៀង ដូច្នេះស្រូវក៏ស្កកអស់... អ្នកខ្លះ ខ្ចីប្រាក់គេដើម្បីធ្វើស្រែ ប៉ុន្តែ ពួកគេត្រូវធ្លាក់ខ្លួនជំពាក់បំណុល នៅពេលដែលគ្មានភ្លៀង និង មិនទទួលបានផលពីការធ្វើស្រែរបស់ពួកគេ... ប្រសិនបើពួកគេមិនចេញទៅរកការងារធ្វើ នៅខាងក្រៅទេនោះ ពួកគេនឹងមិនអាចមានលទ្ធភាពចិញ្ចឹមគ្រួសាររបស់ពួកគេបានឡើយ។

បើទោះជាដូច្នេះក្តី អ្នកផ្តល់ការឆ្លើយតបដទៃទៀត បានទទួលស្គាល់អំពីធម្មជាតិនៃការដាំដុះដំណាំ កសិផល ដែលមិនអាចព្យាករណ៍ទុកជាមុនបាន ប៉ុន្តែ ពួកគេនៅតែមិនយល់ស្របចំពោះការធ្វើទេសន្តរប្រវេសន៍។ បុរសម្នាក់អាយុ ៦១ឆ្នាំ រស់នៅក្នុងឃុំត្រែង ដែលកូនទាំង ៥នាក់របស់គាត់ រស់នៅជាមួយគាត់ឬរស់នៅក្នុងភូមិជាមួយគ្នា បានបង្ហាញអំពីទស្សនៈមួយដោយឡែក ៖

> ការលំបាក គឺត្រង់ថា ធ្វើស្រែមិនបានល្អ ហើយយើងមានមាត់ច្រើនដែលត្រូវចិញ្ចឹម... ឆ្នាំខ្លះ ធ្វើស្រែបានល្អ ឆ្នាំខ្លះទៀត ក៏មិនសូវល្អ... ប៉ុន្តែ យើងមិនចាំបាច់ត្រូវទៅកន្លែងដទៃទៀតទេ។ នៅពេលដែលយើងទៅឆ្ងាយដើម្បីរកប្រាក់ យើងអាចផ្ញើប្រាក់មកផ្ទះវិញបាន លុះត្រាណា តែផាត់ថ្លៃជីវភាព និង ការចំណាយផ្សេងៗរួចរាល់។ ប្រសិនបើយើងនៅផ្ទះជាមួយគ្នា វាប្រសើរជាង បើទោះបីជារកប្រាក់មិនសូវបានច្រើនក៏ដោយ។

## ការធ្វើទេសន្តរប្រវេសន៍ និងការរៀបចំការរស់នៅរបស់កូន

ស្របគ្នាទៅនឹងគំហើញដែលបានរកឃើញថា អត្រាទេសន្តរប្រវេសន៍ខ្ពស់ ពុំបានបន្សល់ទុកឲ្យ ឪពុកម្តាយដែលមានវ័យចំណាស់រស់នៅតែម្នាក់ឯង គឺជាគំហើញដែលបញ្ជាក់ឲ្យដឹងថា ពុំមែនកូន ទាំងអស់ដែលមានសម្បទាបរិបូរណ៍ សុទ្ធសឹងតែបានធ្វើទេសន្តរប្រវេសន៍ឡើយ។ អ្នកផ្តល់ការឆ្លើយតបនៅក្នុងឃុំទាំងពីរបញ្ចូលគ្នា មានកូនដែលនៅរស់ សរុបចំនួន ១.២៦៨នាក់។ ក្នុងចំណោមនេះ មានតែ ៣៣% ប៉ុណ្ណោះ ដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ ២១% កំពុងធ្វើទេសន្តរប្រវេសន៍នៅ ក្នុងប្រទេស និង ៨% កំពុងធ្វើទេសន្តរប្រវេសន៍ឆ្លងដែន។ ដូច្នេះ បើទោះបីជាកូនដែលមានកាយ សម្បទាបរិបូរណ៍ បានធ្វើទេសន្តរប្រវេសន៍ក៏ដោយ ក៏នៅមានកូនដែលមាន

កាយសម្បទាបរិបូរណ៍ ច្រើនជាងនេះដទៃទៀត ពុំបានធ្វើទេសន្តរប្រវេសន៍ឡើយ។ ក្នុងចំណោមកូនដែលធ្លាប់ធ្វើទេសន្តរ ប្រវេសន៍ ពុំមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ ទាក់ទងទៅនឹង ភេទ អាយុ ឬ ស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេឡើយ។ បើទោះជាដូច្នេះក្តី ជនទេសន្តរប្រវេសន៍ឆ្លងដែនបច្ចុប្បន្ន ទំនង ជាបុរសច្រើនជាងស្ត្រី (តារាងទី២)។

**តារាងទី២ ៖ ភាគរយនៃកូន ទាក់ទងទៅនឹងការរៀបចំការរស់នៅ និងស្ថានភាពទេសន្តរប្រវេសន៍ ដោយបែកចែកទៅតាម ភេទ អាយុ និងស្ថានភាពអាពាហ៍ពិពាហ៍**

| ភាគរយនៃកូនដែល ៖ | សរុប | ភេទ | | អាយុ | | ស្ថានភាព អាពាហ៍ពិពាហ៍ (ក) | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | <៣០ | ៣០+ | នៅលីវ | រៀបការរួច |
| ចំនួនករណី | ១២៦៨ | ៦២៧ | ៦៤០ | ៥៨៩ | ៦៧៩ | ៤៨៣ | ៧៨៥ |
| រស់នៅជាមួយឪពុកម្តាយ | ៣១.៧ | ២៩.៧ | ៣៣.៨ | ៤៩.២ | ១៦.៥*** | ៦៥.៦ | ១១.២*** |
| រស់នៅក្នុងភូមិតែមួយជាមួយឪពុកម្តាយ (ខ) | ៥៩.០ | ៥៦.០ | ៦២.០* | ៦៣.៥ | ៥៥.១*** | ៦៩.៨ | ៥២.២*** |
| ធ្លាប់ជាជនទេសន្តរប្រវេសន៍ | ៣២.៦ | ៣៣.០ | ៣២.២ | ៣២.៦ | ៣២.៧ | ៣១.៨ | ៣៣.៥ |
| ជនទេសន្តរប្រវេសន៍ដែលត្រឡប់មកវិញ | ៤.៤ | ៤.១ | ៤.៧ | ៤.៩ | ៤.០ | ៤.៣ | ៤.៧ |
| បច្ចុប្បន្នជាជនទេសន្តរប្រវេសន៍នៅក្នុងប្រទេស | ២០.៧ | ១៩.៨ | ២១.៤ | ២១.១ | ២០.៣ | ១៩.៩ | ២១.៥ |
| បច្ចុប្បន្នជាជនទេសន្តរប្រវេសន៍នៅក្រៅប្រទេស | ៧.៦ | ៩.១ | ៦.១* | ៦.៦ | ៨.៤ | ៧.៧ | ៧.៣ |

កម្រិតនៃភាពគួរឲ្យកត់សម្គាល់ ៖ *=.០៥; **=.០១; ***=.០០១

សំគាល់ ៖ ការសំដៅចំពោះជនទេសន្តរប្រវេសន៍នៅក្នុងតារាងនេះ រាប់បញ្ចូលជនដែលទើបបានចាកចេញមិនទាន់បានរយៈពេល ១ឆ្នាំ (ទៅហើយមកវិញជាបន្តបន្ទាប់ ឬ មិនទាន់ត្រឡប់មកវិញ)។

(ក) លើកលែង ២៩ករណីដែលមានអាយុក្រោម ១៥ឆ្នាំ និង ១១ករណីដែលជាព្រះសង្ឃ ឬមិនដឹងអំពីស្ថានភាពអាពាហ៍ពិពាហ៍។ រៀបការរួច រាប់បញ្ចូលអ្នកដែលរៀបការរួច ប៉ុន្តែមិនរស់នៅជាមួយសហព័ទ្ធ។

(ខ) រាប់បញ្ចូលកូនដែលរស់នៅជាមួយឪពុកម្តាយ។

ស្របពេលជាមួយគ្នានេះ កូនចំនួន ៣២% រស់នៅរួមគ្នាជាមួយឪពុកម្តាយរបស់ពួកគេ ខណៈពេលដែល ៥៩% រស់នៅក្នុងភូមិតែមួយ ជាមួយឪពុកម្តាយរបស់ពួកគេ។ អ្វីដែលហាក់ផ្ទុយទៅនឹងអ្នកផ្តល់ការឆ្លើយតប គឺមានភាពខុសគ្នាគួរឲ្យកត់សម្គាល់មួយចំនួន ចំពោះកូនរបស់អ្នកផ្តល់ការឆ្លើយតបទាក់ទងទៅនឹងការរៀបចំការរស់នៅជាមួយឪពុកម្តាយរបស់ពួកគេ ដោយផ្អែកលើភេទ អាយុ និងស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ។ កូនដែលមិនទាន់រៀបការ និងកូនដែលមានអាយុ តិចជាង ៣០ឆ្នាំ រស់នៅជាមួយឪពុកម្តាយ និងរស់នៅក្នុងភូមិជាមួយគ្នាជាមួយឪពុកម្តាយ

របស់ ពួកគេ ក្នុងកម្រិតភាគរយមួយដែលខ្ពស់ជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងកម្រិតភាគរយនៃ កូនដែលរៀបការរួច និងកូនដែលមានអាយុចាប់ពី ៣០ឆ្នាំ ឡើងទៅ។ ភាពខុសគ្នាទាំងនេះឆ្លុះបញ្ចាំងអំពី ដំណាក់កាលជីវិតរស់នៅរបស់កូន ដែលកូនដែលនៅក្មេង និងកូនដែលមិនទាន់រៀបការ ទំនងនឹងរស់នៅជាមួយ ឬក្បែរឪពុកម្តាយរបស់ពួកគេ។ លើសពីនេះទៀត ភាគរយនៃកូនស្រីដែលរស់នៅក្នុងភូមិតែមួយជាមួយឪពុកម្តាយរបស់ពួកគេ មានកម្រិតខ្ពស់ជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងកូនប្រុស។

## ហានិភ័យដែលទាក់ទងទៅនឹងការធ្វើទេសន្តរប្រវេសន៍

កិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើក បង្ហាញឲ្យដឹងថា ឪពុកម្តាយវ័យចំណាស់ដឹងច្បាស់អំពី ហានិភ័យ ដែលទាក់ទងទៅនឹងការធ្វើទេសន្តរប្រវេសន៍ និងសម្តែងការព្រួយបារម្ភអំពីសុខុមាលភាពរបស់កូនពួកគេ ដែលធ្វើទេសន្តរប្រវេសន៍។ ឪពុកម្តាយភាគច្រើនមានភាពស្ទាក់ស្ទើរក្នុងការ អនុញ្ញាតឲ្យកូនរបស់ពួកគេចាកចេញពីពួកគេ បើទោះបីជាមនុស្សជាច្រើនមើលឃើញថា ពុំមានជម្រើសអ្វីក្រៅពីនេះទៀតក៏ដោយ។ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦៨ឆ្នាំ រស់នៅក្នុងឃុំតាឡុស ដែល មានកូនធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស និងឆ្លងដែន បាននិយាយបង្ហាញអំពីអារម្មណ៍របស់ គាត់ថា ៖

> ខ្ញុំមិនដឹងអំពីអ្វីដែលអាចកើតឡើងចំពោះកូនរបស់ខ្ញុំ ដែលទៅធ្វើការងាររកប្រាក់ឆ្ងាយពីខ្ញុំ ឡើយ។ ប្រសិនបើពួកគេនៅទីនេះ និងអាចមានលទ្ធភាពរកប្រាក់សម្រាប់ទិញម្ហូបអាហារ បាន ពួកគេមិនចាំបាច់ទៅណានោះទេ។ ប៉ុន្តែ ពួកគេក្រ... ខ្ញុំក៏គ្មានអ្វីដែរ ដូច្នេះ កូនរបស់ខ្ញុំ មួយចំនួន បានចាកចេញទៅឆ្ងាយដើម្បីរកប្រាក់ចិញ្ចឹមជីវិតរបស់ពួកគេ ហើយខ្ញុំនៅទីនេះ ជាមួយកូនស្រីរបស់ខ្ញុំ។ បើខ្ញុំជាអ្នកមាន ខ្ញុំមិនឲ្យកូនរបស់ខ្ញុំទៅណាទេ។ ប៉ុន្តែ ខ្ញុំគឺជាអ្នកក្រ ហើយខ្ញុំក៏កាន់តែចាស់ដែរ... ប្រសិនបើខ្ញុំព្យាយាមរារាំងពួកគេ ខ្ញុំមិនអាចចិញ្ចឹមពួកគេ បានឡើយ។ ដូច្នេះ ខ្ញុំត្រូវតែអនុញ្ញាតឲ្យពួកគេទៅ... ខ្ញុំត្រូវតែស៊ូទ្រាំនឹងការលំបាកជាមួយ កូនរបស់ខ្ញុំ។

ឪពុកម្តាយចាត់រាល់វិធានការគ្រប់យ៉ាងដែលពួកគេអាចធ្វើទៅបាន ដើម្បីការពារកូនរបស់ពួកគេ ដែលធ្វើទេសន្តរប្រវេសន៍។ បុរសម្នាក់អាយុ ៦៨ឆ្នាំ រស់នៅក្នុងឃុំត្រែង បានបញ្ជាក់យ៉ាងច្បាស់ លាស់ថា គាត់អនុញ្ញាតឲ្យកូនស្រីរបស់គាត់ ទៅធ្វើការនៅក្នុងរោងចក្រកាត់ដេរក្នុងរាជធានីភ្នំពេញ ដោយសារតែនាងស្នាក់នៅជាមួយសាច់ញាតិប៉ុណ្ណោះ ៖

> កូនស្រីរបស់ខ្ញុំទូរស័ព្ទទៅសាច់ញាតិម្នាក់ ដែលរស់នៅក្នុងរាជធានីភ្នំពេញ។ សាច់ញាតិ ម្នាក់នោះបានរកការងារមួយឲ្យនាងធ្វើ នៅក្នុងរោងចក្រកាត់ដេរ នៅពេលដែលនាងទៅ ដល់ទីនោះ។ ខ្ញុំបានអនុញ្ញាតឲ្យនាងទៅ ព្រោះខ្ញុំមានសាច់ញាតិនៅទីនោះ។ បើមិនដូច្នោះ ទេ ខ្ញុំមិនអនុញ្ញាតឲ្យនាងទៅឡើយ... ខ្ញុំសប្បាយចិត្ត ព្រោះនាងអាចរកប្រាក់បាន។ ប្រសិន បើនាងនៅទីនេះ នាងមិនអាចរកអ្វីបានឡើយ ប៉ុន្តែ ប្រសិនបើនាងត្រូវរស់នៅខាងក្រៅ ខ្ញុំនឹងមិនអនុញ្ញាតឲ្យនាងទៅនោះទេ។

ឪពុកម្ដាយក៏បារម្ភផងដែរ កូនរបស់ពួកគេដែលធ្វើទេសន្តរប្រវេសន៍ អាចធ្លាក់ខ្លួនចូលទៅក្នុង ក្រុមហ៊ុនមិនល្អ។ ស្ត្រីម្នាក់ អាយុ ៦៩ឆ្នាំ រស់នៅក្នុងឃុំត្រែង បានរស់នៅបែកគ្នាពីស្វាមីរបស់គាត់ ជាយូរយារណាស់មកហើយ និង បច្ចុប្បន្ន គាត់កំពុងរស់នៅជាមួយកូនស្រីរបស់គាត់ដែលទើប ត្រឡប់មកពីប្រទេសថៃវិញ។ គាត់បាននិយាយអំពីការព្រួយបារម្ភរបស់គាត់ ចំពោះកូនប្រុសតែមួយ របស់គាត់ ដែលកំពុងធ្វើការងារនៅក្នុងខេត្តក្រចេះ ៖

> បើកូននៅជិត វាប្រសើរជាង។ បើកូនធ្វើខុសអី ខ្ញុំអាចជួយណែនាំវាបាន។ ប៉ុន្តែ ឥឡូវនេះ កូនខ្ញុំនៅឆ្ងាយ ខ្ញុំបារម្ភថា វាតាមគេ ហើយក្លាយជាមនុស្សមិនល្អ។

មេភូមិជីសាង ឃុំត្រែង អាយុ ៦០ឆ្នាំ ដែលមានកូនរស់នៅក្នុងខេត្តបាត់ដំបង បានសម្តែងអំពីអារម្មណ៍ខុសគ្នា ពីឪពុកម្តាយជាច្រើនដទៃទៀត ៖

> ប្រជាជននៅក្នុងភូមិនេះ មិនចង់ឲ្យកូនរបស់ពួកគេទៅណាឆ្ងាយទេ។ ដោយសារតែឪពុក ម្តាយក្រ ទើបកូនត្រូវចាកចេញទៅឆ្ងាយ... ស្ថានភាពបានបង្ខំពួកគេឲ្យអនុញ្ញាតឲ្យកូនរបស់ ពួកគេចាកចេញ។ កូនក៏មិនចង់ទៅឆ្ងាយពីឪពុកម្តាយរបស់ពួកគេដែរ។ ពួកគេចង់រស់នៅ ក្បែរឪពុកម្តាយរបស់ពួកគេ ប៉ុន្តែ ពួកគេត្រូវតែចេញទៅរកប្រាក់។ ចំពោះការដែលកូនស្រី ត្រូវចាកចេញពីឪពុកម្តាយរបស់ពួកគេ វាពុំមែនជារឿងធម្មតាឡើយ... ដោយសារតែឪពុក ម្តាយរបស់ពួកគេជួបប្រទះការលំបាកដូច្នេះហើយ ទើបពួកគេត្រូវធ្វើចំណាកស្រុក... ពួកគេ ត្រូវរកប្រាក់ដើម្បីជួយដោះបំណុលរបស់ឪពុកម្តាយពួកគេ។ ឪពុកម្តាយរបស់ពួកគេ មិនចង់ ឲ្យកូនស្រីរបស់ពួកគេទៅឡើយ ប៉ុន្តែ ពួកគេមិនអាចឃាត់ឃាំងបានឡើយ... នៅពេល ដែលឪពុកម្តាយបានសងបំណុលរបស់ពួកគេរួចរាល់ កូនរបស់ពួកគេនឹងត្រឡប់មកវិញ។

ឪពុកម្តាយ មានការបារម្ភជាពិសេសចំពោះកូនស្រីរបស់ពួកគេ ដែលធ្វើការងារនៅក្នុងប្រទេសដទៃទៀត។ ដោយមានការធានាពីក្រុមហ៊ុន ភ្នាក់ងារជ្រើសរើសបុគ្គលិក និងសំខាន់ជាងនេះទៀត គឺការដែលបានឃើញបទពិសោធន៍វិជ្ជមានរបស់ជនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ពីមុនកន្លងមក ជួយកាត់បន្ថយការព្រួយបារម្ភ ប៉ុន្តែ ពុំបានលុបបំបាត់នូវការព្រួយបារម្ភទាំងនេះឡើយ។ ឪពុកម្នាក់ អាយុ ៦១ឆ្នាំ រស់នៅក្នុងឃុំត្រែង បានពន្យល់អំពីមូលហេតុដែលគាត់ និងភរិយារបស់គាត់ បានអនុញ្ញាតឲ្យកូនស្រីរបស់គាត់ ដែលមានអាយុ ១៨ឆ្នាំ ទៅធ្វើការងារនៅក្នុងប្រទេសម៉ាឡេស៊ី ៖

> កូនស្រីរបស់ខ្ញុំកំពុងទទួលការបណ្តុះបណ្តាលនៅក្នុងរាជធានីភ្នំពេញ ដើម្បីទៅធ្វើការនៅ ប្រទេសម៉ាឡេស៊ី... នាងនឹងត្រូវទៅធ្វើការក្រៅប្រទេស តាមរយៈក្រុមហ៊ុនមួយ ហើយនាង នឹងអាចត្រឡប់មកវិញ ក្នុងរយៈពេល ២ឆ្នាំទៀត... នាងនឹងត្រូវបម្រើការងារបោសសំអាតផ្ទះ បោកគក់ថែទាំមនុស្សចាស់... ក្មួយស្រីរបស់ខ្ញុំ បានទៅប្រទេសម៉ាឡេស៊ី ហើយពួកគេ មួយចំនួនក៏បានត្រឡប់មកវិញហើយដែរ... ខ្ញុំអនុញ្ញាតឲ្យកូនស្រីរបស់ខ្ញុំទៅ ព្រោះខ្ញុំបាន ឃើញអ្នកដទៃទៀតដែលបានទៅប្រទេសម៉ាឡេស៊ី និងរកប្រាក់បានច្រើន... នាងបានទៅ ធ្វើការតាមរយៈក្រុមហ៊ុនមួយ

ដែលធានាថា ពុំមានរឿងអ្វីកើតឡើងចំពោះកូនស្រីរបស់ខ្ញុំ ឡើយ... ខ្ញុំ និងប្រពន្ធរបស់ខ្ញុំ បានយល់ព្រមអនុញ្ញាតឲ្យនាងទៅ ពីព្រោះក្មួយស្រីរបស់ខ្ញុំ ធ្លាប់បានទៅប្រទេសនេះ។

ជាទូទៅ ការធ្វើទេសន្តរប្រវេសន៍ទៅបរទេស តាមរយៈក្រុមហ៊ុន ត្រូវបានចាត់ទុកថាជាជម្រើស ដែលមានសុវត្ថិភាពជាង បើទោះបីជាក្រុមហ៊ុនទុច្ចរិតមួយចំនួន ត្រូវបានគេដឹងថា ជាក្រុមហ៊ុនដែល ទាញប្រយោជន៍ពីជនទេសន្តរប្រវេសន៍ក៏ដោយ[១]។ មេឃុំតាឡុស ទទួលស្គាល់អំពីសេចក្តីត្រូវការ ដែលត្រូវមានភាពប្រុងប្រយ័ត្ន ៖

ប្រជាជនទៅធ្វើការងារនៅក្នុងប្រទេសម៉ាឡេស៊ី តាមរយៈក្រុមហ៊ុន។ មកទល់នឹងពេលនេះ ក្នុងនាមជាសមាជិកអាជ្ញាធរមូលដ្ឋាន ខ្ញុំមានការប្រុងប្រយ័ត្នខ្លាំងណាស់ ព្រោះខ្ញុំបារម្ភ ការជួញដូរស្ត្រី និងកុមារ។ ខ្ញុំបានអញ្ជើញក្រុមហ៊ុនដែលនាំពលករចេញទៅក្រៅប្រទេស ឲ្យមកជួបជាមួយអាជ្ញាធរ។ បន្ទាប់មក ខ្ញុំបញ្ជូនពួកគេឲ្យទៅជួបជាមួយអភិបាលស្រុក ដែល ទទួលខុសត្រូវចំពោះកិច្ចការនាវី ដើម្បីឲ្យគាត់អាចសួរសំនួរ និងត្រួតពិនិត្យទៅលើឯកសារ ថាតើឯកសារទាំងនោះមានលក្ខណៈស្របច្បាប់ដែរឬទេ។

ប្រាកដណាស់ ការធ្វើទេសន្តរប្រវេសន៍ឆ្លងដែន មានការប្រឈមខ្ពស់ជាងការធ្វើទេសន្តរប្រវេសន៍ នៅក្នុងប្រទេស។ អ្នកផ្តល់ការឆ្លើយតបមួយចំនួនបានរៀបរាប់ អំពីស្ថានភាពដែលកូនរបស់ពួកគេ ធ្វើទេសន្តរប្រវេសន៍ដោយពុំមានឯកសារ ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ នៅក្នុងប្រទេសថៃ មុនពេលបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ។ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦២ឆ្នាំ រស់នៅក្នុងឃុំត្រែង បានរំលឹកឡើងវិញ អំពីបទពិសោធន៍របស់កូនស្រីគាត់ម្នាក់ ដែលបានធ្វើទេសន្តរប្រវេសន៍ទៅ ប្រទេសថៃ ៖

កូនស្រីរបស់ខ្ញុំ ក៏បានទៅប្រទេសថៃដែរ ប៉ុន្តែ នាងត្រូវបានគេចាប់ខ្លួន និងដាក់ពន្ធនាគារ។ នាងលែងត្រឡប់ទៅវិញទៀតហើយ... ពេលនោះ នាងទៅធ្វើការងារនៅឯការដ្ឋានសំណង់ មួយ។ ថៅកែថៃ មិនបានបើកប្រាក់ឲ្យនាង ហើយនៅពេលដែលនាងទៅនិយាយជាមួយ ថៅកែ ថៅកែម្នាក់នោះ បានប្រាប់នគរបាល ហើយគេក៏ចាប់នាង... ក្រោយមក នាងក៏ត្រូវ បញ្ជូនមកប្រទេសកម្ពុជាវិញ។

ស្ត្រីចំណាស់ពីរនាក់ ដែលរស់នៅក្នុងឃុំត្រែង បានរៀបរាប់អំពីរឿងរ៉ាវដ៏គួរឲ្យរន្ធត់បំផុត។ ស្ត្រី នីមួយៗបាននិយាយអំពីកូនប្រុសរបស់ពួកគេ ដែលបានធ្វើទេសន្តរប្រវេសន៍ ទៅធ្វើការងារ

---

[១] សូមមើលរបាយការណ៍របស់មូលនិធិអាស៊ី (Holliday, 2011) និងរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (២០១១)។ នៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១១ នាយករដ្ឋមន្ត្រី ហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា បានចេញបញ្ជាឲ្យភ្នាក់ងារជ្រើសរើសបុគ្គលិកឈប់ធ្វើការបញ្ជូនជាបណ្តោះអាសន្ននូវពលករបម្រើការងារតាមផ្ទះ ទៅប្រទេសម៉ាឡេស៊ី បន្ទាប់ពីបានទទួលរបាយការណ៍ជាបន្តបន្ទាប់ អំពីករណីរំលោភបំពាន និង សកម្មភាពខុសច្បាប់។ សូមមើលអត្ថបទដែលមានចំណងជើងថា “Gov’t Suspends Sending Maids to Malaysia,” របស់សារព័ត៌មាន *The Cambodia Daily* ចុះថ្ងៃទី ១៥-១៦ តុលា ២០១១។

តាម ទូកនេសាទនៅឯសមុទ្រ ក្នុងប្រទេសថៃ ប៉ុន្តែ ពួកគាត់ពុំបានដំណឹងពីកូនប្រុសរបស់ពួកគាត់វិញឡើយ។ ស្ត្រីម្នាក់ដែលរស់នៅក្នុងភូមិគីឡូ បាននិយាយអំពីរឿងរ៉ាវកូនប្រុសរបស់គាត់ ៖

> កូនច្បង... បានទៅខេត្តកោះកុង... តាំងពីពេលនោះមក ខ្ញុំមិនដែលឮដំណឹងអ្វីពីវាឡើយ... ខ្ញុំឮថា វាទៅធ្វើការងារនៅលើទូក... ខ្ញុំសង្ឃឹមថា វានៅមានជីវិតរស់ទៅចុះ។ ខ្ញុំខ្លាចតែ វាត្រូវ គេសម្លាប់ ហើយបោះចូលទៅក្នុងសមុទ្រទេ។

ស្ត្រីម្នាក់ទៀតដែលរស់នៅក្នុងភូមិជីសាងបានរៀបរាប់ពីដំណើររឿងរបស់កូនប្រុសគាត់ថា ៖

> កូនប្រុសរបស់ខ្ញុំ បានទៅប្រទេសថៃ អស់រយៈពេល ៦ឆ្នាំ ប៉ុន្តែ ខ្ញុំមិនដែលទទួលបាន ដំណឹងពីវាសោះ។ វាមិនដែលបានផ្ញើប្រាក់ ឬ ដំណឹងអ្វីទេ។ ខ្ញុំមិនដឹងថា កូនរបស់ខ្ញុំនៅរស់ ឬក៏ស្លាប់ទេ... វាស្រាប់តែទៅប្រទេសថៃភ្លាមៗ ហើយមិនបានប្រាប់ខ្ញុំ... ឥឡូវនេះ អ្នកដែល ទៅជាមួយវាបានត្រឡប់មកវិញអស់ហើយ... ខ្ញុំបានសួរមិត្តភក្តិរបស់វា ហើយពួកគេបាន និយាយថា ពួកគេក៏មិនបានទទួលដំណឹងរបស់វា ចាប់តាំងពីពេលនោះដែរ។ ពួកគេគ្រាន់ តែដឹងថា វាធ្វើការនៅលើទូក... ខ្ញុំគ្មានសង្ឃឹមចំពោះកូនខ្ញុំទៀតទេ។

## ផលប៉ះពាល់នៃទេសន្តរប្រវេសន៍ទៅលើសុខុមាលភាពរបស់ឳពុកម្តាយ

គេតែងនិយាយថា ការធ្វើទេសន្តរប្រវេសន៍របស់កូនដែលពេញវ័យ ពីតំបន់ជនបទ ធ្វើឲ្យធ្លាក់ចុះនូវ សុខុមាលភាពរបស់ឳពុកម្តាយ ដែលមានវ័យចំណាស់។ គំហើញរបស់យើង មិនគាំទ្រដល់ការសង្កេតនេះឡើយ។ ជាទូទៅ ស្ថានភាពរបស់ឳពុកម្តាយដែលមានវ័យចំណាស់ ដែលមាន ឬ គ្មានកូនធ្វើទេសន្តរប្រវេសន៍ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ជាក់ស្តែង មធ្យមភាគពិន្ទុសុខភាព របស់ពួកគេ ពិន្ទុសមត្ថភាពកាយសម្បទា ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ ពិន្ទុសុខុមាលភាពផ្លូវចិត្ត និងភាគរយចំពោះដែនកំណត់នៃសកម្មភាពរស់នៅប្រចាំថ្ងៃ ស្ទើរតែមានកម្រិតដូចគ្នា។ ស្របពេល ជាមួយគ្នានេះ អ្នកផ្តល់ការឆ្លើយតបដែលមានកូនកំពុងធ្វើទេសន្តរប្រវេសន៍ នាពេលបច្ចុប្បន្ន បានរាយការណ៍ឲ្យដឹងអំពីអត្រានៃការគ្មានដីធ្លី ដែលមានកម្រិតខ្ពស់ជាងអ្នកផ្តល់ការឆ្លើយតប ដែលពុំ មានកូនកំពុងធ្វើទេសន្តរប្រវេសន៍នាពេលបច្ចុប្បន្ន (តារាងទី៣)។ នេះពុំមែនជារឿងគួរភ្ញាក់ផ្អើល អាស្រ័យដោយគ្រួសារដែលពុំមានដីធ្លី មានសម្ពាធខ្លាំងជាង ដែលតម្រូវឲ្យកូនធ្វើទេសន្តរប្រវេសន៍ រកការងារធ្វើ។

## តារាងទី៣ ៖ សូចនាករដែលត្រូវបានជ្រើសរើស ទាក់ទងទៅនឹងសុខុមាលភាពរបស់អ្នកផ្តល់ការឆ្លើយតប ដោយបែងចែកទៅតាមស្ថានភាពទេសន្តរប្រវេសន៍របស់កូន

| | ស្ថានភាពទេសន្តរប្រវេសន៍ | | |
|---|---|---|---|
| | មានកូនកំពុងធ្វើទេសន្តរប្រវេសន៍ | គ្មានកូនកំពុងធ្វើទេសន្តរប្រវេសន៍ | សរុប |
| ចំនួនករណី | ១៧១ | ៩៤ | ២៦៥ |
| ពិន្ទុសុខភាព[១] (មធ្យមភាគ) | ៤.៨ | ៤.៦ | ៤.៨ |
| ភាគរយនៃអ្នកដែលគ្មានដី | ៣៦ | ២១* | ៣១ |
| ពិន្ទុសមត្ថភាពកាយសម្បទា[២] (មធ្យមភាគ) | ៤.៥ | ៤.៦ | ៤.៥ |
| ភាគរយចំពោះសកម្មភាពនៃដែនកំណត់ រស់នៅប្រចាំថ្ងៃ[៣] | ១០ | ៧ | ៩ |
| ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ[៤] (មធ្យមភាគ) | ៧.៤ | ៧.៥ | ៧.៤ |
| ពិន្ទុសុខុមាលភាពផ្លូវចិត្ត[៥] (មធ្យមភាគ) | ១១.១ | ១១.៤ | ១១.២ |

កម្រិតនៃភាពគួរឲ្យកត់សម្គាល់ ៖ *=.05 ផ្អែកលើ តេស្ត chi-square test និង T-test

១. ត្រូវបានវាស់វែងក្នុងលក្ខណៈជាពិន្ទុបូកសរុបបញ្ចូលគ្នានូវចំណុចចំនួន១៣ ក្នុងគ្រួសារ រួមទាំងលក្ខណៈសម្បត្តិចំនួន២ នៃកន្លែងរស់នៅ។

២. ពិន្ទុសមត្ថភាពកាយសម្បទា មានមូលដ្ឋានផ្អែកលើការយល់ឃើញរបស់អ្នកផ្តល់ការឆ្លើយតប ទៅលើវិធានការវាស់ស្ទង់ចំនួន៣ ដូចជា សមត្ថភាពក្នុងការដើរចម្ងាយ ២០០ម៉ែត្រ សមត្ថភាពក្នុងការលើកកញ្ចប់អង្ករ៥គីឡូក្រាម និងសមត្ថភាពក្នុងការថែទាំផ្ទះ ដោយពុំមានជំនួយពីអ្នកដទៃ។ ពិន្ទុសមត្ថភាពកាយសម្បទាខ្ពស់បំផុត គឺ៦ និងទាបបំផុត គឺ ០។

៣. ដែនកំណត់នៃសកម្មភាពរស់នៅប្រចាំថ្ងៃ មានន័យថា អ្នកផ្តល់ការឆ្លើយតប ត្រូវការជំនួយក្នុងការថែទាំពួកគេ ដូចជា ងូតទឹក និងស្លៀកពាក់។

៤. ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ ផ្អែកលើការយល់ឃើញរបស់អ្នកផ្តល់ការឆ្លើយតប អំពីលក្ខណៈដែលគ្រួសារមានភាពចុះសម្រុងជាមួយគ្នា និង ពឹងផ្អែកគ្នាទៅវិញទៅក និងកម្រិតនៃដំណើរការជីវិតរស់នៅរបស់កូនៗ។ ពិន្ទុខ្ពស់បំផុតនៃការពេញចិត្តចំពោះគ្រួសារ គឺ៩ និងទាបបំផុត គឺ៣។

៥. ពិន្ទុសុខុមាលភាពផ្លូវចិត្ត ផ្អែកលើការយល់ឃើញរបស់អ្នកផ្តល់ការឆ្លើយតប ទៅលើវិធានការវាស់ស្ទង់ចំនួន៦។ ពិន្ទុខ្ពស់បំផុតនៃសុខុមាលភាពផ្លូវចិត្ត គឺ១៨ និងទាបបំផុតគឺ ៦។

អាស្រ័យដោយ ឪពុកម្តាយវ័យចំណាស់ភាគច្រើន មានកូនម្នាក់រស់នៅជាមួយ ជាទូទៅការដែល កូនដទៃទៀតរបស់ពួកគេធ្វើទេសន្តរប្រវេសន៍ មិនបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានទៅលើពួកគេឡើយ។ ប៉ុន្តែ តើនេះគឺជាការពិតចំពោះមនុស្សចាស់ដែរឬទេ ក្នុងករណីដែលកូនដែលនៅជិតបំផុត មិនរស់នៅជាមួយពួកគេ ឬមិនរស់នៅក្នុងភូមិជាមួយគ្នា? ការសិក្សារបស់យើងបានឆ្លើយតបទៅ នឹងសំនួរនេះ តាមរយៈការត្រួតពិនិត្យទៅលើលក្ខណៈសម្បត្តិរបស់អ្នកផ្តល់ការឆ្លើយតប ដោយ យោងទៅតាមទីតាំងនៃកន្លែងរស់នៅរបស់កូនពួកគេដែលនៅជិតបំផុត។

អ្នកផ្តល់ការឆ្លើយតប ដែលមានកូនម្នាក់រស់នៅជាមួយ មានមធ្យមភាគពិន្ទុទ្រព្យសម្បត្តិ ពិន្ទុនៃការពេញចិត្តចំពោះសេដ្ឋកិច្ច ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ និងពិន្ទុសុខុមាលភាពផ្លូវចិត្តខ្ពស់ជាង គួរឲ្យកត់សម្គាល់ បើធៀបទៅនឹងអ្នកផ្តល់ការឆ្លើយតប ដែលកូនដែលនៅជិតបំផុតរស់នៅក្នុងភូមិ តែមួយជាមួយគ្នា ឬ មិននៅក្នុងភូមិជាមួយគ្នា។ លើសពីនេះទៀត អ្នកផ្តល់ការឆ្លើយតប ដែលមាន កូនម្នាក់រស់នៅជាមួយ មានអត្រាទាបជាងគួរឲ្យកត់សម្គាល់ចំពោះការគ្មានដីធ្លី បើធៀបទៅនឹង អ្នកផ្តល់ការឆ្លើយតប ដែលកូនដែលនៅជិតបំផុត រស់នៅក្នុងភូមិតែមួយជាមួយគ្នា ឬ មិននៅក្នុង ភូមិជាមួយគ្នា (តារាងទី៤)។

**តារាងទី៤ ៖ សូចនាករដែលត្រូវបានជ្រើសរើស ទាក់ទងទៅនឹងសុខុមាលភាពរបស់អ្នកផ្តល់ការឆ្លើយតប ដោយបែងចែកទៅតាមទីតាំងកន្លែងរស់នៅរបស់កូន ដែលនៅជិតបំផុត**

| | **ទីតាំងកន្លែងរស់នៅរបស់កូនដែលនៅជិតបំផុត** | | |
|---|---|---|---|
| | **នៅក្នុងផ្ទះ** | **នៅក្នុងភូមិ** | **នៅក្រៅភូមិ** |
| ចំនួនករណី | **២១២** | **៣០** | **២៣** |
| ពិន្ទុទ្រព្យសម្បត្តិ (មធ្យមភាគ) | ៥.១ | ៣.៣ | ៣.៣*** |
| ភាគរយនៃអ្នកដែលគ្មានដី | ២៥ | ៤០ | ៧៤*** |
| ពិន្ទុសមត្ថភាពកាយសម្បទា (មធ្យមភាគ) | ៤.៥ | ៤.៧ | ៤.៦ |
| ភាគរយចំពោះសកម្មភាពនៃដែនកំណត់រស់នៅប្រចាំថ្ងៃ | ៩ | ១៣ | ៤ |
| ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ (មធ្យមភាគ) | ៧.៦ | ៦.៦ | ៧.១*** |
| ពិន្ទុសុខុមាលភាពផ្លូវចិត្ត (មធ្យមភាគ) | ១១.៤ | ១០.១ | ១០.៨** |

កម្រិតនៃភាពគួរឲ្យកត់សម្គាល់ ៖ **=.0១; ***=.00១ផ្អែកលើតេស្ត chi-square និងតេស្ត ANOVA
សម្រាប់និយមន័យ សូមមើលតារាងទី៣។

សមាមាត្រនៃអ្នកផ្តល់ការឆ្លើយតបដែលកូនទាំងអស់មិនរស់នៅក្នុងភូមិ (និងដែលអាចចាត់ទុកថា ត្រូវបានបោះបង់ឲ្យរស់នៅតែម្នាក់ឯង) មានចំនួនតិចជាង ១០%។ បើទោះជាដូច្នេះក្តី ពួកគេជា ច្រើនពុំមានដី និងក្រីក្រ។ សូមកត់សម្គាល់ថា អ្នកផ្តល់ការឆ្លើយតបចំនួន ១៨នាក់ ក្នុងចំណោម ២៣នាក់ នៅក្នុងក្រុមនេះ គឺជាស្ត្រី និង ១៣នាក់ ក្នុងចំណោមស្ត្រីទាំងនេះ មិនទាន់រៀបការនៅ ឡើយ។

កិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើក បានឲ្យដឹងថា នៅក្នុងករណីមួយចំនួន សុខុមាលភាព របស់ឪពុកម្តាយគឺជាបញ្ហាមួយដ៏សំខាន់សម្រាប់ឪពុកម្តាយ និងកូនពេញវ័យ ដែលដូចគ្នាទៅនឹង ការសម្រេចចិត្តក្នុងការធ្វើទេសន្តរប្រវេសន៍ និងការត្រឡប់មកវិញផងដែរ។ បុរសម្នាក់ អាយុ ៦២ឆ្នាំ ដែលរស់នៅក្នុងឃុំត្រែង ពឹងផ្អែកទៅលើការឧបត្ថម្ភពីកូនស្រីច្បងរបស់

គាត់ ដែលធ្វើការងារនៅក្នុង រោងចក្រកាត់ដេរមួយ ក្នុងរាជធានីភ្នំពេញ។ ស្របពេលជាមួយគ្នានេះ គាត់បានបដិសេធ មិនព្រម អនុញ្ញាតឲ្យកូនស្រីបន្ទាប់របស់គាត់ ចាកចេញពីផ្ទះ ដើម្បីទៅធ្វើការងារជាមួយបងស្រីរបស់នាង ឡើយ ៖

> ខ្ញុំនឹងមិនអនុញ្ញាតឲ្យកូនស្រីបន្ទាប់របស់ខ្ញុំទៅទេ។ ខ្ញុំចង់ឲ្យនាងនៅផ្ទះដើម្បីជួយមើលម្តាយ របស់នាង។ មានតែកូនស្រីច្បងរបស់ខ្ញុំប៉ុណ្ណោះ ដែលខ្ញុំអនុញ្ញាតឲ្យទៅ។ ប្រសិនបើកូនស្រី បន្ទាប់របស់ខ្ញុំទៅធ្វើការងារជាមួយបងស្រីរបស់នាងដែរ ម្តាយរបស់នាងប្រាកដជាត្រូវនៅ ម្នាក់ឯង នៅពេលដែលខ្ញុំចេញទៅធ្វើការងារខាងក្រៅ។ ប្រពន្ធខ្ញុំមិនហ៊ាននៅផ្ទះតែម្នាក់ ឯងទេ។

ស្ត្រីម្នាក់ អាយុ ៦០ឆ្នាំ នៅក្នុងឃុំតាឡស ដែលបានលែងលះគ្នាជាមួយស្វាមីរបស់គាត់ មានកូនចំនួន ៥នាក់ ក្នុងនោះ ៤នាក់ បានត្រឡប់មកពីប្រទេសថៃវិញ និងកំពុងរស់នៅជាមួយគាត់។ យើង អាចមើលឃើញយ៉ាងច្បាស់ថា ការសម្រេចចិត្តរបស់កូនគាត់ ដើម្បីត្រឡប់មករស់នៅជាមួយគាត់វិញ ពិតជាធ្វើឲ្យគាត់សប្បាយចិត្តខ្លាំងណាស់ ៖

> កូនរបស់ខ្ញុំចង់ទៅប្រទេសថៃ ដើម្បីធ្វើការងារវេចខ្ចប់នំ។ កូនរបស់ខ្ញុំទាំងអស់ សុទ្ធតែចង់ទៅ ប៉ុន្តែពួកគេបារម្ភខ្លាចក្រែងខ្ញុំមានការឈឺថ្កាត់។ ដូច្នេះ ពួកគេមិនព្រមទៅនោះទេ។ ខ្ញុំបាន អនុញ្ញាតឲ្យពួកគេទៅ ប៉ុន្តែ ពួកគេនិយាយថា "ម៉ែ ពួកយើងមិនទៅទេ ព្រោះអី បើកូនទៅ អស់ ម៉ែ ប្រាកដជារស់នៅម្នាក់ឯងមិនខាន។ បើម៉ែមានរឿងអី ហើយទូរស័ព្ទហៅកូនមក វិញ ក៏កូនមិនអាចត្រឡប់មកវិញភ្លាមបានដែរ"។ ដូច្នេះ ពួកគេសម្រេចចិត្តនៅទីនេះ និងធ្វើ ការងារក្បែរៗនេះ។ យើងចេះរកផ្សេងៗរស់នៅបាន រហូតមកទល់នឹងសព្វថ្ងៃ។

ដូចគ្នាទៅនឹងការសម្រេចចិត្តមិនធ្វើទេសន្តរប្រវេសន៍ដែរ ការសម្រេចចិត្តត្រឡប់មកវិញ តែងគិតគូ អំពីសុខុមាលភាពរបស់ឪពុកម្តាយដែលមានវ័យចំណាស់។ ស្ត្រីចំណាស់ម្នាក់ អាយុ ៦១ឆ្នាំ ដែលរស់នៅតែម្នាក់ឯងជាមួយចៅស្រីរបស់គាត់ អាយុ ៩ឆ្នាំ ក្នុងឃុំត្រែង បានសូមឲ្យកូនស្រីរបស់គាត់ ដែលធ្វើការងារនៅក្នុងប្រទេសថៃ ត្រឡប់មកផ្ទះវិញ ដើម្បីរស់នៅជាមួយគាត់ និងកូនរបស់នាង ៖

> កូនស្រីរបស់ខ្ញុំ នៅប្រទេសថៃ មិនអាចផ្ញើប្រាក់មកផ្ទះបានទេ ព្រោះនាងក៏គ្មានប្រាក់ដែរ។ នាងអាចរកប្រាក់បានត្រឹមតែចិញ្ចឹមខ្លួនឯងប៉ុណ្ណោះ... ខ្ញុំបានហៅឲ្យនាងត្រឡប់មកវិញ ពីព្រោះយ៉ាងហោចណាស់ ក៏យើងអាចរស់នៅជាមួយគ្នាបានដែរ។ យើងចេះតែខំរកនេះ រកនោះទៅ។ បើទោះបីជាអត់ឃ្លានយ៉ាងណា យើងអាចនៅជាមួយគ្នាបាន... មនុស្សយើង មើលមិនឃើញទេ... យើងអាចឈឺថ្កាត់ថ្ងៃនេះ ឬថ្ងៃណាក៏មិនដឹង... តើបាននរណាមើលថែ យើង? បើមានកូននៅក្បែរ ទើបវាប្រសើរជាង។

កូនដែលមិនរស់នៅក្នុងស្រុកជាមួយឪពុកម្តាយចំណាស់របស់ពួកគេ អាចមកមើលថែឪពុកម្តាយ របស់ពួកគេជាបណ្តោះអាសន្ន នៅពេលដែលឪពុកម្តាយមានជម្ងឺ។ មេភូមិជីសាង ក្នុងឃុំ

ត្រែង ដែលមានអាយុ ៦០ឆ្នាំ មានអារម្មណ៍រំភើបយ៉ាងខ្លាំង នៅពេលដែលកូនច្បងរបស់គាត់ មកពីក្រុង បាត់ដំបង ដើម្បីមើលថែគាត់ នៅពេលដែលគាត់ឈឺ ៖

> នៅពេលដែលខ្ញុំឈឺ កូនច្បងរបស់ខ្ញុំចំនួន ៣នាក់ បានមកមើលខ្ញុំ... ខ្ញុំសម្រាកនៅឯ មណ្ឌលសុខភាពអស់រយៈពេល១សប្តាហ៍។ ពួកគេបារម្ភខ្លាចក្រែងខ្ញុំស្លាប់។ ពួកគេ បាន មកមើលខ្ញុំទាំងថ្ងៃទាំងយប់... ពួកគេបានចេញប្រាក់សម្រាប់អ្វីៗគ្រប់យ៉ាង ដូចជាថ្លៃពិនិត្យ ថ្លៃថ្នាំ និងថ្លៃចំណាយដទៃទៀត។ ខ្ញុំមិនចាំបាច់ត្រូវបារម្ភអ្វីឡើយ។ ខ្ញុំមានប្រាក់មួយចំនួន ដែរ ប៉ុន្តែ ពួកគេប្រាប់ខ្ញុំថា មិនចាំបាច់ត្រូវចេញប្រាក់អ្វីនោះទេ និងបានប្រាប់ឲ្យខ្ញុំ ទុកប្រាក់ ទាំងនេះ ដើម្បីទិញរបស់ហូប នៅពេលដែលខ្ញុំត្រឡប់ទៅផ្ទះវិញ...ខ្ញុំពិតជាសប្បាយចិត្ត ចំពោះពួកគេខ្លាំងណាស់ ព្រោះវាមានន័យថា ពួកគេយកចិត្តទុកដាក់ចំពោះឪពុករបស់ ពួកគេ។

ស្រដៀងគ្នានេះដែរ ឪពុកវ័យចំណាស់ម្នាក់ អាយុ ៦៩ឆ្នាំ ដែលរស់នៅក្នុងឃុំត្រែង បានកោត សរសើរថា កូនស្រីច្បងរបស់គាត់ បានសុំច្បាប់ពីការងាររបស់នាងជាបណ្តោះអាសន្នពីរោងចក្រ កាត់ដេរមួយ នៅក្នុងរាជធានីភ្នំពេញ ដើម្បីមើលថែគាត់ នៅពេលដែលគាត់ឈឺ បើទោះបីជាមានប្រពន្ធ និងកូនស្រីបន្ទាប់របស់គាត់រស់នៅឯផ្ទះក៏ដោយ ៖

> កូនស្រីរបស់ខ្ញុំ កំពុងធ្វើការងារ ក៏ស្រាប់តែមានគេទូរស័ព្ទហៅនាងឲ្យត្រឡប់មកផ្ទះវិញ។ នាងក៏ត្រឡប់មកវិញ ដើម្បីមើលថែខ្ញុំ... នៅពេលដែលខ្ញុំឈឺ នាងបានថែទាំខ្ញុំ។

ផ្ទុយទៅវិញ មានករណីមួយចំនួនផងដែរ ដែលឪពុកម្តាយវ័យចំណាស់ មានទំនាក់ទំនងបន្តិចបន្តួច ឬពុំមានទំនាក់ទំនងទាល់តែសោះជាមួយកូនរបស់ពួកគេ ដែលបានធ្វើទេសន្តរប្រវេសន៍។ សម្រាប់ មនុស្សចាស់ដែលពុំមានកូនដទៃទៀតរស់នៅក្បែរពួកគេ បញ្ហានេះ អាចមានផលវិបាកធ្ងន់ធ្ងរ។ ករណីស្ត្រីចំណាស់ម្នាក់ ក្នុងឃុំត្រែង ដែលរស់នៅតែម្នាក់ឯងជាមួយស្វាមីរបស់គាត់បានរៀបរាប់ អំពីស្ថានភាពបែបនេះ យ៉ាងក្រៀមក្រំ។ ស្ត្រីម្នាក់នេះ មានកូនប្រុសចំនួន ២នាក់ ដែលពួកគេទាំងពីរ សុទ្ធសឹងតែបានធ្វើទេសន្តរប្រវេសន៍។ កូនប្រុសរបស់គាត់ម្នាក់ បានទៅប្រទេសថៃ ៧ឆ្នាំហើយ និង កូនប្រុសម្នាក់ទៀត បានធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស កាលពីឆ្នាំមុន។ ចាប់តាំងពីពេលធ្វើ ទេសន្តរប្រវេសន៍ ពុំមានកូនណាម្នាក់បានទាក់ទងជាមួយម្តាយរបស់ពួកគេឡើយ។ ការដែលកូន របស់គាត់បានទុកឲ្យគាត់រស់នៅតែម្នាក់ឯងយ៉ាងដូច្នេះ ធ្វើឲ្យបន្ទុកនៅក្នុងគ្រួសារ ត្រូវធ្លាក់មកលើ រូបគាត់ ៖

> ខ្ញុំបារម្ភថា ខ្ញុំមិនអាចរកប្រាក់ដើម្បីចិញ្ចឹមជីវិតបាន ព្រោះខ្ញុំចាស់ហើយ។ នៅក្នុងតំបន់នេះ មិនសូវមានការងារធ្វើទេ។ ខ្ញុំក៏មិនអាចពឹងផ្អែកទៅលើការងារប្តីរបស់ខ្ញុំបានដែរ ពីព្រោះ ឥឡូវនេះ គាត់ក៏ចាស់ហើយដែរ។ គាត់ត្រឹមតែអាចមើលគោឲ្យគេប៉ុណ្ណោះ។ គាត់មិនអាច ទៅកាប់អុស ឬជីកត្រពាំងសម្រាប់លក់បានទេ... ខ្ញុំនៅតែផ្ទះទេ។ ជួនកាល ខ្ញុំអាចដាំស្ល បាន ប៉ុន្តែ ជួនកាល ខ្ញុំធ្វើមិនបានទេ...

ខ្ញុំពិបាកណាស់... នៅពេលដែលកូនខ្ញុំចាកចេញទៅ ខ្ញុំក៏ធ្លាក់ខ្លួនឈឺ... នៅពេលដែលពួកគេទៅបាត់ដោយគ្មានដំណឹង ជម្ងឺរបស់ខ្ញុំកាន់តែធ្ងន់ធ្ងរ ឡើង។ ខ្ញុំគិតពីកូនខ្លាំងពេក រហូតដល់ហូបអីលែងចូលទៅហើយ។

ការមានកូនច្រើន ផ្តល់នូវឱកាសមួយដល់ឪពុកម្តាយវ័យចំណាស់ ក្នុងការទទួលបានប្រយោជន៍ពី កូនដែលធ្វើទេសន្តរប្រវេសន៍ ព្រមទាំងទទួលបានជំនួយឧបត្ថម្ភពីកូនដែលរស់នៅក្បែរពួកគេផងដែរ។ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦២ឆ្នាំ ដែលរស់នៅក្នុឃុំតាឡុស មានកូនស្រីចំនួន ៣នាក់ ៖ កូនទី១ រស់នៅទីរួមខេត្តបន្ទាយមានជ័យ កូនទី២ រស់នៅក្បែរគាត់ក្នុងភូមិជាមួយគ្នា និងកូនទី៣ រស់នៅ ជាមួយគាត់ជាមួយស្វាមីរបស់នាង និងកូន ២នាក់។ នៅពេលដែលឈានមកដល់វ័យចំណាស់ ស្ត្រីម្នាក់នេះ និយាយអំពីគុណសម្បត្តិក្នុងការដែលមានកូនច្រើន ដោយក្នុងនោះ កូនមួយចំនួនអាចឧបត្ថម្ភដល់គាត់ ដោយការធ្វើទេសន្តរប្រវេសន៍ និងកូនដទៃទៀត អាចនៅក្បែរគាត់ដើម្បីជួយដល់ គាត់ ៖

វាជាការប្រសើរ ដែលកូនមួយចំនួនរស់នៅក្បែរខ្ញុំ និងកូនមួយចំនួនទៀត រស់នៅឆ្ងាយ... វាគឺជាការងាររបស់ពួកគេ។ ប្រសិនបើពួកគេរស់នៅក្បែរខ្ញុំ ពួកគេមិនអាចរកប្រាក់ដើម្បី ចិញ្ចឹមជីវិតបានឡើយ។ ពួកគេត្រូវចេញទៅឆ្ងាយ ដើម្បីរកប្រាក់ចិញ្ចឹមជីវិត។ កូនមួយចំនួន អាចទៅនៅកន្លែងឆ្ងាយ ហើយកូនខ្លះទៀត អាចនៅទីនេះ។ ពួកគេមិនចាំបាច់ត្រូវនៅទីនេះ ទាំងអស់គ្នានោះទេ។ កូនមួយចំនួនក៏ចេញទៅឆ្ងាយ ហើយកូនមួយចំនួនទៀត ក៏នៅ ជាមួយខ្ញុំ។ នៅពេលដែលខ្ញុំចាស់ ខ្ញុំចង់មានកូន ៥នាក់។ វាប្រាកដជាល្អណាស់ ព្រោះកូន មួយចំនួនអាចទៅភ្នំពេញ កូនមួយចំនួនទៀត អាចទៅបាត់ដំបង និងកូនដទៃទៀត អាចទៅ បន្ទាយមានជ័យ។ នៅពេលដែលយើងចាស់ហើយមានកូនតិចពេក វាពិបាកណាស់។ បើខ្ញុំ មានកូន ៤-៥នាក់ ពួកគេអាចជួយឧបត្ថម្ភខ្ញុំបាន។

បុរសម្នាក់ អាយុ ៦១ឆ្នាំ រស់នៅក្នុងឃុំតាឡុស ដែលមានកូនចំនួន ៧នាក់ ធ្វើការនៅក្នុងប្រទេសថៃ បានធ្វើការកោតសរសើរស្រដៀងគ្នា ចំពោះអត្ថប្រយោជន៍បន្ថែម ក្នុងការមានកូនដែលធ្វើទេសន្តរប្រវេសន៍ និងកូនដែលមិនធ្វើទេសន្តរប្រវេសន៍ ៖

កូននៅទីនេះ ផ្តល់អាហារឲ្យខ្ញុំជារៀងរាល់ថ្ងៃ ដោយឡែក កូននៅក្នុងប្រទេសថៃ ផ្ញើប្រាក់ ឲ្យខ្ញុំ១ខែម្តង។ កូននៅទីនេះ ពុំមានប្រាក់ទេ ប៉ុន្តែពួកគេ ផ្តល់អាហារឲ្យខ្ញុំ... នៅពេលដែល កូននៅក្នុងប្រទេសថៃ មានលទ្ធផលភាព ពួកគេបានផ្តល់ប្រាក់ឲ្យខ្ញុំ។

## កិច្ចគាំទ្រគ្នាជាសម្ភារៈ និងថវិកា

គេបាននិយាយថា ការធ្វើទេសន្តរប្រវេសន៍របស់កូនពេញវ័យ ចេញពីតំបន់ជនបទ បានទុកឲ្យឪពុកម្ដាយវ័យចំណាស់ធ្វើការងារស្រែចម្ការ ដោយគ្មាននរណាជួយ (Murshid, 2007)។ ការសង្កេតនេះ មានន័យថា កូនដែលបន្តរស់នៅជាមួយឪពុកម្ដាយរបស់ពួកគេ បានជួយរួមចំណែកផ្ដល់វិភាគទាន ច្រើនជាង ចំពោះឪពុកម្ដាយ។ ការសិក្សារបស់យើងបានធ្វើការពិនិត្យមើលទៅលើបញ្ហានេះ តាមរយៈការភ្ជាប់ទំនាក់ទំនងវិភាគទានរបស់កូនចំពោះឪពុកម្ដាយ ទាក់ទងទៅនឹងការផ្ដល់ជំនួយជាប្រចាំ ចំពោះការប្រកបរបរមុខជំនួញ ឬ ការងារស្រែចម្ការ រហូតដល់ការផ្ដល់វិភាគទានជាថវិកា។ របកគំហើញ បានបង្ហាញឲ្យដឹងថា ខណៈពេលដែលកូនដែលរស់នៅជាមួយ ឬរស់នៅក្បែរឪពុកម្ដាយរបស់ពួកគេ ផ្ដល់ជំនួយជាប្រចាំ ចំពោះការប្រកបរបរអាជីវកម្ម ឬការងារស្រែចម្ការ កូនដែលរស់នៅឆ្ងាយ បាន រួមចំណែកផ្ដល់វិភាគទានជាថវិកាច្រើនជាង។

មិនគួរឲ្យភ្ញាក់ផ្អើលនោះទេ កូនដែលរស់នៅជាមួយឪពុកម្ដាយ គឺជាអ្នកដែលទំនងនឹងជួយដល់ ឪពុកម្ដាយជាទៀងទាត់ ចំពោះការងារអាជីវកម្ម ឬការងារស្រែចម្ការរបស់ពួកគេ (៧១%)។ កូនដែល រស់នៅក្នុងភូមិជាមួយគ្នា ប៉ុន្តែ នៅផ្ទះផ្សេងគ្នា មិនទំនងថាអាចផ្ដល់ជំនួយយ៉ាងដូច្នេះបានឡើយ ប៉ុន្តែនៅតែមានល័ក្ខខ័ណ្ឌប្រសើរជាងកូនដែលរស់នៅឆ្ងាយជាងនេះ។ អាស្រ័យដោយឪពុកម្ដាយ ភាគច្រើន មានកូនម្នាក់រស់នៅក្នុងផ្ទះជាមួយ ភស្តុតាងនេះ ផ្ទុយទៅនឹងទស្សនៈដែលយល់ឃើញថា អត្រាកូនធ្វើទេសន្តរប្រវេសន៍ខ្ពស់ បន្សល់ទុកឲ្យឪពុកម្ដាយរស់នៅតែម្នាក់ឯងដោយគ្មាននរណាជួយ។ ស្របពេលជាមួយគ្នានេះដែរ កូនចំនួន ៤៣% ដែលកំពុងរស់នៅក្រៅប្រទេស បានរួមចំណែក ជួយឧបត្ថម្ភដល់ឪពុកម្ដាយរបស់ពួកគេច្រើនជាង ១០០.០០០ រៀល (២៥ដុល្លាសហរដ្ឋអាមេរិក) នៅក្នុងឆ្នាំកន្លងទៅ។ តាមរយៈការប្រៀបធៀប មានតែ ៧% ប៉ុណ្ណោះនៃកូនដែលរស់នៅក្នុងភូមិ ជាមួយគ្នា បានរួមចំណែកជួយឧបត្ថម្ភជាទឹកប្រាក់ដល់ឪពុកម្ដាយរបស់ពួកគេ ក្នុងកម្រិតនេះ (រូបភាពទី៤)[2]។

[២] ការរួមចំណែកជួយឧបត្ថម្ភជាថវិកាពីកូនដែលរស់នៅជាមួយឪពុកម្ដាយ មិនត្រូវបានយកមកធ្វើការពិចារណាឡើយ អាស្រ័យដោយមានការលំបាកនៅក្នុងការបកស្រាយ ដោយប្រហែលជាគ្រួសារជាច្រើនមានថវិការួម និង ថវិកាដែលទទួលបានពីកូនដែលរស់នៅជាមួយ អាចទំនងនឹងត្រូវបានប្រើប្រាស់សម្រាប់ចំណាយនៅក្នុងគ្រួសារ ដែលផ្ដល់ប្រយោជន៍ដោយផ្ទាល់ដល់កូនដែលបានរួមចំណែកជួយឧបត្ថម្ភថវិកា។

## រូបភាពទី៤ ៖ ការរួមចំណែករបស់កូន ដើម្បីឧបត្ថម្ភដល់ឪពុកម្តាយ ដោយបែងចែកទៅតាម ទីតាំងនៃកន្លែងរស់នៅរបស់កូន




សំគាល់ ៖ ការដែលចំនួនភាគរយមានកម្រិតខ្ពស់ ចំពោះកូនដែលរស់នៅក្នុងរាជធានីភ្នំពេញ និងក្រៅប្រទេស ដែលជួយដល់ការប្រកបអាជីវកម្ម ឬការងារស្រែចម្ការជាប្រចាំ នៅក្នុងឆ្នាំកន្លងទៅ គឺបណ្តាលមកពីការដែលពួកគេគឺជាជនដែលទើបធ្វើទេសន្តរប្រវេសន៍ មិនទាន់បានរយៈពេល ១ឆ្នាំ។

គំហើញទាំងនេះ បានឲ្យដឹងថា កូនរួមចំណែកជួយឧបត្ថម្ភគាំទ្រដល់ឪពុកម្តាយរបស់ពួកគេក្នុង លក្ខណៈផ្សេងៗគ្នា អាស្រ័យទៅតាមកន្លែងរស់នៅរបស់ពួកគេ។ កូនដែលបន្តរស់នៅជាមួយឪពុក ម្តាយរបស់ពួកគេ អាចមានលទ្ធភាពរួមចំណែកផ្តល់ជំនួយជាប្រចាំ ចំពោះការប្រកបរបរអាជីវកម្ម និងការងារស្រែចម្ការ ហើយវាជាការសំខាន់ខ្លាំងណាស់ ដែលគេមិនត្រូវមើលស្រាលចំពោះកិច្ចគាំទ្រនេះឡើយ។ ស្របពេលជាមួយគ្នានេះដែរ កូនដែលរស់នៅក្រៅស្រុក ក្នុងប្រទេសកម្ពុជា និងកូន ដែលរស់នៅក្រៅប្រទេស ខណៈពេលដែលពួកគេមិនអាចមានលទ្ធភាពផ្តល់ជំនួយជាប្រចាំ ចំពោះ ការប្រកបអាជីវកម្ម និងការងារស្រែចម្ការបាន ពួកគេរមែងតែងរួមចំណែកដ៏សំខាន់ចំពោះកិច្ចគាំទ្រ ជាថវិកា។

គួរកត់សម្គាល់ថា ចំនួនភាគរយនៃកូនមិនរស់នៅជាមួយឪពុកម្តាយ ដែលបានរួមចំណែកឧបត្ថម្ភ គាំទ្រជាថវិកាច្រើនជាង ៥០០.០០០ រៀល (១២៥ ដុល្លាសហរដ្ឋអាមេរិក) ជូនដល់ឪពុកម្តាយរបស់ ពួកគេ ក្នុងឆ្នាំកន្លងទៅ បានកើនឡើងគួរឲ្យកត់សម្គាល់ ចំពោះកូនដែលរស់នៅក្នុងរាជធានីភ្នំពេញ និងក្រៅប្រទេសកម្ពុជា។ ចំណុចនេះ បានឲ្យដឹងថា កន្លែងទាំងនោះផ្តល់នូវការងារដែលទទួលបាន ប្រាក់កម្រៃខ្ពស់ជាង សម្រាប់កូនដែលធ្វើទេសន្តរប្រវេសន៍។ ស្របពេលជាមួយគ្នា

នេះដែរ កូនភាគ ច្រើនដែលមិនរស់នៅជាមួយឪពុកម្តាយ មិនចំពោះថា ពួកគេរស់នៅកន្លែងណាឡើយ បានរួមចំណែក ឧបត្ថម្ភជាថវិកាច្រើនជាង ២០.០០០ រៀល (៥ដុល្លាសហរដ្ឋអាមេរិក) ជូនដល់ឪពុកម្តាយរបស់ ពួកគេ ក្នុងឆ្នាំកន្លងទៅ។ ការរួមចំណែកឧបត្ថម្ភបន្តិចបន្តួចទាំងនេះ មានគុណតម្លៃជានិមិត្តរូបមួយ ដ៏សំខាន់ ដែលភ្ជាប់ចំណងទំនាក់ទំនង រវាងកូន និងឪពុកម្តាយរបស់ពួកគេ ជាពិសេស ក្នុងអំឡុង ពេលចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ ព្រមទាំងការជូនប្រាក់មួយចំនួនតូចដល់ឪពុកម្តាយ ដើម្បី ទៅវត្ត (រូបភាពទី៥)។

**រូបភាពទី៥ ៖ កូនដែលបានផ្ញើប្រាក់ជូនឪពុកម្តាយ នៅក្នុងឆ្នាំកន្លងទៅ ដោយបែងចែកទៅតាមទីតាំងនៃកន្លែងរស់នៅរបស់កូន**




ការផ្លោះប្តូរកិច្ចគាំទ្រ និងការជួយគ្នាទៅវិញទៅមក រវាងឪពុកម្តាយ និងកូនដែលធ្វើទេសន្តរប្រវេសន៍ អាចមានលំហូរពីឪពុកម្តាយទៅកូន ឬពីកូនទៅឪពុកម្តាយ ឬពុំមានកិច្ចគាំទ្រ និងការជួយគ្នាទៅវិញ ទៅមកទាល់តែសោះ។ មិនមែនតែកូនដែលធ្វើទេសន្តរប្រវេសន៍ប៉ុណ្ណោះទេ ដែលរួមចំណែកឧបត្ថម្ភ ថវិកាជូនដល់ឪពុកម្តាយរបស់ពួកគេ ជាញឹកញាប់ ឪពុកម្តាយតែងផ្តល់កិច្ចគាំទ្រហិរញ្ញវត្ថុជូនដល់ កូនដែលធ្វើទេសន្តរប្រវេសន៍ផងដែរ ជាពិសេស ចំពោះថ្លៃចំណាយក្នុងដំណាក់កាលដំបូងនៃ ដំណើរការទេសន្តរប្រវេសន៍។ ក្នុងចំណោមកូនចំនួន ៣៤៤នាក់ ដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ យ៉ាងហោចណាស់រយៈពេល ១ឆ្នាំ មានកូនចំនួន ៤៨% បានទទួលជំនួយពីឪពុកម្តាយរបស់ពួកគេ ដើម្បីបង់ថ្លៃចំណាយសម្រាប់ការធ្វើទេសន្តរប្រវេសន៍។ ស្របពេលជាមួយគ្នានេះដែរ ៥៦% នៃកូន ដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ យ៉ាងហោចណាស់រយៈពេល ១ឆ្នាំ បាន

ផ្តល់កិច្ចគាំទ្រហិរញ្ញវត្ថុជា ប្រចាំជូនដល់ឪពុកម្តាយរបស់ពួកគេ។ ចំណុចនេះ បង្ហាញអំពីការព្រួយបារម្ភដ៏ខ្លាំងក្លារបស់ជន ទេសន្តរប្រវេសន៍ ចំពោះសុខុមាលភាពរបស់ឪពុកម្តាយពួកគេ។

សរុបមក ៥៥% នៃកូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍រយៈពេល ១ឆ្នាំ ឬច្រើនជាងនេះ បានរួមចំណែក គ្របដណ្តប់ទៅលើថ្លៃចំណាយព្យាបាលវេជ្ជសាស្ត្រ របស់ឪពុកម្តាយពួកគេ។ លើសពីនេះទៀត ៣២% នៃកូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ យ៉ាងហោចណាស់រយៈពេល ១ឆ្នាំ បានត្រឡប់មកវិញ ដើម្បីជួយដល់ឪពុកម្តាយរបស់ពួកគេ នៅពេលដែលឪពុកម្តាយមានជម្ងឺ។

គេបាននិយាយថា ក្នុងអំឡុងពេលទាំងមូល ដែលកូនធ្លាប់ធ្វើទេសន្តរប្រវេសន៍ បានឃ្លាតទៅយ៉ាង ហោចណាស់រយៈពេល ១ឆ្នាំ កូនបានជួយឧបត្ថម្ភជាសម្ភារៈដល់ឪពុកម្តាយរបស់ពួកគេ (អាហារ ថវិកា ទ្រព្យសម្បត្តិនានា) ក្នុងកម្រិតសមាមាត្រមួយខ្ពស់ជាង (៤២%) បើធៀបទៅនឹងការដែល ឪពុកម្តាយរបស់ពួកគេ បានរួមចំណែកជួយឧបត្ថម្ភគាំទ្រដល់ពួកគេ (៣៣%)។ គំហើញទាំងនេះ បង្ហាញយ៉ាងច្បាស់ថា មានការប្រែប្រួលសកម្មភាពគួរឲ្យកត់សម្គាល់ ទាក់ទងទៅនឹងអ្នកដែល ទទួលបានប្រយោជន៍ច្រើនជាង។ បើទោះជាដូច្នេះក្តី ចំណុចនេះបានគូសបញ្ជាក់អំពីការគ្របដណ្តប់ នៃលំហូរឧបត្ថម្ភជាវិជ្ជមានជូនដល់ឪពុកម្តាយ។ គួរកត់សម្គាល់ថា សមាមាត្រនៃកូនស្រីដែលបាន ធ្វើទេសន្តរប្រវេសន៍ ដែលរួមចំណែកចំពោះលំហូរវិជ្ជមាននេះ មានកម្រិតខ្ពស់ជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងកូនប្រុសដែលបានធ្វើទេសន្តរប្រវេសន៍ (រូបភាពទី៦)។

**រូបភាពទី៦ ៖ ទិសដៅនៃការរួមចំណែកផ្តល់ការឧបត្ថម្ភថវិកា រវាងកូនដែលធ្វើទេសន្តរប្រវេសន៍ និងឪពុកម្តាយ**




កម្រិតនៃភាពគួរឲ្យកត់សម្គាល់ ៖ **.0១ ផ្អែកលើតេស្ត chi-square

## កិច្ចគាំទ្រដែលទទួលបានពីកូន ដែលធ្វើទេសន្តរប្រវេសន៍

កិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើក បានឲ្យដឹងយ៉ាងច្បាស់ថា អ្នកផ្តល់ការឆ្លើយតបមួយ ចំនួនទទួលបានប្រយោជន៍គួរឲ្យកត់សម្គាល់ ពីថវិកាដែលកូនរបស់ពួកគេផ្ញើជូន។ បុរសពិការម្នាក់ អាយុ ៦៦ឆ្នាំ រស់នៅក្នុងឃុំត្រែង ដែលមានកូន ២នាក់ ធ្វើការងារនៅក្នុងប្រទេសថៃ បានសម្តែង អំពីភាពរីករាយ ចំពោះកិច្ចគាំទ្រថវិកាដែលគាត់ទទួលបានពីកូនប្រុសច្បងរបស់គាត់ ៖

> កូនប្រុសច្បងរបស់ខ្ញុំ បានរៀបការជាមួយនារីជនជាតិថៃម្នាក់... គាត់បានទុកទូរស័ព្ទដៃមួយ ដើម្បីឲ្យខ្ញុំទូរស័ព្ទទៅគាត់។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំជំពាក់បំណុលគេ ប្រហែលជា ៣លាន រៀល។ ខ្ញុំមានបំណងចង់លក់ដីស្រែ និងទៅរស់នៅខេត្តបាត់ដំបងជាមួយកូនស្រីរបស់ខ្ញុំ។ គាត់និយាយថា គាត់មិនឲ្យខ្ញុំលក់ដីស្រែឡើយ... ប្រមាណ ១១ខែក្រោយមក គាត់បានផ្ញើ ប្រាក់ឲ្យខ្ញុំ ដើម្បីសងបំណុលទាំងអស់... គាត់បាននិយាយថា ខ្ញុំចាស់ហើយ ហើយខ្ញុំមិន ចាំបាច់ត្រូវខ្ចីប្រាក់ពីអ្នកដទៃទៀតទេ... គាត់បានចាប់ផ្តើមផ្ញើប្រាក់ឲ្យខ្ញុំ ចំនួន ២.០០០ បាត ក្នុង១ខែ... ឥឡូវនេះ ខ្ញុំធូរធារជាងមុនបន្តិចហើយ ដោយសារតែខ្ញុំទទួលបានការជួយ ឧបត្ថម្ភពីកូនប្រុសរបស់ខ្ញុំ... គាត់បានប្រាប់ឲ្យខ្ញុំទូរស័ព្ទរកគាត់ភ្លាម នៅពេលដែលខ្ញុំគ្មាន បាយហូប... កូនប្រុសរបស់ខ្ញុំនិយាយថា គាត់នឹងសងគុណខ្ញុំវិញ ចំពោះការដែលខ្ញុំបាន ថែទាំគាត់ តាំងពីពេលដែលគាត់នៅតូច។

ស្រដៀងគ្នានេះដែរ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦១ឆ្នាំ ដែលរស់នៅក្នុងឃុំតាឡស ពឹងផ្អែកទៅលើការ ឧបត្ថម្ភពីកូនប្រសាររបស់គាត់ ដែលធ្វើការងារជាជាងផ្សាដែក នៅក្នុងទីក្រុងបាងកក។ ស្របពេល ជាមួយគ្នានេះដែរ កូនប្រុសម្នាក់ទៀត ដែលធ្វើការងារនៅក្នុងព្រំដែនប្រទេសថៃ បានខ្ចីលុយគាត់ សម្រាប់ថ្លៃធ្វើដំណើរ ៖

> ខ្ញុំរស់នៅទីនេះជាមួយកូនស្រីរបស់ខ្ញុំ។ កាលពីមុននាងរស់នៅក្បែរព្រំដែនថៃ ជាមួយម្តាយក្មេករបស់នាង។ នាងរស់នៅទីនោះរហូតដល់ពេលដែលនាងប្រសូតកូនរួច។ បន្ទាប់មក ខ្ញុំក៏យកនាងមករស់នៅក្នុងភូមិនេះ។ ប្តីរបស់នាងធ្វើការងារជាជាងផ្សាដែក នៅក្នុងទីក្រុង បាងកក។ ប្តីរបស់នាងផ្ញើប្រាក់ឲ្យនាងចំនួន ១.៥០០ បាត ក្នុង១ខែ... កូនស្រីម្នាក់នេះមាន ប្រាក់។ នាងឲ្យប្រាក់ខ្ញុំមួយចំនួនដើម្បីទិញឥវ៉ាន់បន្តិចបន្តួច សម្រាប់លក់គ្រាន់បាន ចំណេញខ្លះ... កូនស្រីដែលខ្ញុំរស់នៅជាមួយជួយខ្ញុំច្រើនណាស់។ កូនដទៃទៀត ឲ្យប្រាក់ ខ្ញុំតែនៅពេលបុណ្យភ្ជុំបិណ្ឌ និង ពេលបុណ្យចូលឆ្នាំខ្មែរប៉ុណ្ណោះ។ នោះគឺដោយសារតែ ពួកគេក៏ក្រីក្រផងដែរ។

បើទោះបីជាប្រាក់ដែលទទួលបានពីកូនដែលធ្វើទេសន្តរប្រវេសន៍ឆ្លងដែន អាចមានសារៈសំខាន់ ខ្លាំងចំពោះឪពុកម្តាយវ័យចំណាស់ក៏ដោយ ប៉ុន្តែ ប្រាក់ដែលកូនធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស បានផ្ញើជូន ក៏មានសារៈសំខាន់ផងដែរ។ បុរសម្នាក់ អាយុ ៦៤ឆ្នាំ ដែលរស់នៅក្នុងឃុំត្រែង បាន ទទួលស្គាល់ និង ថ្លែងអំណរគុណចំពោះការឧបត្ថម្ភហិរញ្ញវត្ថុ ដែលគាត់ទទួលបានពីកូនស្រីរបស់ គាត់ ដែលធ្វើការងារជាកម្មករកាត់ដេរ នៅក្នុងរាជធានីភ្នំពេញ ៖

> ខ្ញុំអាចពឹងផ្អែកទៅលើកូនស្រីច្បងរបស់ខ្ញុំ ដែលធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ នៅឯ ភ្នំពេញ ប៉ុណ្ណោះ អាស្រ័យដោយ នាងអាចរកប្រាក់បាន។ នាងបានផ្តល់ប្រាក់មកឲ្យខ្ញុំ។ បើខ្ញុំ មិនបានទទួលប្រាក់ពីនាងទេនោះ ខ្ញុំប្រាកដជាស្លាប់បាត់ទៅហើយ នៅពេលដែលខ្ញុំឈឺ។

ស្ត្រីម្នាក់ អាយុ ៦៥ឆ្នាំ រស់នៅក្នុងឃុំត្រែង ដែលមានកូនចំនួន ៥នាក់ ពឹងផ្អែកទៅលើកូនប្រុសរបស់ គាត់ ដែលធ្វើការងារជាពលករ នៅឯព្រំដែនប៉ោយប៉ែត ដើម្បីឧបត្ថម្ភគាត់។ គាត់ក៏ពុំបានទទួល ដំណឹងអ្វីពីកូនប្រុសច្បងរបស់គាត់ ដែលបានទៅធ្វើការតាមទូកនេសាទនៅក្នុងប្រទេសថៃ កាលពី ឆ្នាំមុនផងដែរ ៖

> ប្រសិនបើកូនប្រុសរបស់ខ្ញុំនៅប៉ោយប៉ែត មិនបានឧបត្ថម្ភពួកយើងទេនោះ យើងប្រាកដជា អត់ឃ្លានស្លាប់មិនខានទេ។ កាលពីខែមុន ខ្ញុំបានជំពាក់ប្រាក់គេ ចំនួន ៥០.០០០ រៀល ហើយកូនប្រុសរបស់ខ្ញុំបានឲ្យប្រាក់ខ្ញុំចំនួន ១០០.០០០ រៀល ដើម្បីសងគេវិញ។ អ្នកជិតខាងបាននិយាយថាខ្ញុំនឹងមិនអត់ឃ្លាននោះទេ ព្រោះខ្ញុំមានកូនជួយឧបត្ថម្ភ។

នៅក្នុងឃុំតាឡុស បុរសម្នាក់ អាយុ ៦៧ឆ្នាំ ពឹងផ្អែកទៅលើកូនស្រីចំនួន ២នាក់ ដែលកំពុងធ្វើ ការងារជាអ្នកបម្រើតាមផ្ទះ នៅក្នុងខេត្តបាត់ដំបង ដើម្បីឧបត្ថម្ភគាត់ និងភរិយារបស់គាត់ ព្រមទាំង កូនពៅរបស់គាត់ ដែលគរថ្លង់។ បន្ថែមពីនេះទៀត កូនស្រីទាំងពីរនាក់ ក៏បានឧបត្ថម្ភដល់កូនចំនួន ៤នាក់ របស់បងស្រីពួកគេ ដែលបន្សល់ឲ្យរស់នៅជាមួយជីដូនជីតា នៅពេលដែលបងស្រីរបស់ ពួកគេត្រឡប់ទៅរស់នៅឯព្រំដែនប្រទេសថៃ ជាមួយស្វាមីទី២របស់គាត់។ កាលពីមុនមានកូនស្រី ម្នាក់ទៀត (បច្ចុប្បន្ន ទើបតែរៀបការ) ក៏ធ្លាប់ធ្វើការងារជាអ្នកបម្រើតាមផ្ទះនៅក្នុងខេត្តបាត់ដំបង និងបានផ្តល់ការឧបត្ថម្ភជូនដល់គាត់ផងដែរ ៖

> ខ្ញុំមានចៅចំនួន ៤នាក់ ដែលរស់នៅជាមួយខ្ញុំ រួមទាំងកូនរបស់ខ្ញុំម្នាក់ ដែលគរថ្លង់។ ដូច្នេះ សរុបទៅគឺ ៥នាក់។ កាលពីមុនមានកូនស្រីចំនួន ៥នាក់ បានជួយឧបត្ថម្ភខ្ញុំ ប៉ុន្តែ ឥឡូវនេះ មានកូនស្រីម្នាក់បានរៀបការ និងនៅសល់តែកូនស្រីចំនួន ២នាក់ ប៉ុណ្ណោះ ដែលឧបត្ថម្ភ ដល់ខ្ញុំ។ ប៉ុន្តែពួកគេមិនអាចយកប្រាក់ទាំងអស់ ដែលពួកគរកបានដើម្បីឧបត្ថម្ភដល់ខ្ញុំបានទេ ព្រោះយើងត្រូវសងបំណុល។ ពួកគេកំពុងតែជួយសងបំណុលផង និងឧបត្ថម្ភខ្ញុំផង...ខ្ញុំ មានអារម្មណ៍សោកស្តាយណាស់ចំពោះពួកគេ ពីព្រោះពួកគេគ្មានអនាគតនោះទេ។ ពួកគេ ឧបត្ថម្ភខ្ញុំជាមួយនឹងប្រាក់ ដែលពួកគេរកបាន។

ប៉ុន្តែ ខណៈពេលដែលឪពុកម្តាយវ័យចំណាស់មួយចំនួនទទួលបានកិច្ចគាំទ្រហិរញ្ញវត្ថុដ៏សំខាន់នេះ ពីកូនដែលបានធ្វើទេសន្តរប្រវេសន៍ឆ្លងដែន និងកូនដែលបានធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស ឪពុកម្តាយដទៃទៀត ពុំបានទទួលកិច្ចគាំទ្រហិរញ្ញវត្ថុបែបនេះឡើយ។ ឪពុកម្តាយវ័យចំណាស់មួយ ចំនួនទទួលបានប្រាក់ឧបត្ថម្ភបន្តិចបន្តួច ឬមិនទទួលបានអ្វីទាល់តែសោះពីកូនរបស់ពួកគេ ដែល បានធ្វើទេសន្តរប្រវេសន៍។ ស្ត្រីម្នាក់ អាយុ ៦៩ឆ្នាំ រស់នៅឃុំត្រែង ដែលមានកូនចំនួន

៥នាក់ បាន រៀបរាប់អំពីការខាតបង់របស់គាត់ តាមរយៈបទពិសោធន៍នៃការធ្វើទេសន្តរប្រវេសន៍ របស់កូនប្រុស គាត់ នៅក្នុងប្រទេសថៃ ៖

> នៅពេលដែលកូនប្រុសពៅរបស់ខ្ញុំនៅក្នុងប្រទេសថៃ គាត់ធ្លាប់ផ្ញើប្រាក់ឲ្យខ្ញុំដែរ ប្រមាណ ជា៤ដង។ សរុបទៅ ប្រាក់ដែលកូនខ្ញុំបានផ្ញើមកឲ្យខ្ញុំមានចំនួនប្រមាណ ៣.០០០បាត ទៅ ៤.០០០ បាត។ ប្រាក់នេះ គឺជាញើសឈាមរបស់កូនប្រុសខ្ញុំ ដូច្នេះ ខ្ញុំមិនបានចាយប្រាក់ នោះទេ។ ដោយឡែក ខ្ញុំបានសន្សំប្រាក់នោះ និងបានទិញមាស ១ជី ទុកឲ្យកូនខ្ញុំ។ បន្ទាប់ មក ខ្ញុំបានឮថា កូនប្រុសរបស់ខ្ញុំ មានជម្ងឺធ្ងន់ និងត្រូវបានបញ្ជូនទៅខេត្តបន្ទាយមានជ័យ។ ខ្ញុំត្រូវលក់មាសនោះ ដើម្បីព្យាបាល កូនរបស់ខ្ញុំ។ ខ្ញុំត្រូវចំណាយប្រាក់ច្រើនជាងប្រាក់ដែល កូនរបស់ខ្ញុំ បានផ្ញើមកឲ្យខ្ញុំទៅទៀត។ ខ្ញុំមិនអាចពឹងផ្អែកទៅលើកូនរបស់ខ្ញុំបានទេ ដោយ សារតែពួកគេសុទ្ធតែក្រ... តើឲ្យខ្ញុំទាមទារចង់ បានពីពួកគេយ៉ាងដូចម្ដេច នៅពេលដែល ពួកគេក្រជាងខ្ញុំទៅទៀត។

ស្ត្រីមេម៉ាយម្នាក់ អាយុ ៦០ឆ្នាំ ដែលរស់នៅក្នុងឃុំគ្រែង កំពុងថែទាំចៅចំនួន ៣នាក់ ដែល ជាកូន របស់កូនស្រីគាត់ ដែលបានស្លាប់ទៅ។ គាត់ពុំបានទទួលការឧបត្ថម្ភគាំទ្រអ្វីពីកូនប្រុសតែ ម្នាក់របស់ គាត់ដែលនៅរស់ និងដែលកំពុងធ្វើទេសន្តរប្រវេសន៍នៅក្នុងខេត្តប៉ៃលិនឡើយ ៖

> កូនប្រុសរបស់ខ្ញុំមិនដែលផ្ញើប្រាក់មកឲ្យខ្ញុំនោះទេ។ គាត់បានត្រឡប់មកផ្ទះម្ដង នៅពេល បុណ្យសព បងស្រីរបស់គាត់។ នៅពេលដែលត្រឡប់ទៅវិញ គាត់ពុំមានប្រាក់សម្រាប់ថ្លៃ រថយន្តក្រុងឡើយ។ ខ្ញុំបានខ្ចីប្រាក់គេចំនួន ១៥.០០០ រៀល ដើម្បីឲ្យគាត់ជិះរថយន្តក្រុង ត្រឡប់ទៅវិញ។ ខ្ញុំមិនទាន់បានសងប្រាក់នេះទៅគេវិញផង... ខ្ញុំបាននិយាយជាមួយកូន របស់ខ្ញុំថា "កូនអើ្ហ... ម៉ែឥឡូវនេះទីទ័លក្រណាស់។ តើកូនអាចត្រឡប់មករស់នៅជាមួយម៉ែ វិញបានទេ? គ្រែងម៉ែមិនសូវស្រួលខ្លួននៅពេលណាមួយ ម៉ែអាចពឹងកូនបាន"។ គាត់និយាយថា គាត់មិនអាចត្រឡប់ មកវិញបានទេ ព្រោះគាត់មានដីចម្ការលើភ្នំនៅទីនោះ។ បើកូននិយាយ តែរបៀបនេះ តើឲ្យខ្ញុំពឹង ពាក់ទៅលើកូនដូចម្ដេចទៅ?

## ទំនាក់ទំនងសង្គមរវាងឪពុកម្ដាយ និងកូន

ទំនាក់ទំនងសង្គមរវាងឪពុកម្ដាយ និងកូនពេញវ័យ ត្រូវបានផ្ដល់តម្លៃនៅក្នុងប្រទេស កម្ពុជា។ ការធ្វើទេសន្តរប្រវេសន៍របស់កូន ចេញពីឪពុកម្ដាយរបស់ពួកគេ កាត់បន្ថយឱកាសនៃការ ប្រាស្រ័យ ទាក់ទងប្រចាំថ្ងៃ និងគំរាមកំហែងធ្វើឲ្យគុណតម្លៃនេះ មានការធ្លាក់ចុះ។ បើទោះបីជា ការធ្វើទេសន្តរ ប្រវេសន៍ អាចរួមចំណែកជាវិជ្ជមាន ចំពោះសុខុមាលភាពសេដ្ឋកិច្ចរបស់គ្រួសារ របស់អ្នកធ្វើទេសន្តរ ប្រវេសន៍ក៏ដោយ ប៉ុន្តែ វាក៏អាចធ្វើឲ្យមានភាពរេចរិលនូវទំនាក់ទំនងរវាង ឪពុកម្ដាយ និង កូនផងដែរ។ កាលពីអតីតកាល ការរស់នៅឆ្ងាយពីគ្នារវាងឪពុកម្ដាយ និងកូន គឺជា កត្តាដែលហាមឃាត់ មិនឲ្យមានការជួបគ្នាទៀងទាត់ជារៀងរាល់ខែ និង ពុំមានបណ្ដាញទូរស័ព្ទ

ទំនាក់ទំនង។ បច្ចុប្បន្ន ចាប់តាំងពីមានការប្រើប្រាស់ទូរស័ព្ទចល័តយ៉ាងទូលំទូលាយ បានជួយសម្របសម្រួលឪពុកម្តាយ និងកូនដែលធ្វើទេសន្តរប្រវេសន៍ឲ្យប្រាស្រ័យទាក់ទងគ្នាបានយ៉ាងងាយស្រួល បើទោះបីជាពួកគេ រស់នៅឆ្ងាយពីគ្នាក៏ដោយ។

របកគំហើញរបស់យើងបានបង្ហាញឲ្យដឹងថា កូនភាគច្រើនដែលរស់នៅក្រៅស្រុកដែលឪពុកម្តាយរបស់ ពួកគេរស់នៅ មិនចំពោះថា ពួកគេរស់នៅក្នុង ឬក្រៅប្រទេសកម្ពុជាក៏ដោយ ពួកគេតែងនិយាយ និង/ឬ បានទៅសួរសុខទុក្ខឪពុកម្តាយរបស់ពួកគេ យ៉ាងហោចណាស់មួយដងក្នុងមួយខែ។ អ្នកធ្វើ ទេសន្តរប្រវេសន៍ទាំងពីរប្រភេទនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើទូរស័ព្ទចល័តច្រើនជាងការមកសួរ សុខទុក្ខផ្ទាល់ ដើម្បីរក្សាទំនាក់ទំនង។ ការប្រាស្រ័យទាក់ទងទាំងនេះ មានកម្រិតទាបជាង ប៉ុន្តែ ក៏អាចយកទៅធ្វើការប្រៀបធៀបបានជាមួយកូនដែលមិនរស់នៅក្នុងភូមិតែមួយ ប៉ុន្តែ រស់នៅក្នុងស្រុកតែមួយ ជាមួយឪពុកម្តាយរបស់ពួកគេ ដែលកូនទាំងនោះមិនត្រូវបានការសិក្សាស្រាវជ្រាវនេះ ចាត់ទុកថាជាជនទេសន្តរប្រវេសន៍ (រូបភាពទី៧)។

នៅពេលពិភាក្សាអំពីទំនាក់ទំនងសង្គម រវាងឪពុកម្តាយ និងកូន ចាំបាច់ត្រូវចងចាំថា មានឪពុកម្តាយ តិចតួចណាស់ដែលត្រូវបានសម្ភាសន៍ បានឲ្យដឹងថា ពួកគេពុំមានកូនរស់នៅក្បែរ។ មានតែ អ្នកផ្តល់ការឆ្លើយតបដែលមានវ័យចំណាស់ចំនួន ៩% ប៉ុណ្ណោះ ពុំមានកូនរស់នៅក្នុងភូមិ មានតែ ៦% ប៉ុណ្ណោះ ដែលពុំមានកូនរស់នៅក្នុងស្រុក មានតែ ៤% ប៉ុណ្ណោះ ដែលពុំមានកូនរស់នៅក្នុងខេត្ត និងមានតែ ១% ប៉ុណ្ណោះ ដែលពុំមានកូនរស់នៅក្នុងប្រទេសកម្ពុជាជាមួយពួកគេ។ ករណីទាំង៣ នៅក្នុងក្រុមចុងក្រោយ តំណាងឲ្យកូនដែលធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ ដែលរស់នៅក្បែរ ព្រំដែន។ ដូច្នេះ នៅក្នុងកន្លែងដែលត្រូវបានជ្រើសរើស ដើម្បីធ្វើការសិក្សាស្រាវជ្រាវ យើងឃើញថា ជាករណីកម្រណាស់ ចំពោះកូនគ្រប់រូបដែលមានឪពុកម្តាយវ័យចំណាស់ ក្នុងការចាកចេញពីប្រទេស និងក៏ជាករណីកម្រផងដែរ ចំពោះកូនគ្រប់រូបដែលចាកចេញពីខេត្ត ដែលឪពុកម្តាយរបស់ពួកគេ រស់នៅ។

រូបភាពទី៧ ៖ កូនដែលមិនរស់នៅក្នុងភូមិតែមួយជាមួយឪពុកម្តាយរបស់ពួកគេ រក្សាទំនាក់ទំនងសង្គមជាមួយឪពុកម្តាយ យ៉ាងហោចណាស់មួយដងក្នុងមួយខែ




កិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើក បង្ហាញឲ្យដឹងថា ឪពុកម្តាយវ័យចំណាស់ដែលរស់នៅ ក្នុងឃុំត្រែង និងឃុំតាឡូស បានកោតសរសើរចំពោះភាពងាយស្រួលនៃការប្រាស្រ័យទាក់ទងតាម ទូរស័ព្ទជាមួយកូនរបស់ពួកគេ។ មេភូមិជីសាង នៃឃុំត្រែង ដែលមានអាយុ ៦០ឆ្នាំ និងមានកូន ដែលមិនរស់នៅក្នុងស្រុកជាមួយគាត់ ក្នុងខេត្តបាត់ដំបង បានសម្តែងឲ្យឃើញអំពីភាពធូរស្រាលថា គាត់អាចទូរស័ព្ទរកកូនរបស់គាត់បាន នៅពេលដែលគាត់ឈឺ ៖

> វាជាការល្អ ប្រសិនបើមានកូនរស់នៅក្បែរ ព្រោះនៅពេលដែលខ្ញុំឈឺ ពួកគេអាចជួយមើលថែខ្ញុំទាន់ពេល។ សម្រាប់កូនដែលរស់នៅឆ្ងាយ ពួកគេត្រូវចំណាយពេលវេលាមួយចំនួនសម្រាប់ការធ្វើដំណើរ... ដូចយើងដឹងស្រាប់ហើយ ឥឡូវនេះ យើងអាចទូរស័ព្ទបាន។ មិនចំពោះថា ពួកគេនៅឆ្ងាយប៉ុណ្ណានោះទេ យើងអាចទាក់ពួកគេបានជានិច្ច។ ប្រសិនបើខ្ញុំប្រាប់ពួកគេថា ខ្ញុំមានជម្ងឺ ពួកគេប្រាកដជាមកភ្លាម។

ទោះបីជាមនុស្សចាស់ដែលពុំមានទូរស័ព្ទចល័តក៏ដោយ ពួកគេរមែងតែងអាចប្រើប្រាប់ទូរស័ព្ទរបស់ សាច់ញាតិ ឬអ្នកជិតខាងបាន។ លទ្ធភាពក្នុងការដែលអាចប្រើប្រាស់ទូរស័ព្ទចល័តរបស់អ្នកជិតខាង បានធ្វើឲ្យស្ត្រីមេម៉ាយម្នាក់ អាយុ ៦១ឆ្នាំ ដែលរស់នៅក្នុងឃុំតាឡូស អាចនិយាយជាមួយកូនប្រុស របស់គាត់ ដែលជាពលករបម្រើការងារនៅក្នុងវិស័យកសិកម្ម ក្នុងព្រំដែនប្រទេសថៃ ៖

ជូនកាល កូនប្រុសរបស់ខ្ញុំដែលធ្វើការងារនៅឯព្រំដែនប្រទេសថៃ ទូរស័ព្ទមកនរណាម្នាក់នៅទីនេះ និងប្រាប់គេថា គាត់ចង់និយាយជាមួយខ្ញុំ។ ដូច្នេះ គេក៏យកទូរស័ព្ទមកឲ្យខ្ញុំ។ ប្រសិនបើខ្ញុំទូរស័ព្ទរកគាត់ឥឡូវនេះ ខ្ញុំអាចនិយាយជាមួយគាត់បានភ្លាម។ ជូនកាល ខ្ញុំទូរស័ព្ទទៅកូនប្រុសរបស់ខ្ញុំមួយដង ឬ ពីរដងក្នុងមួយខែ... នៅពេលដែលខ្ញុំមានរឿងត្រូវនិយាយជាមួយកូនរបស់ខ្ញុំ។ ប៉ុន្តែ នៅពេលខ្ញុំពុំមានអ្វីត្រូវនិយាយ ខ្ញុំគ្រាន់តែចង់សួរគាត់ថា តើគាត់រកបានការងារធ្វើហើយឬនៅ។

## ការថែទាំចៅ

សេវាកម្មដ៏សំខាន់មួយជាសក្តានុពលដែលឪពុកម្តាយវ័យចំណាស់ ផ្តល់ជូនដល់កូនរបស់ពួកគេ ដែល ធ្វើទេសន្តរប្រវេសន៍ គឺការថែទាំកូនរបស់កូនពួកគេដែលធ្វើទេសន្តរប្រវេសន៍ (ចៅរបស់ពួកគេ)។ សរុបមក អ្នកផ្តល់ការឆ្លើយតបចំនួន ១៤២នាក់ (៥៩%) មានកូនធ្វើទេសន្តរប្រវេសន៍យ៉ាងហោច ណាស់រយៈពេល១ឆ្នាំ ដោយបន្សល់ចៅឲ្យរស់នៅជាមួយពួកគេ។ មានតែ ៦% ប៉ុណ្ណោះ នៃអ្នក ផ្តល់ការឆ្លើយបតទាំងនេះ (ដែលសុទ្ធសឹងតែជាស្ត្រី) ធ្លាប់ចាកចេញពីស្រុក ដើម្បីថែទាំចៅទាំងនេះ យ៉ាងហោចណាស់រយៈពេល៣ខែ។

អ្នកផ្តល់ការឆ្លើយតប ទំនងនឹងថែទាំចៅរបស់ពួកគេនៅឯផ្ទះរបស់ពួកគេ នៅពេលដែលកូនរបស់ ពួកគេធ្វើទេសន្តរប្រវេសន៍ចាកចេញទៅឆ្ងាយ។ សរុបមក ក្នុងចំណោមអ្នកផ្តល់ការឆ្លើយតបចំនួន ១៤២នាក់ មានអ្នកផ្តល់ការឆ្លើយតបចំនួន ៣១នាក់ (ឬ ២២%) មានចៅ (ដែលជាកូនរបស់កូន ពួកគេ ដែលបានធ្វើទេសន្តរប្រវេសន៍) រស់នៅជាមួយពួកគេយ៉ាងហោចណាស់រយៈពេល៦ខែ។ គេទទួលបានសេចក្តីរាយការណ៍ អំពីការថែទាំបែបនេះច្រើនជាង ពីអ្នកផ្តល់ការឆ្លើយតបជាស្ត្រី បើធៀបទៅនឹងអ្នកផ្តល់ការឆ្លើយតបជាបុរស (២៤% ធៀបទៅនឹង ១៨%)។ ស្ទើរតែពាក់កណ្តាលនៃ អ្នកផ្តល់ការឆ្លើយតប ចំនួន ៣១នាក់ទាំងនេះ បានថែទាំចៅលើសពីម្នាក់ ដោយគិតជាមធ្យម ពួកគេ ថែទាំចៅ ចំនួន ១,៨នាក់។ លើសពីនេះទៀត ចៅទាំងនេះ ចំនួនពាក់កណ្តាលបានចាប់ផ្តើមរស់នៅ ជាមួយអ្នកផ្តល់ការឆ្លើយតប ដែលជាជីដូនជីតារបស់ពួកគេ ចាប់តាំងពីពេលដែលពួកគេមានអាយុ ក្រោម ៥ឆ្នាំ។ សរុបរយៈពេលមធ្យម ដែលចៅរស់នៅជាមួយអ្នកផ្តល់ការឆ្លើយតប ដែលជាជីដូន ជីតារបស់ពួកគេ មានចំនួន ៤,២ឆ្នាំ។

ទាក់ទងទៅនឹងថ្លៃចំណាយសម្រាប់ការចិញ្ចឹមចៅទាំងនេះ ក្នុងអំឡុងពេលនៃការថែទាំពួកគេ ជីដូន ជីតាបានរាយការណ៍ឲ្យដឹងថា ពួកគេបានគ្របដណ្តប់ទៅលើការចំណាយនេះ ចំនួនបីភាគប្រាំ និង ឪពុកម្តាយរបស់ចៅទាំងនោះ គ្របដណ្តប់ទៅលើការចំណាយចំនួនមួយភាគបួន ហើយទាំងឪពុក ម្តាយ និងជីដូនជីតា ចែករំលែកថ្លៃចំណាយផ្សេងៗទៀតដែលនៅសេសសល់។

កិច្ចសម្ភាសន៍ដោយការសាកសួរសំនួរបើក បានបង្ហាញឲ្យឃើញអំពីការលំបាក ដែលឪពុកម្តាយ វ័យចំណាស់បានជួបប្រទះ ក្នុងការថែទាំចៅ ដែលជាកូនរបស់កូនពួកគេ ដែលបានធ្វើទេសន្តរ ប្រវេសន៍។ ស្ត្រីមេម៉ាយម្នាក់ អាយុ ៦៧ឆ្នាំ ដែលរស់នៅក្នុងឃុំតាឡុស ថែទាំចៅចំនួន ៣នាក់ ខណៈពេលដែលកូនស្រី និងកូនប្រសាររបស់គាត់ កំពុងធ្វើការងារនៅក្នុងប្រទេសថៃ ដើម្បីរកប្រាក់ សងបំណុល ៖

> កូនស្រីរបស់ខ្ញុំ បានទៅធ្វើការនៅប្រទេសថៃ ជាមួយប្តីរបស់នាង ២ឆ្នាំមកហើយ។ នាងបានផ្ញើប្រាក់មកឲ្យខ្ញុំ ដើម្បីចិញ្ចឹមកូនរបស់នាងនៅទីនេះ។ កូនរបស់ពួកគេទាំង ៣នាក់ រស់នៅជាមួយខ្ញុំ... ខ្ញុំចាស់ហើយ ប៉ុន្តែខ្ញុំត្រូវមើលថែចៅរបស់ខ្ញុំ...កូនស្រីរបស់ខ្ញុំជំពាក់ប្រាក់គេ... ប្តីរបស់នាងក៏ជំពាក់បំណុលគេដែរ។ ដោយសារតែនាងនៅជំពាក់ប្រាក់គេនៅឡើយ ទើបនាងមិនចង់ត្រឡប់មកផ្ទះវិញ។ នាងមិនគិតថា ម្តាយរបស់នាងចាស់នោះទេ។ នាងមិនដែលមកលេងខ្ញុំឡើយ ប៉ុន្តែ តើឲ្យខ្ញុំធ្វើដូចម្តេចទៅ បើនាងនៅជំពាក់បំណុលគេដែរ។

បុរសម្នាក់ អាយុ ៦១ឆ្នាំ ដែលរស់នៅក្នុងឃុំតាឡុស មានកូនចំនួន ៤នាក់ ដែលបានធ្វើទេសន្តរ ប្រវេសន៍ និងកំពុងធ្វើការងារនៅក្នុងប្រទេសថៃ។ កូនស្រីច្បងរបស់គាត់ បានផ្ញើប្រាក់មកឲ្យឪពុកម្តាយរបស់នាង ដើម្បីចិញ្ចឹមកូនរបស់នាងចំនួន ៣នាក់ ដែលកំពុងរស់នៅជាមួយពួកគាត់ ៖

> កូនស្រីច្បងរបស់ខ្ញុំ បានទៅជាមួយប្តីរបស់នាង ដើម្បីរកប្រាក់នៅក្នុងប្រទេសថៃ។ នាងមានលិខិតឆ្លងដែន... នាងបានទៅប្រទេសថៃ ដោយស្របច្បាប់ជាមួយប្តីរបស់នាង...នាងធ្វើការងារជាពលករនៅទីនោះ... នាងយកកូន ២នាក់ទៅជាមួយ និងទុកកូនចំនួន ៣នាក់នៅទីនេះ... ពួកគេទាក់ទងមកខ្ញុំជារៀងរាល់ខែ។ នៅពេលដែលពួកគេមានប្រាក់ ពួកគេផ្ញើប្រាក់ឲ្យខ្ញុំចំនួន ២.០០០បាត ទៅ ៣.០០០ បាត ក្នុងមួយខែដើម្បីចិញ្ចឹមកូនរបស់ពួកគេ។ ប្រាក់ដែលពួកគេផ្ញើមកឲ្យខ្ញុំ គឺសម្រាប់ចំណាយទៅលើការចិញ្ចឹមកូនរបស់ពួកគេប៉ុណ្ណោះ... ពួកគេបានឲ្យប្រាក់ខ្ញុំបន្តិចបន្តួចដែរ សម្រាប់ថ្លៃថ្នាំនៅពេលដែលខ្ញុំឈឺ។ ប្រាក់ទាំងនោះមិនគ្រប់គ្រាន់សម្រាប់ខ្ញុំទិញអ្វីហូបនោះទេ... ពួកគេក៏ពិបាករកប្រាក់ដែរ។ ពួកគេត្រូវកាត់ប្រាក់មួយចំនួនដែលគេរកបាន ដើម្បីសងបំណុលដែលពួកគេជំពាក់ផងដែរ។

បើទោះបីជាការធ្វើទេសន្តរប្រវេសន៍របស់កូន អាចបន្ថែមបន្ទុកថែទាំមួយចំនួន ទៅលើឪពុកម្តាយ ដែលមានវ័យចំណាស់ក៏ដោយ វាពុំមែនជាកត្តាតែម្យ៉ាងដែលធ្វើឲ្យមនុស្សចាស់ត្រូវថែទាំចៅរបស់ ពួកគេនោះទេ។ មានករណីមួយចំនួនដែលមរណភាពរបស់កូន ដែលមិនបានធ្វើទេសន្តរប្រវេសន៍ តម្រូវឲ្យមនុស្សចាស់ត្រូវថែទាំចៅរបស់ពួកគេផងដែរ។ ស្ត្រីម្នាក់ អាយុ ៦៣ឆ្នាំ ដែលរស់នៅក្នុង ឃុំតាឡុស បានរៀបរាប់អំពីរបៀបដែលគាត់ បានឆ្លងកាត់ភាពអាម៉ាស់របស់គាត់

ក្រោយពេល ដែលកូនរបស់គាត់ចំនួន ២នាក់ ដែលពុំមែនជាអ្នកធ្វើទេសន្តរប្រវេសន៍បានស្លាប់ ដោយសារ ជំងឺអេដស៍។ បច្ចុប្បន្ន គាត់កំពុងចិញ្ចឹមចៅកំព្រា ៤នាក់ ជាមួយស្វាមីរបស់គាត់ ៖

> ខ្ញុំត្រូវចិញ្ចឹមចៅកំព្រាចំនួន ៤នាក់...ឪពុកម្តាយរបស់ពួកគេបានស្លាប់អស់ទៅហើយ... បើនិយាយតាមធម៌ព្រះពុទ្ធ ខ្ញុំជំពាក់កម្មគេ... ខ្ញុំមានការខ្មាសអៀនខ្លាំងណាស់ ពីព្រោះពួកគេសុទ្ធសឹងតែស្លាប់ដោយជំងឺអេដស៍ម្តងម្នាក់ៗ... ខ្ញុំបានចាកចេញពីផ្ទះ ដើម្បីទៅរស់នៅស្រុកមោងឫស្សី។ ខ្ញុំមិនចង់ឲ្យនរណាឃើញខ្ញុំទេ... ប៉ុន្តែ ក្រោយមកនៅពេលដែលខ្ញុំឃើញអ្នកដទៃ ក៏កើតជំងឺដូចគ្នាដែរ ទើបខ្ញុំមិនសូវមានអារម្មណ៍ខ្មាសគេ។

ស្ត្រីមេម៉ាយម្នាក់ អាយុ ៦០ឆ្នាំ ដែលរស់នៅក្នុងឃុំត្រែង កំពុងថែទាំចៅចំនួន ៣នាក់ ជាកូនរបស់ កូនស្រីគាត់ ដែលពុំមែនជាអ្នកធ្វើទេសន្តរប្រវេសន៍ និងដែលទើបតែស្លាប់នាពេលថ្មីៗនេះ។ គាត់ បានរអ៊ូរទាំថា ឪពុករបស់ពួកគេ ដែលរស់នៅក្នុងផ្ទះជាមួយគាត់ដែរ គឺជាទាហាន និងផ្តល់ការឧបត្ថម្ភបន្តិចបន្តួចប៉ុណ្ណោះ ៖

> ខ្ញុំរស់នៅទីនេះជាមួយចៅ ៣នាក់... បន្ទាប់ពីកូនស្រីរបស់ខ្ញុំបានផ្តល់កំណើតដល់កូនទី៣របស់នាង នាងក៏ធ្លាក់ខ្លួនឈឺប្រមាណជា ៣ខែ ហើយក្រោយមកនាងក៏ស្លាប់ទៅ...ខ្ញុំបានខិតខំចិញ្ចឹមចៅរបស់ខ្ញុំ។ ជួនកាល អ្នកជិតខាងឲ្យប្រាក់ខ្ញុំ ១.០០០ រៀល ទៅ ២.០០០ រៀល ដើម្បីទិញអាហារ។ ក្មួយស្រីរបស់ខ្ញុំឲ្យអង្ករខ្ញុំ ២-៣ កំប៉ុង.... ជីវភាពខ្ញុំក្រីក្រខ្លាំងណាស់.... ខ្ញុំមិនអាចធ្វើអ្វីបានទេ ក្រៅពីដើរស៊ីឈ្នួលគេ។ ប្រសិនបើខ្ញុំទៅធ្វើការ ខ្ញុំត្រូវទុកចៅរបស់ខ្ញុំឲ្យនៅតែឯង។ គ្មាននរណាចំអិនអាហារសម្រាប់ពួកគេនោះទេ... ដូច្នេះ ខ្ញុំត្រូវតែនៅជាមួយពួកគេ... នៅពេលដែលខ្ញុំស្លាប់ទៅ ខ្ញុំមិនដឹងថា ចៅរបស់ខ្ញុំមិនដឹងជាយ៉ាងម៉េចនោះទេ... ឪពុករបស់ពួកគេ ក៏រស់នៅក្នុងផ្ទះនេះដែរ។ គាត់គឺជាទាហាន ប៉ុន្តែ គាត់មិនបានផ្តល់អ្វីសម្រាប់កូនរបស់គាត់ឡើយ... គាត់ផឹកស្រាជារៀងរាល់យប់ រហូតទល់ភ្លឺ... គាត់និយាយជាមួយកូនបានតែពីរបីម៉ាត់ ហើយបន្ទាប់មក ក៏បាត់ស្រមោលដូចអំពិលអំពែកអញ្ចឹង។

## សុខភាព និងសុខុមាលភាពផ្លូវចិត្តរបស់ឪពុកម្តាយ

ផ្អែកលើពិន្ទុទាបបំផុតរបស់អ្នកផ្តល់ការឆ្លើយតប ឬសហព័ទ្ធ អ្នកផ្តល់ការឆ្លើយតបដែលពុំមានកូន កំពុងធ្វើទេសន្តរប្រវេសន៍បច្ចុប្បន្ន ឬ កូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍និងបានត្រឡប់មកវិញ បានធ្វើការប៉ាន់ប្រមាណទៅលើស្ថានភាពសុខភាពបច្ចុប្បន្នរបស់ពួកគេ ឬ របស់សហព័ទ្ធពួកគេ ក្នុង លក្ខណៈមួយល្អប្រសើរជាង បើធៀបទៅនឹងអ្នកផ្តល់ការឆ្លើយតប ដែលមានកូនកំពុងធ្វើទេសន្តរប្រវេសន៍ ឬ ធ្លាប់ធ្វើទេសន្តរប្រវេសន៍និងបានត្រឡប់មកវិញ។ ស្របពេលជាមួយគ្នានេះដែរ អ្នកផ្តល់ការឆ្លើយតបច្រើនជាងពាក់កណ្តាលដែលពុំមានកូនកំពុងធ្វើទេសន្តរប្រវេសន៍និងច្រើន

ជាង ពីរភាគបីនៃអ្នកផ្តល់ការឆ្លើយតប ដែលមានកូនកំពុងធ្វើទេសន្តរប្រវេសន៍ពេលបច្ចុប្បន្ន ឬ កូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍និងបានត្រឡប់មកវិញ បានរៀបរាប់អំពីចំណាត់ថ្នាក់នៃសុខភាព ផ្ទាល់ខ្លួនរបស់ពួកគេ ឬសុខភាពរបស់សហព័ទ្ធពួកគេ ថាមានភាពទន់ខ្សោយ ឬ ទន់ខ្សោយខ្លាំង (តារាងទី៥)។

ក្នុងចំណោមអ្នកផ្តល់ការឆ្លើយតប និងសហព័ទ្ធ ដែលមាន ឬ ពុំមានកូនកំពុងធ្វើទេសន្តរប្រវេសន៍ ឬ ធ្លាប់ធ្វើទេសន្តរប្រវេសន៍និងបានត្រឡប់មកវិញ ភាគរយរបស់ដែនកំណត់នៃការបំពេញមុខងារ មានលក្ខណៈស្ទើរតែដូចគ្នាទាំងស្រុង ទៅនឹងមធ្យមភាគពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ និង មធ្យមភាគពិន្ទុសុខុមាលភាពផ្លូវចិត្ត។ បើទោះជាដូច្នេះក្តី គួរកត់សម្គាល់ថា ១៧% នៃមនុស្សចាស់ ដែលមានកូនធ្លាប់ធ្វើទេសន្តរប្រវេសន៍និងបានត្រឡប់មកវិញ បានរងគ្រោះពីសកម្មភាពមួយនៃ ភាពមានកម្រិតនៅក្នុងការរស់នៅប្រចាំថ្ងៃ (អ្នកផ្តល់ការឆ្លើយតប ឬ សហព័ទ្ធត្រូវការជំនួយដើម្បី ថែទាំពួកគេ) បើធៀបទៅនឹងមនុស្សចាស់ចំនួន ១០% ដែលមានកូនកំពុងធ្វើទេសន្តរប្រវេសន៍ នាពេលបច្ចុប្បន្ននិង ៦% ដែលពុំមានកូនធ្វើទេសន្តរប្រវេសន៍។ របកគំហើញនេះ អាចបង្ហាញថា កូន មួយចំនួនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ និងបានត្រឡប់មកវិញ បានមកផ្ទះ ដើម្បីថែទាំឪពុកម្តាយរបស់ពួកគេ នៅពេលដែលឪពុកម្តាយមិនអាចថែទាំខ្លួនឯងបាន។

## តារាងទី៥ ៖ សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកផ្ដល់ការឆ្លើយតប និងសហព័ទ្ធ បែងចែកទៅតាមស្ថានភាពទេសន្តរប្រវេសន៍របស់កូន

| | ស្ថានភាពទេសន្តរប្រវេសន៍របស់កូន | | |
|---|---|---|---|
| | គ្មានកូនកំពុង ឬ ធ្លាប់ធ្វើទេសន្តរប្រវេសន៍ | មានកូនកំពុង ធ្វើទេសន្តរប្រវេសន៍[១] | មានកូនធ្លាប់ធ្វើ ទេសន្តរប្រវេសន៍[២] |
| ចំនួនករណី | ៨៥ | ១៧១ | ៤២ |
| ការបែងចែកចំនួនភាគរយនៃ ស្ថានភាពសុខភាពបច្ចុប្បន្ន[៣] | | | |
| ល្អ | ៨.២ | ២.៩ | ២.៤ |
| មធ្យម | ៣៧.៦ | ២៩.២ | ២៦.២ |
| ខ្សោយ ឬ ខ្សោយខ្លាំង | ៥៤.១ | ៦៧.៨ | ៧១.៤ |
| ការបែងចែកចំនួនភាគរយនៃ ស្ថានភាពសុខភាពកាលពីឆ្នាំមុន[៣] | | | |
| មានភាពប្រសើរឡើង | ១១.៨ | ៦.៤ | ៧.១ |
| នៅដដែល | ៥.៩ | ១៤.៦ | ៧.១ |
| ធ្ងន់ធ្ងរជាងមុន | ៨២.៤ | ៧៨.៩ | ៨៥.៧ |
| ភាគរយនៃភាពមានកម្រិត ចំពោះការបំពេញមុខងារ[៤] | ៤២.៤ | ៥៥.៦ | ៥៧.១ |
| ភាគរយនៃភាពមានកម្រិត ចំពោះការងារផ្ទះ[៥] | ៤៣.៥ | ៥១.៥ | ៥៤.៨ |
| ភាគរយនៃភាពមានកម្រិតចំពោះ សកម្មភាពមួយ ក្នុងការរស់នៅ ប្រចាំថ្ងៃ[៦] | ៥.៨ | ៩.៩ | ១៦.៧ |
| មធ្យមភាពពិន្ទុនៃការពេញចិត្ត ចំពោះគ្រួសារ[៧] | ៧.៥ | ៧.៤ | ៧.៥ |
| មធ្យមភាគពិន្ទុសុខុមាលភាព ផ្លូវចិត្ត[៧] | ១១.៤ | ១១.១ | ១១.៣ |

តេស្តស្ថិតិគួរឲ្យកត់សម្គាល់ មិនត្រូវបានបង្កើតឡើងសម្រាប់តារាងនេះឡើយ។

១. អ្នកផ្ដល់ការឆ្លើយតប ក៏អាចមានកូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ និងបានត្រឡប់មកវិញផងដែរ។

២. អ្នកផ្ដល់ការឆ្លើយតប ក៏អាចមានកូនដែលបច្ចុប្បន្នកំពុងធ្វើទេសន្តរប្រវេសន៍ផងដែរ។

៣. តាមរយៈពិន្ទុទាបបំផុតនៃអ្នកផ្ដល់ការឆ្លើយតប ឬ សហព័ទ្ធ។

៤. ភាពមានកម្រិតនៃការបំពេញមុខងារ មានន័យថា អ្នកផ្ដល់ការឆ្លើយតប ឬ សហព័ទ្ធ មានការលំបាក មួយចំនួន ឬមិនអាចធ្វើដំណើរបានចំនួន ២០០ម៉ែត្រ ដោយខ្លួនឯង ឬ មានការលំបាក ឬ មិនអាចលើកកញ្ចប់អង្ករដែលមានទម្ងន់ ៥គីឡូក្រាមបាន។

៥. ភាពមានកម្រិតចំពោះការងារផ្ទះ មានន័យថា អ្នកផ្ដល់ការឆ្លើយតប ឬ សហព័ទ្ធ មានការលំបាកមួយចំនួន ឬ មិនអាចធ្វើការងារផ្ទះមួយចំនួន ដូចជា បោសសំអាតផ្ទះ ចំអិនអាហារ ឬ ជូសជុលផ្ទះ។

៦. សម្រាប់និយមន័យនៃពាក្យថា អ្នកផ្ដល់ការឆ្លើយតប ឬ សហព័ទ្ធ សូមមើលតារាងទី៣។

៧. សូមមើលតារាងទី៣ សម្រាប់និយមន័យ។

កិច្ចសម្ភាសន៍ដោយសាកសួរសំនួរបើក ផ្ដល់នូវការយល់ដឹងមួយចំនួនអំពីសុខុមាលភាពផ្លូវចិត្ត របស់ឪពុកម្ដាយដែលមានវ័យចំណាស់ មិនចំពោះថាពួកគេធ្លាប់ ឬ មិនធ្លាប់មានកូនធ្វើទេសន្តរ ប្រវេសន៍ឡើយ។ មនុស្សចាស់ ដែលកំពុងសុំសីលទៅតាមជំនឿព្រះពុទ្ធសាសនា ហាក់មានការយល់ឃើញថា ពួកគេនឹងទៅដល់ឋានសុខ នៅពេលដែលពួកគេលាចាកពីលោកនេះ។ អាចារ្យម្នាក់ អាយុ ៦០ឆ្នាំ រស់នៅក្នុងឃុំតាឡុស ដែលមានកូនធ្វើទេសន្តរប្រវេសន៍ឆ្លងដែន និងធ្វើទេសន្តរ ប្រវេសន៍នៅក្នុងប្រទេស បានរៀបរាប់អំពីការដែលគាត់កំពុងត្រៀមខ្លួនសម្រាប់ជាតិក្រោយ ៖

> ខ្ញុំធ្វើអាចារ្យ ៥-៦ឆ្នាំហើយ... បច្ចុប្បន្ន ខ្ញុំកំពុងខិតខំសន្សំបុណ្យកុសល្យសម្រាប់ជាតិក្រោយ។ ខ្ញុំមិនសូវចាប់អារម្មណ៍ចំពោះជីវិតរស់នៅក្នុងជាតិនេះទេ។ នេះគឺដោយសារតែជីវិតមនុស្ស ខ្លីពេក ដូច្នេះ ខ្ញុំកំពុងស្វែងរកអ្វីដែលជាបុណ្យកុសល្យសម្រាប់អនាគត។ យើងមិនអាចពឹង ផ្អែកទៅលើកូនរបស់យើងបានឡើយ... ឪពុកម្ដាយត្រូវពឹងផ្អែកទៅលើខ្លួនឯង នៅពេលដែល កូនរៀបការហើយ... នេះគឺជាជីវិត។ ដូច្នេះ យើងត្រូវតែធ្វើអ្វីដែលយើងអាចធ្វើបាននៅពេល នេះ... យើងមិនអាចរង់ចាំឲ្យតែកូនជួយនោះទេ... យើងគួរតែរៀបចំកន្លែងរបស់យើងឲ្យ ហើយទៅ នៅពេលនេះ។ នេះគឺជាជីវិតរបស់ជនជាតិខ្មែរ ដែលកាន់ព្រះពុទ្ធសាសនា។

ស្រដៀងគ្នានេះដែរ បុរសម្នាក់ អាយុ ៦២ឆ្នាំ រស់នៅក្នុងឃុំត្រែងជាមួយកូន ២នាក់ ដែលកូនរបស់ គាត់ទាំងពីរ សុទ្ធសឹងតែមិនមែនជាអ្នកធ្វើទេសន្តរប្រវេសន៍ បានរៀបរាប់អំពីសារៈសំខាន់នៃការ ឃ្លាតចាកពីការបារម្ភនៅលើភពផែនដី និងការត្រៀមខ្លួនសម្រាប់ការស្លាប់ ៖

> ឥឡូវនេះ ខ្ញុំអត់មានបញ្ហាអ្វីនោះទេ ក្រៅពីបញ្ហាជីវភាព។ ខ្ញុំក៏គ្មានការបារម្ភខ្វល់ខ្វាយអ្វីដែរ។ ខ្ញុំគិតតែពីធម៌អារ្យប៉ុណ្ណោះ... នេះគឺជាផ្លូវសម្រាប់អនាគត... ទ្រព្យសម្បត្តិមិនអាចជួយគាំទ្រ ដល់ជីវិតមនុស្សបានឡើយ។ មនុស្សត្រូវតែចេះកសាងខ្លួនឯង ដើម្បីឲ្យគេចផុតពីទុក្ខវេទនា ទាំងពួង... នៅពេលដែលយើងលាចាកពីលោកនេះ និងត្រឡប់ទៅពិភពដើមរបស់យើងវិញ គ្មាននរណាអាចជួយយើងបានឡើយ ក្រៅពីបុណ្យកុសល្យរបស់យើង... កូនរបស់យើង អាចជួយយើងបាននៅពេលដែលយើងនៅរស់ប៉ុណ្ណោះ។ ប៉ុន្តែនៅពេលដែលយើងស្លាប់ទៅ ពួកគេមិនអាចជួយយើងបានឡើយ... នៅពេលដែលយើងស្លាប់ គ្មាននរណាអាចជួយយើង បាននោះទេ ក្រៅពីខ្លួនឯង។ យើងត្រូវសម្លឹងមើលទៅមុខ... យើងត្រូវមើលទៅអនាគត។ ជីវិតនៅលើភពផែនដីរបស់យើង គឺមានតែនៅក្នុងជាតិនេះទេ... អញ្ចឹងហើយ ទើបព្រះធម៌ គឺជាផ្លូវដែលយើងត្រូវដើរ។

បុរសពោះម៉ាយម្នាក់ អាយុ ៧០ឆ្នាំ ដែលរស់នៅក្នុងឃុំតាឡុស មានកូនចំនួន ៨នាក់ និងមានដី គ្រប់គ្រាន់ ដូច្នេះ មានតែកូនប្រុសម្នាក់ប៉ុណ្ណោះ ដែលបានធ្វើទេសន្តរប្រវេសន៍ចេញពីស្រុកទៅ ភ្នំពេញ។ ខណៈពេលដែលគាត់មានមោទនភាព ចំពោះការដែលគាត់អាចមានលទ្ធភាពផ្គត់ផ្គង់គ្រួសាររបស់គាត់បាន គាត់ក៏មានការសោកស្ដាយផងដែរ ដែលគាត់មិនអាចធ្វើបុណ្យកឋិនទានមួយបាន ៖

ខ្ញុំចាស់ហើយ... ប្រសិនបើខ្ញុំស្លាប់ វាគឺជារឿងធម្មតានោះទេ... ប្រសិនខ្ញុំស្លាប់ក៏ស្លាប់ចុះ... កាលប្រពន្ធខ្ញុំនៅរស់ ខ្ញុំគិតគូអំពីប្រពន្ធ និងកូនរបស់ខ្ញុំ។ ប៉ុន្តែ ឥឡូវនេះ កូនរបស់ខ្ញុំបាន រៀបការអស់ហើយ ហើយប្រពន្ធខ្ញុំក៏បានស្លាប់បាត់ទៅហើយដែរ ដូច្នេះ ខ្ញុំរស់នៅតែម្នាក់ឯង នោះទេ... នៅពេលដែលពួកគេរស់នៅទីនេះ ខ្ញុំត្រូវខិតខំរកប្រាក់ដើម្បីចិញ្ចឹមពួកគេ ដូច្នេះ ហើយ ទើបខ្ញុំមិនអាចសន្សំប្រាក់ដើម្បីធ្វើបុណ្យកឋិនទានមួយបាន។ ខ្ញុំអាចត្រឹមតែឧបត្ថម្ភ ផ្គត់ផ្គង់គ្រួសារខ្ញុំតែប៉ុណ្ណោះ... នៅពេលដែលប្រពន្ធ និង កូនរបស់ខ្ញុំនៅជុំវិញខ្លួនខ្ញុំ ខ្ញុំចង់ មានស្រែចម្ការ និង ទ្រព្យសម្បត្តិ សម្រាប់ប្រពន្ធ និងកូនរបស់ខ្ញុំ។ ប៉ុន្តែ ឥឡូវនេះ ខ្ញុំលែង ចង់បានរបស់ទាំងនេះទៀតហើយ។ អ្វីដែលខ្ញុំចង់បាននៅពេលនេះ គឺការសាងអំពើល្អ និង បុណ្យកុសល្យសម្រាប់ជាតិក្រោយ។ នៅពេលដែលខ្ញុំមានប្រាក់បន្តិចបន្តួច ខ្ញុំតែងតែយកទៅធ្វើបុណ្យ... នៅពេលដែលខ្ញុំមានប្រាក់ខ្លះ ខ្ញុំតែងតែទៅវត្តនៅថ្ងៃសីល។

# សេចក្តីសន្និដ្ឋាន

របកគំហើញនៃឯកសារស្រាវជ្រាវរបស់យើងបង្ហាញឲ្យដឹងច្បាស់ថា ការធ្វើទេសន្តរប្រវេស្តន៍ (ពុំមែនជាការបោះបង់) គឺជាគោលដៅនៃការធ្វើអង្កេតទៅលើគ្រួសារដែលមានមនុស្សចាស់។ អ្នក ផ្តល់ការឆ្លើយតបប្រមាណជិតពីរភាគបី បានរាយការណ៍ឲ្យដឹងថា មានកូនម្នាក់ដែលកំពុងធ្វើទេសន្តរប្រវេស្តន៍នាពេលបច្ចុប្បន្ន ដោយឡែក អ្នកផ្តល់ការឆ្លើយតបចំនួនបួនភាគប្រាំ មានកូនម្នាក់ កំពុងរស់នៅជាមួយ។ បើទោះបីជាអត្រានៃការធ្វើទេសន្តរប្រវេស្តន៍របស់កូនពួកគេ មានកម្រិត ខ្ពស់ក៏ដោយ ឪពុកម្តាយដែលមានវ័យចំណាស់ មិនត្រូវបានទុកចោលឲ្យរស់នៅតែម្នាក់ឯងឡើយ។ គេអាចពន្យល់បានថា កត្តានេះ គឺបណ្តាលមកពីអ្នកផ្តល់ការឆ្លើយតប ដែលមានអាយុចន្លោះពី ៦០-៧០ឆ្នាំ ទាំងនេះ មានកូនច្រើន។ ជាមធ្យម អ្នកផ្តល់ការឆ្លើយតបមានកូនចំនួន ៤,៨ នាក់ ដែលនៅរស់។ កត្តានេះ អនុញ្ញាតឲ្យកូនមួយចំនួនធ្វើទេសន្តរប្រវេសន៍ និងកូនដទៃទៀតបន្តរស់នៅក្នុង ផ្ទះ ឬ ភូមិជាមួយឪពុកម្តាយរបស់ពួកគេ។ អ្នកផ្តល់ការឆ្លើយតបច្រើនជាងបីភាគបួនដែលមានកូន កំពុងធ្វើទេសន្តរប្រវេសន៍ ក៏កំពុងរស់នៅជាមួយកូនម្នាក់ផងដែរ។ ស្របទៅនឹងគំហើញដែលបាន ឲ្យដឹងថា អត្រានៃការធ្វើទេសន្តរប្រវេសន៍ខ្ពស់ ពុំបានបន្សល់ឲ្យឪពុកម្តាយដែលមានវ័យចំណាស់ រស់នៅតែម្នាក់ឯង គឺជាគំហើញដែលបានរកឃើញថា ពុំមែនកូនទាំងអស់ដែលមានកាយសម្បទា បរិបូរណ៍ សុទ្ធសឹងតែបានធ្វើទេសន្តរប្រវេសន៍នោះទេ។ មានតែ ៣៣% ប៉ុណ្ណោះនៃកូនរបស់អ្នក ផ្តល់ការឆ្លើយតបចំនួន ១.២៦៨នាក់ ធ្លាប់ធ្វើទេសន្តរប្រវេសន៍។

បើទោះបីជាពុំមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ទៅលើស្ថិតិ រវាងអ្នកផ្តល់ការឆ្លើយតបដែល មានវ័យចំណាស់ ដោយផ្អែកទៅលើភេទ និងស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន ទាក់ទងទៅនឹង ស្ថានភាពទេសន្តរប្រវេសន៍នៃកូនរបស់ពួកគេក៏ដោយ ឪពុកម្តាយដែលមានវ័យចំណាស់នៅក្នុង ឃុំតាឡុស មានកូនដែលធ្លាប់ធ្វើទេសន្តរប្រវេសន៍ ក្នុងកម្រិតភាគរយច្រើនជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងឪពុកម្តាយវ័យចំណាស់ ដែលរស់នៅក្នុងឃុំត្រែង។ បើទោះបីជាឃុំត្រែងមានទីតាំង ភូមិសាស្ត្រស្ថិតនៅជិតព្រំដែនថៃ ជាងឃុំតាឡុសក៏ដោយ ប៉ុន្តែ អត្រាភាគរយនៃឪពុកម្តាយវ័យ ចំណាស់ ដែលមានកូនធ្វើទេសន្តរប្រវេសន៍មានកម្រិតខ្ពស់ជាងគួរឲ្យកត់សម្គាល់ចំពោះកូនដែល បានធ្វើទេសន្តរប្រវេសន៍ទៅធ្វើការងារនៅក្បែរព្រំដែនក្នុងប្រទេសថៃ។ ភាពខុសគ្នានេះ អាចឆ្លុះ បញ្ចាំងអំពីបណ្តាញសង្គម ដែលមានលក្ខណៈរឹងមាំ និងមានការអភិវឌ្ឍន៍ជាងមុនដែលជម្រុញឲ្យ មានការធ្វើទេសន្តរប្រវេសន៍បែបនេះ នៅក្នុងឃុំតាឡុសច្រើនជាងឃុំត្រែង ដែលគេអាចធ្វើការ តាមដានបាន អំពីភាពខុសប្លែកគ្នានៃប្រវត្តិតាំងទីលំនៅរបស់ឃុំទាំងពីរនេះ ការរៀបចំការរស់នៅ និងទីតាំងជាក់លាក់។

ការធ្វើទេសន្តរប្រវេសន៍របស់កូនពេញវ័យ ចេញពីតំបន់ជនបទ តែងត្រូវបានគេធ្វើអត្ថាធិប្បាយថា ជាការធ្វើឲ្យធ្លាក់ចុះនូវសុខុមាលភាពរបស់ឪពុកម្តាយ ដែលមានវ័យចំណាស់។ ការសិក្សារបស់ យើងពុំបានគាំទ្រទៅលើការសង្កេតយ៉ាងដូច្នេះទេ។ ជាទូទៅ ស្ថានភាពរបស់

ឪពុកម្តាយវ័យចំណាស់ ដែលមាន ឬ គ្មានកូនធ្វើទេសន្តរប្រវេសន៍ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ជាក់ស្តែង មធ្យមភាគពិន្ទុទ្រព្យសម្បត្តិ ពិន្ទុសមត្ថភាពកាយសម្បទា ពិន្ទុនៃការពេញចិត្តចំពោះគ្រួសារ ពិន្ទុសុខុមាលភាពផ្លូវចិត្ត និងភាគរយចំពោះដែនកំណត់នៃសកម្មភាពរស់នៅប្រចាំថ្ងៃ ស្ទើរតែមានកម្រិតដូចគ្នា។ ស្របពេលជាមួយគ្នានេះ អ្នកផ្តល់ការឆ្លើយតបដែលមានកូនកំពុងធ្វើទេសន្តរប្រវេសន៍នាពេលបច្ចុប្បន្ន បានរាយការណ៍ឲ្យដឹងអំពីអត្រានៃការគ្មានដីធ្លី ដែលមានកម្រិតខ្ពស់ជាងអ្នកផ្តល់ការឆ្លើយតប ដែល ពុំមានកូនកំពុងធ្វើទេសន្តរប្រវេសន៍នាពេលបច្ចុប្បន្ន។ នេះពុំមែនជារឿងគួរភ្ញាក់ផ្អើលឡើយ អាស្រ័យ ដោយគ្រួសារដែលពុំមានដីធ្លី មានសម្ពាធខ្លាំងជាងដែលតម្រូវឲ្យកូនធ្វើទេសន្តរប្រវេសន៍រក ការងារធ្វើ។

គេបាននិយាយថា ការធ្វើទេសន្តរប្រវេសន៍របស់កូនពេញវ័យ ចេញពីតំបន់ជនបទ បានទុកឲ្យឪពុក ម្តាយវ័យចំណាស់ធ្វើការងារស្រែចម្ការ ដោយគ្មាននរណាជួយ។ ការស្រាវជ្រាវរបស់យើងមិនគាំទ្រ ចំពោះអំណះអំណាង ដែលបានលើកឡើងយ៉ាងដូច្នេះឡើយ។ ខណៈពេលដែលកូនដែលរស់នៅ ជាមួយ ឬ រស់នៅក្បែរឪពុកម្តាយរបស់ពួកគេ ផ្តល់ជំនួយជាប្រចាំ ចំពោះការប្រកបរបរអាជីវកម្ម ឬការងារស្រែចម្ការ កូនដែលរស់នៅឆ្ងាយ បានរួមចំណែកផ្តល់វិភាគទានជាថវិកាច្រើនជាង។ ចំណុចនេះ បានឲ្យដឹងថា កូនរួមចំណែកជួយឧបត្ថម្ភគាំទ្រដល់ឪពុកម្តាយរបស់ពួកគេក្នុងលក្ខណៈ ផ្សេងៗគ្នា អាស្រ័យទៅតាមកន្លែងរស់នៅរបស់ពួកគេ។ កូនដែលបន្តរស់នៅជាមួយឪពុកម្តាយ របស់ពួកគេ អាចមានលទ្ធភាពរួមចំណែកផ្តល់ជំនួយជាប្រចាំ ចំពោះការប្រកបរបរអាជីវកម្ម និង ការងារស្រែចម្ការ។ ដោយឡែក កូនដែលរស់នៅក្រៅស្រុក ក្នុងប្រទេសកម្ពុជា និងកូនដែលរស់នៅ ក្រៅប្រទេស តែងរួមចំណែកដ៏សំខាន់ចំពោះកិច្ចគាំទ្រជាថវិកា។

ការសិក្សាស្រាវជ្រាវមួយ របស់ CDRI ដែលមានមូលដ្ឋានផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៧ ដែលតំណាងឲ្យប្រទេសទាំងមូល បានឲ្យដឹងថា ប្រាក់ដែលកូនធ្វើទេសន្តរប្រវេសន៍ទៅ ក្រៅប្រទេសបានផ្ញើឲ្យគ្រួសារ មានប្រសិទ្ធភាពជាង ក្នុងការកាត់បន្ថយភាពក្រីក្រ ជាងប្រាក់ដែល កូនធ្វើទេសន្តរប្រវេសន៍ក្នុងប្រទេសបានផ្ញើជូន (Tong, 2010)។ ស្រដៀងគ្នានេះដែរ ការសិក្សារបស់ យើងបានរកឃើញថា កូនដែលបានធ្វើទេសន្តរប្រវេសន៍ឆ្លងដែន ទំនងនឹងផ្តល់ជំនួយឧបត្ថម្ភហិរញ្ញវត្ថុច្រើនជាង តាមរយៈការផ្ញើប្រាក់ បើធៀបទៅនឹងកូនដែលធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស បើទោះបីជាគេត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក៏ដោយ។ ការផ្ញើប្រាក់ពីកូនដែលបានធ្វើទេសន្តរប្រវេសន៍ ទៅធ្វើការងារនៅឯរាជធានីភ្នំពេញ មានកម្រិតប្រហាក់ប្រហែលគ្នាទៅនឹងកូនដែលបានធ្វើទេសន្តរ ប្រវេសន៍ឆ្លងដែនដែរ ដែលចំណុចនេះ ស្តែងឲ្យយើងដឹងថា កន្លែងទាំងនេះផ្តល់នូវការងារដែល ទទួលបានប្រាក់កម្រៃខ្ពស់ សម្រាប់កូនដែលធ្វើទេសន្តរប្រវេសន៍។ បើទោះជាដូច្នេះក្តី គុណតម្លៃ ថវិកាដែលមានកម្រិតទាបនៃប្រាក់ដែលបានផ្ញើជូននៅក្នុងករណីទាំងពីរនេះ គាំទ្រដល់គំហើញនៃ ការសិក្សាស្រាវជ្រាវដទៃទៀតដែលបានបញ្ជាក់ថា ប្រាក់ដែលបានផ្ញើក្នុងប្រទេសកម្ពុជា តែងត្រូវ បានប្រើប្រាស់ ដើម្បីចំណាយទៅលើថ្លៃជីវភាពរស់នៅប្រចាំថ្ងៃ (Analyzing Development Issues, 2005; Tong, 2010)។

ឪពុកម្តាយតែងផ្តល់កិច្ចគាំទ្រហិរញ្ញវត្ថុដល់កូនដែលធ្វើទេសន្តរប្រវេសន៍ ជាពិសេស ចំពោះថ្លៃចំណាយនៅដំណាក់កាលដំបូង នៃដំណើរការទេសន្តរប្រវេសន៍។ កូនដែលធ្វើទេសន្តរប្រវេសន៍ស្ទើរតែពាក់កណ្តាល បានទទួលជំនួយពីឪពុកម្តាយរបស់ពួកគេ ដើម្បីបង់ថ្លៃធ្វើទេសន្តរប្រវេសន៍។ ស្របពេលជាមួយគ្នានេះដែរ កូនដែលបានធ្វើទេសន្តរប្រវេសន៍ច្រើនជាងពាក់កណ្តាល បានផ្តល់កិច្ចគាំទ្រហិរញ្ញវត្ថុជាប្រចាំ ជូនដល់ឪពុកម្តាយរបស់ពួកគេ។ អ្នកផ្តល់ការឆ្លើយតប ក៏ទំនងនឹងផ្តល់សេចក្តីរាយការណ៍ផងដែរថា ពួកគេបានទទួលកិច្ចគាំទ្រជាសម្ភារៈច្រើនជាង ពីកូនដែលបានធ្វើទេសន្តរប្រវេសន៍ បើធៀបនឹងការដែលកូនបានទទួលការឧបត្ថម្ភគាំទ្រពីពួកគេ ក្នុងអំឡុងពេលដែលកូនបានចាកចេញពីពួកគេ។ លើសពីនេះទៀត សមាមាត្រានៃកូនស្រីធ្វើទេសន្តរប្រវេសន៍បានរួមចំណែកផ្តល់ការឧបត្ថម្ភដល់ឪពុកម្តាយក្នុងលំហូរវិជ្ជមាននេះ មានកម្រិតខ្ពស់ជាងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងការឧបត្ថម្ភដែលផ្តល់ជូនដោយកូនប្រុសដែលបានធ្វើទេសន្តរប្រវេសន៍។

បើទោះបីជាការធ្វើទេសន្តរប្រវេសន៍របស់កូន ចេញពីឪពុកម្តាយរបស់ពួកគេ កាត់បន្ថយឱកាសនៃ ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃក៏ដោយ ការប្រើប្រាស់ទូរស័ព្ទចល័តយ៉ាងទូលំទូលាយនាពេល បច្ចុប្បន្ន បានជួយសម្របសម្រួលដល់ឪពុកម្តាយ និងកូនដែលធ្វើទេសន្តរប្រវេសន៍ឲ្យប្រាស្រ័យ ទាក់ទងគ្នាបានយ៉ាងងាយស្រួល បើទោះបីជាពួកគេរស់នៅឆ្ងាយពីគ្នាក៏ដោយ។ ការស្រាវជ្រាវរបស់ យើងបានរកឃើញថា កូនភាគច្រើនដែលរស់នៅក្រៅស្រុក ដែលឪពុកម្តាយរបស់ពួកគេរស់នៅ មិនចំពោះថា ពួកគេរស់នៅក្នុង ឬ ក្រៅប្រទេសកម្ពុជាក៏ដោយ ពួកគេតែងនិយាយ និង/ឬ បានទៅ សួរសុខទុក្ខឪពុកម្តាយរបស់ពួកគេ យ៉ាងហោចណាស់មួយដងក្នុងមួយខែ។ អ្នកធ្វើទេសន្តរប្រវេសន៍ ទាំងពីរប្រភេទនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើទូរស័ព្ទដៃ ច្រើនជាងការមកសួរសុខទុក្ខផ្ទាល់ ដើម្បីរក្សាទំនាក់ទំនង។ ការប្រាស្រ័យទាក់ទងទាំងនេះ មានកម្រិតទាបជាង ប៉ុន្តែក៏អាចយកទៅធ្វើការ ប្រៀបធៀបបានជាមួយកូនដែលមិនរស់នៅក្នុងភូមិតែមួយ ប៉ុន្តែ រស់នៅក្នុងស្រុកតែមួយជាមួយ ឪពុកម្តាយរបស់ពួកគេ ដែលកូនទាំងនោះ មិនត្រូវបានការសិក្សាស្រាវជ្រាវនេះចាត់ទុកថាជាជន ទេសន្តរប្រវេសន៍។

ទាក់ទងទៅនឹងការថែទាំចៅ មានតែអ្នកផ្តល់ការឆ្លើយតបចំនួន ៦% ប៉ុណ្ណោះ ដែលមានកូនធ្វើទេសន្តរប្រវេសន៍ ធ្លាប់ចាកចេញពីស្រុករបស់ពួកគេ ដើម្បីទៅថែទាំចៅ យ៉ាងហោចណាស់រយៈពេល ៣ខែ នៅពេលដែលឪពុកម្តាយរបស់ពួកគេ បានធ្វើទេសន្តរប្រវេសន៍ទៅឆ្ងាយ។ បើតាមការប្រៀប ធៀប ២២% នៃអ្នកផ្តល់ការឆ្លើយតបដោយឡែកពីគ្នាទាំងនេះ ធ្លាប់បានថែទាំចៅដែលរស់នៅ ជាមួយពួកគេ យ៉ាងហោចណាស់រយៈពេល ៦ខែ នៅពេលដែលឪពុកម្តាយរបស់ពួកគេបានធ្វើ ទេសន្តរប្រវេសន៍។ ទាក់ទងទៅនឹងថ្លៃចំណាយសម្រាប់ការចិញ្ចឹមចៅ ក្នុងអំឡុងពេលនៃការថែទាំ ចៅទាំងនោះ ជីដូនជីតាបានគ្របដណ្តប់ទៅលើការចំណាយភាគច្រើន ឬ ការចំណាយទាំងស្រុង ក្នុងកម្រិតសមាមាត្ររហូតដល់បីភាគប្រាំ។

កិច្ចសម្ភាសន៍បែបគុណវិស័យជាមួយឪពុកម្តាយ បានគូសបញ្ជាក់អំពីចំណុចរួមជាច្រើន និងជួយពង្រឹងបន្ថែមលើរបកគំហើញនៃការស្រាវជ្រាវបែបបរិមាណវិស័យ។ ជាទូទៅ ឪពុកម្តាយ

មានការបារម្ភអំពីសុខុមាលភាពកូនប្រុសស្រីរបស់ពួកគេ និងយល់អំពីហានិភ័យដែលពាក់ព័ន្ធនៅក្នុងការធ្វើទេសន្តរប្រវេសន៍ ដោយទទួលស្គាល់ទៅលើហានិភ័យនៃការធ្វើទេសន្តរប្រវេសន៍ឆ្លងដែនថា មានភាពធ្ងន់ធ្ងរជាងហានិភ័យដែលទាក់ទងទៅនឹងការធ្វើទេសន្តរប្រវេសន៍ក្នុងប្រទេស។ ដូច្នេះ ឪពុកម្តាយចង់ឲ្យកូនរបស់ពួកគេ ដែលធ្វើទេសន្តរប្រវេសន៍ឆ្លងដែន ប្រើប្រាស់ភ្នាក់ងារជ្រើសរើសបុគ្គលិកផ្លូវការ ជាជាងភ្នាក់ងារជ្រើសរើសបុគ្គលិកមិនផ្លូវការ ប៉ុន្តែ បើទោះជាដូច្នេះក្តី បច្ចុប្បន្ន អាជ្ញាធរមូលដ្ឋានមួយចំនួន មានការយល់ដឹងអំពីភាពចាំបាច់ក្នុងការត្រួតពិនិត្យ ទៅលើភ្នាក់ងារជ្រើសរើសបុគ្គលិកផ្លូវការ។ បើទោះបីជាឪពុកម្តាយមួយចំនួនមានភាពស្ទាក់ស្ទើរក្នុងការអនុញ្ញាតឲ្យកូនរបស់ពួកគេ ជាពិសេស គឺកូនស្រីធ្វើទេសន្តរប្រវេសន៍ក៏ដោយ ប៉ុន្តែ បរាជ័យក្នុងការធ្វើស្រែចម្ការ និងការកើនឡើងនៃបំណុល បានបង្ខំឲ្យពួកគេទុកការព្រួយបារម្ភបែបនេះឲ្យនៅដោយឡែក ដោយសង្ឃឹមថា អាចទទួលបានប្រយោជន៍ជាសក្តានុពលពីប្រាក់ដែលកូនផ្ញើឲ្យ។ ឪពុកម្តាយមានភាពរីករាយចំពោះលទ្ធភាព និង ភាពងាយស្រួលនៃការប្រាស្រ័យទាក់ទងតាមទូរស័ព្ទ ជាមួយកូនរបស់ពួកគេដែលធ្វើទេសន្តរប្រវេសន៍ ដែលធ្វើឲ្យពួកគេមានទំនុកចិត្តមួយកម្រិតពីការភ័យខ្លាច ក្នុងការទំនាក់ទំនងជាមួយកូន នៅពេលពួកគេមានជម្ងឺ។ សតិអារម្មណ៍ របស់ឪពុកម្តាយ ទាក់ទងទៅនឹងបញ្ហាសុវត្ថិភាពការដែលមានកូនមួយចំនួននៅឯផ្ទះ ឬ រស់នៅក្បែរ ក៏ត្រូវបានគេមើលឃើញថា មានសារៈសំខាន់ដូចគ្នា ឬ មានសារៈសំខាន់ជាងការដែលមានកូន ធ្វើទេសន្តរប្រវេសន៍។

បទពិសោធន៍របស់ឪពុកម្តាយដែលមានវ័យចំណាស់ ទាក់ទងទៅនឹងការធ្វើទេសន្តរប្រវេសន៍ ឆ្លុះបញ្ចាំងអំពីធម្មជាតិអវិជ្ជមានរបស់វានៅក្នុងប្រទេសកម្ពុជា។ ការធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេស រមែងតែងធ្វើឡើងតាមរដូវកាល និងទទួលបានប្រាក់កម្រៃទាប ប៉ុន្តែ ការអនុញ្ញាតឲ្យកូនស្រីទៅ ធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ នៅឯរាជធានីភ្នំពេញ អាចទទួលបានប្រយោជន៍ហិរញ្ញវត្ថុខ្ពស់ គួរឲ្យកត់សម្គាល់។ ស្រដៀងគ្នានេះដែរ ប្រាក់កម្រៃ និងប្រាក់បញ្ញើដែលកូនធ្វើទេសន្តរប្រវេសន៍ ទៅក្រៅប្រទេស រកបាន និង ផ្ញើជូនឪពុកម្តាយរបស់ពួកគេ អាចអាស្រ័យទៅលើទីកន្លែងដែល ពួកគេទៅ។ ជាលទ្ធផល បទពិសោធន៍ផ្ទាល់ខ្លួនរបស់គ្រួសារទេសន្តរប្រវេសន៍ដែលមានវ័យចំណាស់ មានភាពខុសប្លែកពីគ្នាគួរឲ្យកត់សម្គាល់។ ការមានកូនធ្វើទេសន្តរប្រវេសន៍ មិនចំពោះការធ្វើទេសន្តរប្រវេសន៍ក្នុងស្រុក ឆ្លងដែន ឬ ទាំងពីរប្រភេទឡើយ អាចមានគុណសម្បត្តិសម្រាប់បុគ្គលមួយចំនួន និងគុណវិបត្តិសម្រាប់បុគ្គលដទៃទៀត។ តើអ្វីទៅដែលបណ្តាលឲ្យមានភាពខុសប្លែកពីគ្នាទាំងនេះ? ជាក់ស្តែង ប្រភេទនៃការងារក្នុងប្រទេស ឬ ការងារឆ្លងដែន អាចមានទំនាក់ទំនង ជាច្រើនទៅនឹងនិន្នាការនៃជោគជ័យ។ ការធ្វើទេសន្តរប្រវេសន៍តាមរយៈបណ្តាញផ្លូវការ ជំនួសឲ្យបណ្តាញមិនផ្លូវការ ក៏អាចជួយធានាឲ្យទទួលបានជោគជ័យផងដែរ។ ប៉ុន្តែ រឿងរ៉ាវរបស់អ្នកផ្តល់ ការឆ្លើយតបរបស់យើង ដែលមានវ័យចំណាស់ បានធ្វើការចង្អុលទៅលើទិសដៅដទៃទៀតផងដែរ និងពន្យល់អំពីឥទ្ធិពលនៃការធ្វើទេសន្តរប្រវេសន៍ទៅលើសុខុមាលភាពទូទៅផ្នែកសម្ភារៈ និងផ្លូវចិត្តរបស់ពួកគេ។ ក្នុងនោះរាប់បញ្ចូលចរិកលក្ខណៈនៃកូនរបស់ពួកគេ ការមានកូនដទៃទៀតរស់នៅជាមួយ ឬ រស់នៅក្បែរ ការមានកូនគ្រប់គ្រាន់ ដើម្បីធានាឲ្យមាននូវប្រភេទនៃការឧបត្ថម្ភគាំទ្រផ្សេងៗគ្នា ការមានសហព័ទ្ធដែលនៅមានជីវិតរស់នៅ ការមានសុខភាពល្អ ការមានដី

និងមធ្យោបាយ ឯករាជ្យក្នុងការរស់នៅ និង ការមានអារម្មណ៍ថាមានបុណ្យកុសល្យនៅក្នុងខ្លួន ខណៈពេលដែល ពួកគេកំពុងខិតទៅរកការស្លាប់។

សរុបមក ផ្ទុយពីទស្សនៈដែលយល់ឃើញថា ការធ្វើទេសន្តរប្រវេសន៍របស់កូនពេញវ័យ នៅក្នុង ប្រទេសកម្ពុជា មានផលវិបាកសង្គមអវិជ្ជមាន ទៅលើឪពុកម្តាយដែលមានវ័យចំណាស់ ការស្រាវជ្រាវ របស់យើង បានបង្ហាញឲ្យឃើញអំពីផលប៉ះពាល់វិជ្ជមានទូទៅ ចំពោះសុខុមាលភាព របស់ឪពុកម្តាយ ដែលមានវ័យចំណាស់។ ចំណុចនេះផ្តល់នូវកិច្ចគាំទ្រមួយចំនួនទៅលើគោលគំនិត ថា "ការផ្លាស់ប្តូរ ទំនាក់ទំនងនៅក្នុងគ្រួសារធំ" កំពុងកើតមានឡើង រវាងឪពុកម្តាយដែលមានវ័យ ចំណាស់ និងកូន ដែលធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ បើទោះបីជាការសិក្សា របស់យើងបានបង្ហាញ អំពីផលប៉ះពាល់វិជ្ជមានទូទៅ នៃការធ្វើទេសន្តរប្រវេសន៍ទៅលើឪពុកម្តាយ ដែលមានវ័យចំណាស់ ក៏ដោយ ក៏នៅតែមានវិស័យមួយជាក់លាក់គួរឲ្យបារម្ភ។ អ្នកផ្តល់ការឆ្លើយតប ដែលមានកូនទាំងអស់ មិនរស់នៅក្នុងភូមិ (ដែលគេអាចចាត់ទុកថាត្រូវបានបោះបង់ចោល) មាន ចំនួនតិចជាង ១០% ប៉ុន្តែ ពួកគេភាគច្រើន គឺជាអ្នកដែលគ្មានដី និង ក្រីក្រ។ បើគេធ្វើការ ប្រៀបធៀប ជាពិសេស ជាមួយអ្នក ផ្តល់ការឆ្លើយតបដែលមានកូនម្នាក់រស់នៅជាមួយ កម្រិតនៃ ភាពគ្មានដីរបស់ពួកគេ មានភាពខ្ពស់ជាង ហើយមធ្យមភាគពិន្ទុសុខភាពរបស់ពួកគេមានកម្រិត ទាបជាង។ គោលនយោបាយ និងកម្មវិធី របស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែល ត្រូវបានអភិវឌ្ឍន៍ដើម្បីកាត់បន្ថយផលប៉ះពាល់ អវិជ្ជមាននៃការធ្វើទេសន្តរប្រវេសន៍ អាចអនុវត្តន៍ និងទទួលបានជោគជ័យល្អប្រសើរ ប្រសិនបើ គោលនយោបាយ និងកម្មវិធីទាំងនោះ ផ្តោត គោលដៅទៅលើប្រជាជនប្រភេទនេះ។

បើទោះបីជាការសិក្សារបស់យើងបានបង្ហាញអំពី ការរួបរួមគ្នាពីជំនាន់មួយទៅជំនាន់មួយ រវាងឪពុកម្តាយ និង កូនដែលធ្វើទេសន្តរប្រវេសន៍ និងកូនមិនធ្វើទេសន្តរប្រវេសន៍ កើតឡើងនៅក្នុង បរិបទរួមមួយនៃភាពក្រីក្រ។ ទ្រព្យសម្បត្តិរបស់ឪពុកម្តាយដែលមានវ័យចំណាស់ មិនសូវមាន ច្រើនឡើយ ហើយគេអាចស្រម៉ៃឃើញថា ប្រសិនបើពុំមានការជួយឧបត្ថម្ភពីកូនទេនោះ ទ្រព្យ សម្បត្តិ ទាំងនោះ ប្រាកដជានឹងកាន់តែតិចទៅៗ។ កូនអាចដើរតួនាទីមួយក្នុងការកាត់បន្ថយផល ប៉ះពាល់ នៃភាពក្រីក្រនៅតំបន់ជនបទ ទោះជាដូច្នេះក្តី ភាពក្រីក្រនៅតែបន្តមានវត្តមាន។ បើទោះបី ជាឱកាសក្នុងការធ្វើទេសន្តរប្រវេសន៍អាចជួយដល់ឪពុកម្តាយវ័យចំណាស់ ដែលរស់នៅតំបន់ជនបទ តាមរយៈការឧបត្ថម្ភគាំទ្រពីកូនដែលធ្វើទេសន្តរប្រវេសន៍ក៏ដោយ ក៏មានមូលហេតុមួយ ចំនួនដែល ត្រូវប្រុងប្រយ័ត្នផងដែរ។ គ្រួសារដែលមានកូនតិច និង គ្រួសារដែលទំនងនឹងមានទំហំ កាន់តែតូច នៅពេលអនាគត អាចបង្កឲ្យមានផលប៉ះពាល់ទៅលើការប្រាស្រ័យទាក់ទងរវាងមនុស្ស មួយជំនាន់ ទៅមនុស្សមួយជំនាន់ទៀត។

# ឯកសារយោង


Aborderin, I. (2004) Modernisation and ageing theory revisited: Current explanations of recent developing world and historical Western shifts in material family support for older people. *Ageing & Society,* 24(1), 29-50

Analyzing Development Issues, (2005) *Impact of the Garment Industry on Rural Livelihoods: Lessons from Prey Veng Garment Workers and Rural Households*. Phnom Penh, Cambodia: Cooperation Committee for Cambodia.

Ang, S., Oeur, I. and McAndrew, J. (2007) Understanding social capital in response to floods and droughts. *Cambodian Development Review,* 11 (4), 9-12.

Ballard, B.M. (2007) Executive summary. In *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap.* Phnom Penh, Cambodia: Cambodia Development Research Institute.

Cai, Q. (2003) Migrant remittances and family ties: A case study in China. *International Journal of Population Geography*, 9(6), 471-483.

Chan, S. (2008) The political economy of managing labour migration. *Cambodia Development Review*, 12 (1), 1-4.

Chan, S. (2009) *Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study*. Working Paper Series No.44. Phnom Penh, Cambodia: Cambodia Development Research Institute.

FitzGerald, I., So, S., Chan, S., Kem, S., and Tuot S. (2007) *Moving Out of Poverty?: Trends in Community Well-Being and Household Mobility in Nine Cambodian Villages*. Phnom Penh, Cambodia: Cambodia Development Research Institute.

Hendricks, J., and Yoon, H. (2006) The sweep of age and aging: Changing mores, changing policies. In J. Hendricks and H. Yoon (Eds.), *Handbook of Asian Aging* (pp. 1-22). Amityvile: Baywood Publishing.

Hermalin, A. I., Ofstedal, M.B., and Shih,S.R. (2003) Patterns of intergenerational support in urban China and urban Taiwan. In M.K. Whyte (Ed.), *China's Revolutions and Intergenerational Relations* (pp. 255-275). Ann Arbor, MI: Center for Chinese Studies, The University of Michigan.

Holliday, J. (2011) *Cambodia's Labour Migration: Analysis of the Legal Framework.* Phnom Penh, Cambodia: The Asia Foundation.

Human Rights Watch (2011) *"They Deceived Us at Every Step": Abuse of Cambodian Domestic Workers to Malaysia.* New York, USA: Human Rights Watch.

Knodel, J., Kespichayawattana, J., Saengtienchai, C., and Wiwatwanich, S. (2010) How left behind are rural parents of migrant children: Evidence from Thailand. *Ageing and Society* 30(5): 811-841, July 2010.

Knodel, J., Kim, K.S., Zimmer, Z., and Puch, S. (2005) *Older persons in Cambodia: A profile from the 2004 Survey of the Elderly*. UNFPA Cambodia and Royal University of Phnom Penh, Phnom Penh, Cambodia: UNFPA and RUPP.

Lim, S. (2008) Youth migration in Cambodia. *Cambodia Development Review*, 12(4), 1-5.

Litwak, E. (1960) Geographic-mobility and extended family cohesion. *American Sociological Review*, 25, 385-394.

Litwak, E. (1987) Technology, proximity and measures of kin support. *Journal of Marriage and the Family* 49, 649-661.

Murshid, K.A.S. (2007) Chapter 7: Domestic and cross-border migration from the Tonle Sap. In B.M. Ballard (Ed.), *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap.* Phnom Penh, Cambodia: Cambodia Development Research Institute.

Smith, G.C. (1998) Residential separation and patterns of interaction between elderly parents and their adult children. *Progress in Human Geography* 22, 368-384.

Stark, O. and Bloom, D.E. (1985) The new economics of labor migration. *American Economic Review* 75(2), 173-178.

Stark, O. and Lucas, R.E.B. (1988) Migration, remittances and the family. *Economic Development and Cultural Change* 36(3), 465-481.

Tong, K. (2010) Migration, Remittances and Poverty Reduction: Evidence from Cambodia. Unpublished paper. Phnom Penh, Cambodia: Cambodia Development Research Institute.

Vanwey, L. K. (2004) Altruistic and contractual remittances between male and female migrants and households in rural Thailand. *Demogrphy,* 41, 739-756.

Zimmer, Z., Korinek, K., Knodel, J., and Chayovan, N. (2008) Migrant interactions with elderly parents in rural Cambodia and Thailand. *Journal of Marriage and the Family*, 70(4), 585-598.

# អ្នកស្រាវជ្រាវ

## កម្មសិក្សាស្រាវជ្រាវ

| | |
|---|---|
| ជា សំណាង | Enfants & Developpement |
| សូ សៀងសុធារី | មជ្ឈមណ្ឌលប្រជាជនសម្រាប់ការអភិវឌ្ឍន៍ និងសន្តិភាព |
| តឹក វណ្ណារ៉ា | សមាគមថែរក្សាវប្បធម៌ និងបរិស្ថាន |
| ឆន តុលា | អង្គការអភិវឌ្ឍន៍សហគមន៍ |
| លឹម សុភា | អង្គការពុទ្ធិកុមារ |
| ព្រហ្ម គឹមឆេង | មជ្ឈមណ្ឌលសមាគមកុមាររីករាយ |
| ប៉ិល ម៉ាទីន | អង្គការវឌ្ឍនភាព |
| ទូច ធូ | អង្គការអូខិនជិនកម្ពុជា |
| មាស ចាន់ថន | អង្គការសហប្រតិបត្តិការសម្រាប់សេវាកម្មសង្គម និងការអភិវឌ្ឍន៍ |
| ភាព សុជា | កម្មវិធីអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ |
| យឹម នីម៉ូឡា | មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ |

## ក្រុមស្រាវជ្រាវ

| | |
|---|---|
| Zachary Zimmer | សាកលវិទ្យាល័យកាលីហ្វ័រញ៉ា រដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ |
| John Knodel | សាកលវិទ្យាល័យមីឈីហ្គិន/មជ្ឈមណ្ឌលសិក្សាប្រជាជន |
| Chanpen Saengtienchai | អ្នកស្រាវជ្រាវឯករាជ្យ |
| ហាក់ សុចន្ទី | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| អឿ អ៊ីល | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| ជេន សុជឿន | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| សូ ដាណេ | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| ហ៊ួន កល្យាណ | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| ឃួន ច័ន្ទដូរេ | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |
| John McAndrew | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា/គម្រោង ADI |

# គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

## ទស្សនវិស័យ:

សង្គមស៊ីវិលមួយដែលមានការសហការដ៏រឹងមាំ និងមានសមត្ថភាព ឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍន៍នៅកម្ពុជា ។

## បេសកកម្ម:

ក្នុងឋានៈជាសមាគមនដែលមានវិជ្ជាជីវៈមួយនៃអង្គការមិនមែន រដ្ឋាភិបាលនៅកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ផ្តល់សេវាកម្មប្រកបដោយគុណភាព ខ្ពស់ជូនដល់សង្គម ស៊ីវិល និង បង្ករលក្ខណៈអោយមានឥទ្ធិពលដល់ដៃគូអភិវឌ្ឍន៍នៃ ប្រទេសកម្ពុជាយើង ។

## គុណតំលៃ:

- សុច្ចរិតភាព
- កិច្ចសហប្រតិបត្តិការ
- ភាពឆ្លើយតប
- គុណភាព

ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខ័ណ្ឌ ចំការមន
ប្រអប់សំបុត្រលេខ: ៨៨៥ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ១៥២/ ២១៦ ០០៩
ទូរសារលេខ: (៨៥៥-២៣) ២១៦ ០០៩
អ៊ីមែល: info@ccc-cambodia.org
គេហទំព័រ: www.ccc-cambodia.org

ឧបត្ថម្ភដោយ

eed Evangelischer Entwicklungsdienst · Broederlijk Delen omdat het zuiden plannen heeft · TROCAIRE Working for a Just World · Oxfam Hong Kong · christian aid JOINT PROGRAMME · esp